សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit  et des Sciences Economiques

ROYAL UNIVERSITY OF LAWS AND ECONOMICS


## សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ស្រាវជ្រាវពីថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លុចហេង ម៉េងថៃ**

សាស្ត្រាចារ្យណែនាំ

លោក **ខឿក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **លុចហេង ម៉េងថៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ ក្រុម L4A2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២១។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក **គីម មិនាលុច** និង អ្នកម្ដាយ **គុង គឹមហេង** ជាទីគោរពដែលលោកទាំងពីរមានគុណដ៏ខ្ពង់ខ្ពស់មិនអាចកាត់ថ្លៃបាន ដោយលោកទាំងពីរបានចិញ្ចឹមបីបាច់ថែរក្សារូបកូនតាំងពីតូចរហូតដល់ធំ ដោយមិនគិតពីការនឿយហត់ដើម្បីផ្គត់ផ្គង់កូនឲ្យបានចូលរៀន ទោះជាជួបឧបសគ្គធំប៉ុណ្ណាក៏ដោយចុះ លោកទាំងពីរតែងតែលើកទឹកចិត្ត គាំទ្រ និងជម្រុញឲ្យខ្ញុំពុះពារឆ្លងកាត់ការសិក្សាពីកម្រិតមួយទៅកម្រិតមួយទៀត។

ជាបន្ទាប់ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលកន្លងមកលោកបានខិតខំដឹកនាំនិងគ្រប់គ្រងអោយដំណើរការប្រព័ន្ធអប់រំនៅទីនេះមានភាពល្អប្រសើរ និងប្រព្រឹត្តទៅដោយរលូនរួមទាំងផ្តល់ការអនុញ្ញាតអោយខ្ញុំបាទបានចូលសិក្សាក្នុងថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ នៅសាកលវិទ្យាល័យនេះផងដែរ និងបង្កភាពងាយស្រួលដល់ការសិក្សារបស់ខ្ញុំបាទកន្លងមក ក្នុងគោលបំណងសម្រេចបាននូវធនធានមនុស្សសម្រាប់សង្គមជាតិក្នុងគោលដៅអភិវឌ្ឍប្រទេសជាតិប្រកបទៅដោយចីរភាព និងនិរន្តរភាព។

សូមថ្លែងអំណរគុណ **លោកគ្រូ អ្នកគ្រូ លោក/លោកស្រីសាស្ត្រាចារ្យ** ដែលបានបង្រៀនអប់រំខ្ញុំបាទកន្លងមក ដោយមិនគិតពីសេចក្តីលំបាកអ្វី និងមានឆន្ទៈដ៏ល្អឯកក្នុងការផ្ទេរចំណេះដឹងអោយសិស្សនិស្សិតគ្រប់ជំនាន់។

លើសពីនេះខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនដល់ **លោកសាស្ត្រាចារ្យ ឌឿក ពិដោរ** ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹកពីការបង្រៀនដើម្បីធ្វើការដឹកនាំខ្ញុំបាទសរសេរសារណា បញ្ចប់ការសិក្សាដោយមិនខ្លាចនឿយហត់ក្នុងការផ្តល់គោលគំនិតមតិយោបល់ បែបបទ និងយុទ្ធសាស្ត្រសំខាន់ៗតាំងពីចាប់ផ្តើមរហូតដល់សារណានេះត្រូវបានបញ្ចប់ដោយជោគជ័យ។

ជាចុងក្រោយខ្ញុំបាទ សូមប្រសិទ្ធពរជ័យជូនទៅដល់អ្នកមានគុណទាំងអស់អោយជួបតែក្តីសុខនៅក្នុងក្រុមគ្រួសារជាពិសេសអោយជួបតែពុទ្ធិពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅសារាណាបញ្ចប់ការសិក្សាដែលនិយាយអំពី “ **កំណែទម្រង់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** ” នេះ ត្រូវបានតាក់តែងឡើងដោយផ្អែកលើ កម្មវិធីធ្វើកំណែទម្រង់ដែលបានចេញដោយរាជរដ្ឋាភិបាល និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សៀវភៅនេះទាក់ទងនឹងបញ្ហាក្នុងការផ្តល់សេវាសាធារណៈបច្ចុប្បន្ន ការផ្លាស់ប្តូរវិធីសាស្រ្តក្នុងការផ្តល់សេវារដ្ឋបាល ក៏ដូចជាការផ្លាស់ប្តូរលើប្រព័ន្ធថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សៀវភៅនេះអាចឲ្យអ្នកអានទទួលបាននូវចំណេះដឹងពាក់ព័ន្ធនឹងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែប្រែដែលជាទ្រឹស្តីអភិវឌ្ឍដើម្បីឆ្ពោះទៅរកភាពជឿនលឿន និងរីកចម្រើន។

ខ្ញុំបាទសូមថ្លែងអំណគុណដល់លោកសាស្រ្តាចារ្យ “ ឌឿក ពិដោរ ” ដែលបានជ្រោមជ្រែង ផ្តល់ជាគំនិត យោបល់ល្អៗដល់ខ្ញុំបាទ ទើបនាំឲ្យខ្ញុំបាទអាចសរសេរសៀវភៅនេះបាន។

ខ្ញុំបាទនឹងទទួលទាំងអស់នូវការរិះគន់ ដើម្បីស្ថាបនាសៀវភៅនេះបន្ថែមឲ្យកាន់តែប្រសើរឡើង។

ជាចុងក្រោយខ្ញុំបានសូមជូនពរដល់ សាស្រ្តាចារ្យនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ មិត្តៗអ្នកអាន សិស្សានុសិស្សទាំងឡាយឲ្យជួបប្រទះតែភាពជោគជ័យនៅក្នុងជីវិត និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២១

លុចហេង ម៉េងថៃ

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ១

## ជំពូកទី ១
## កំណែទម្រង់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ក. កំណែទម្រង់រចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** ៣

ក.១ បញ្ហាដែលទាមទារឲ្យមានការកែទម្រង់រដ្ឋបាល ៣

ក.២. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៤

ក.៣. លក្ខខណ្ឌក្នុងការធ្វើសកម្មភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ៦

ក.៤. ការកែប្រែរបៀបផ្តល់សេវា ៧

ក.៥. គោលដៅធ្វើកំណែទម្រង់រចនាសម្ព័ន្ធ ៨

**ខ. កំណែទម្រង់មនុស្ស** ១២

ខ.១.ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ១២

ខ.១.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ១២

ខ.១.២. ប្រធានក្រុមប្រឹក្សា ១៤

ខ.១.៣. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ១៤

ខ.២. គណៈអភិបាលក្រុង ស្រុក ខណ្ឌ ១៥

ខ.៣. ទំនាក់ទំនងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ១៧

ខ.៣.១. ទំនាក់ទំនងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយ ថ្នាក់ជាតិ ១៧

ខ.៣.២. ទំនាក់ទំនងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមួយ  គណៈអភិបាល ១៧

## ជំពូកទី ២
## កំណែទម្រង់ហិរញ្ញវត្ថុ

**គ. ថវិកាកម្មវិធី** ១៩

គ.១. អ្វីទៅជាថវិកាកម្មវិធី ១៩

គ.២. ដំណើរការរៀបចំថវិកាកម្មវិធី ១៩
**ឃ. ប្រតិបត្តិការចំណូលចំណាយ** ២៨
ឃ.១. ប្រភពចំណូលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ២៨
ឃ.២. កំណែទម្រង់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ២៩
ឃ.២.១. ការរៀបចំ និងការអនុម័តថវិកា ២៩
ឃ.២.២. ការអនុវត្តនិងការត្រួតពិនិត្យថវិកា ៣០
ឃ.៣. ការកែប្រែបហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ៣៣
ឃ.៣.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា ៣៣
ឃ.៣.២. ការកសាង និងអភិវឌ្ឍសមត្ថភាព ៣៤
ឃ.៣.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣៤
**សេចក្តីសន្និដ្ឋាន** ៣៥
**ការផ្តល់អនុសាសន៍** ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅទូទាំងសកលលោក ពីមួយសម័យកាលទៅមួយសម័យកាល រមែងតែមានការរីកចម្រើន ឬ ការផ្លាស់ប្តូរទៅតាមបរិបថរបស់សង្គមនីមួយៗ ហើយការផ្លាស់ប្តូរទាំងនោះសុទ្ធតែធ្វើឡើងដើម្បីសម្របទៅតាមបរិបថជាក់ស្តែង បំពេញតម្រូវការចាំបាច់ និង ធ្វើឲ្យមានភាពងាយស្រួល។ ជាក់ស្តែង រដ្ឋបាលក៏ត្រូវការផ្លាស់ប្តូររបៀបរបបធ្វើការ និងការកែប្រែលើផ្នែកផ្សេងៗទៀត ដើម្បីបម្រើដល់ប្រជាពលរដ្ឋឲ្យបានសមប្រកបទៅតាមសម័យកាលនីមួយៗ។ ការកែប្រែនេះ ត្រូវបានគេហៅថា កំណែទម្រង់ ដែលសំដៅដល់ការរៀបចំផ្លាស់ប្តូរទៅលើស្ថាប័នសាធារណៈដែលធ្វើឡើងដើម្បីឲ្យមានការរីកចម្រើននៃទម្រង់ការបំពេញការងារ និងគុណភាពនៃការងារ។ ហើយរដ្ឋបាលសំដៅដល់ ស្ថាប័នសាធារណៈដែលគ្រប់គ្រង ដែន ឬតំបន់។ សរុបមក កំណែទម្រង់រដ្ឋបាលគឺជាយុទ្ធសាស្ត្រ នៃការជំរុញឲ្យមាន ការរៀបចំកែប្រែទៅលើរដ្ឋបាលតាមបែបប្រជាធិបតេយ្យ និងមានការរីកចម្រើនសមស្របទៅនឹងស្ថានភាពក្នុងសង្គម ទាំងទម្រង់ ការបំពេញការងារ និងគុណភាពនៃការងារ ។ បើយោងតាមវចនានុក្រមបារាំង Dictionnaire encyclopédique កំណែទម្រង់រដ្ឋបាល[1]គឺជា ការផ្លាស់ប្តូរមនសិការ និងប្រកបដោយពិចារណាបញ្ចូលទៅក្នុងអង្គការមួយឬ ប្រព័ន្ធសាធារណៈមួយដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវរចនាសម្ព័ន្ធរបស់ខ្លួន ការប្រព្រឹត្តទៅរបស់ខ្លួន និង គុណភាពនៃបុគ្គលិករបស់ខ្លួន។

នៅកម្ពុជា កំណែទម្រង់រដ្ឋបាលត្រូវបានចាប់ផ្តើមពីរដ្ឋបាលមូលដ្ឋានថ្នាក់ទាបគឺ រដ្ឋបាលឃុំ-សង្កាត់ទៅរដ្ឋបាលថ្នាក់ខ្ពស់គឺ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រោយពីបោះឆ្នោតឆ្នាំ ១៩៩៣ រួចមក ចាប់ពីឆ្នាំ ១៩៩៦-២០០០ គឺមានគម្រោងមួយធ្វើកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលមូលដ្ឋានបានចាប់ផ្តើមឡើង ដោយគម្រោងនេះត្រូវបានយកទៅអនុវត្តនៅតាមរដ្ឋបាលឃុំ-សង្កាត់ មួយចំនួននៅតាមបណ្តាខេត្តសំដៅដោះស្រាយបញ្ហាតម្រូវការតាមទីជនបទដោយប្រសិទ្ធិភាព ដើម្បីសម្រេចបានគម្រោងនេះផ្ទេរធនធានហិរញ្ញវត្ថុ និងអំណាចធ្វើសេចក្តីសម្រេចទៅឲ្យរដ្ឋបាលមូលដ្ឋាន។ ក្រោយមកក្នុងឆ្នាំ ២០០១ មានការធ្វើកំណែទម្រង់លើរដ្ឋបាលឃុំ-សង្កាត់ និងមានការបង្កើតគណៈកម្មាធិការជាតិសម្រាប់គាំទ្រឃុំ-សង្កាត់ ដែលជាគណៈកម្មាធិការជួយជ្រោមជ្រែងរដ្ឋបាលឃុំ-សង្កាត់អនុវត្តច្បាប់ស្តីពីរដ្ឋបាលឃុំសង្កាត់ បន្ទាប់ពីនោះ ក្នុងឆ្នាំ២០០៨ ទើបមានការធ្វើកំណែទម្រង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ហើយក៏មានការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ បន្ទាប់ពីបានធ្វើកំណែទម្រង់ ការផ្តល់សិទ្ធិអំណាចខាងហិរញ្ញវត្ថុ និងរដ្ឋបាល ត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយការងាររបស់ រាជរដ្ឋាភិបាលក៏

[1] វចនានុក្រមបារាំង Dictionnaire encyclopédique

បានផ្ទេរទៅផងដែរ។ដោយសារតែការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិបច្ចុប្បន្នមានលក្ខណៈមិន សមប្រកប ឬ មិនរហ័ស ដោយសារតែមិនទាន់មានការធ្វើទំនើបកម្មឲ្យទាន់ទៅនឹងតថភាពសង្គមបច្ចុប្បន្ន ដែលមានការរីកចម្រើនទាំងផ្នែក បច្ចេកវិទ្យា និងព័ត៌មានជាដើម ដែលនាំឲ្យមានការយឺតយ៉ាវដល់ការងាររបស់ប្រជាពលរដ្ឋ តួយ៉ាងដូចជាការផ្តល់សេវាមានភាពស្មុំញ៉ាំ ត្រូវឆ្លងការច្រើនដំណាក់ មានភាពយឺតយ៉ាវ នាំឲ្យប្រជាពលរដ្ឋមានការលំបាកក្នុងការទទួលបានសេវារដ្ឋបាល ទើបមានការកែប្រែដើម្បីឲ្យការផ្តល់សេវាមានភាពងាយស្រួល។ ហើយការកែប្រែរដ្ឋបាលនេះគឺមានគោលដៅក្នុងការអភិវឌ្ឍលើការផ្តល់សេវាសាធារណៈឲ្យមានភាពសាមញ្ញ ងាយស្រួលដល់ប្រជាពលរដ្ឋ ប្រសិទ្ធភាពអាចជឿទុកចិត្តបាន ឆាប់រហ័ស លើសពីនេះទៅទៀតការធ្វើកំណែទម្រង់ក៏អាចផ្តល់ជាការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល និង មានគោលដៅកែសម្រួលដល់ប្រព័ន្ធថវិកាដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ដោយសារតែរដ្ឋបាលឃុំ-សង្កាត់ ជារដ្ឋបានមូលដ្ឋានថ្នាក់ទាបហេតុដូចនេះ រដ្ឋបាលនេះមិនទាន់មានលទ្ធភាពក្នុងការបំពេញការងារទាំងអស់ទេ ទើបការធ្វើកំណែទម្រង់ត្រូវបានបញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភាពជិតដិតនឹងប្រជាពលរដ្ឋ។ ដោយហេតុថារដ្ឋបាលនេះ ទទួលការងារជាច្រើនដែលរដ្ឋ បាលថ្នាក់លើផ្ទេរមជ្ឈការមកឲ្យ ហេតុនេះរដ្ឋបាលនេះក៏ ត្រូវតែធ្វើកំណែទម្រង់បន្ថែមដើម្បីបម្រើសេវាឲ្យបានល្អដល់ប្រជាពលរដ្ឋផងដែរ។

តើរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើកំណែទម្រង់បែបណាខ្លះ ដើម្បីឲ្យមានភាពរហ័ស គុណភាពខ្ពស់ និង មានភាពងាយស្រួល?

ដើម្បីបកស្រាយនូវបញ្ហាដែលបានចោទឡើងខាងលើនេះឲ្យបានច្បាស់លាស់ និង ក្បោះក្បាយ យើងត្រូវសិក្សាទៅលើការធ្វើកំណែទម្រង់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ ( I ) ដែលក្នុងនោះមានកំណែទម្រង់លើរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ( ក ) និង កំណែទម្រង់លើមនុស្ស ( ខ ) និង កំណែទម្រង់ហិរញ្ញវត្ថុ (II) ដែលមាន ថវិកាកម្មវិធី ( គ ) និង ប្រតិបត្តិការចំណូលចំណាយ ( ឃ )។

# ជំពូកទី ១
# កំណែទម្រង់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ដើម្បីធ្វើឲ្យការប្រព្រឹត្តទៅរបស់រដ្ឋបាល មានភាពរលូន និង អាចធ្វើការបម្រើដល់ប្រជាពលរដ្ឋបាន រដ្ឋាភិបាលត្រូវធ្វើការកែប្រែទៅលើ ២ចំណុច ដែលមានឥទ្ធិពលទៅលើរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ។ ចំណុចទាំង ២នោះរួមមាន ការធ្វើកំណែទម្រង់លើរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង កំណែទម្រង់មនុស្ស។

## ក. កំណែទម្រង់រចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ក.១ បញ្ហាដែលទាមទារឲ្យមានការកែទម្រង់រដ្ឋបាល

បញ្ហាដែលទាមទារឲ្យមានការកែប្រែមានដូចជា៖

- សេវាសាធារណៈមិនទាន់ទទួលបានទំនុកចិត្តពេញលេញពីសាធារណៈជន
- ក្របខណ្ឌបទដ្ឋានលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ដល់សេវាសាធារណៈមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងប្រសិទ្ធភាព
- សមត្ថភាពរបស់មន្ត្រីសាធារណៈដើម្បីអនុវត្តច្បាប់គឺស្ថិតនៅក្រោមកម្រិតដែលត្រូវការ
- ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័ននៅមានកម្រិត
- សកម្មភាពអនុវត្តមិនសូវស្របនឹងគោលដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការរៀបចំរចនាសម្ព័ន្ធ និងការផ្ទេរមុខងារនិងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនទាន់ឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ
- តម្រូវការរបស់ប្រជាពលរដ្ឋ។

ហេតុនេះការធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាការកែប្រែពាក់ព័ន្ធនឹងការផ្ដល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានកែប្រែដើម្បីឲ្យមានភាពប្រសើរជាងមុន ងាយស្រួលជាងមុន និង បង្កើននូវទំនុកចិត្តជូនប្រជាពលរដ្ឋ។

ក្នុងការធ្វើកំណែទម្រង់រចនាសម្ព័ន្ធនេះមានគោលដៅដើម្បីបង្កើត និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយដើម្បីសម្រេចបានរាជរដ្ឋាភិបាលប្រើប្រាស់មធ្យោបាយដ៏មានប្រសិទ្ធិភាពមួយក្នុងការបង្វិតសេវាសាធារណៈឲ្យកាន់តែជិតប្រជាពលរដ្ឋដោយស្របតាម កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ក.២. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

**វិមជ្ឈការ** [2] មានន័យថា រាជរដ្ឋាភិបាលកម្ពុជា ប្រគល់នូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។ ការប្រគល់នូវភាពជាម្ចាស់នេះ ត្រូវបានធ្វើឡើងដោយរាជរដ្ឋាភិបាល ជាឧទាហរណ៍ រាជរដ្ឋាភិបាលផ្ទេរថវិកាចំនួន៥០លានរៀល ឲ្យទៅរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ដើម្បីអភិវឌ្ឍ។ ក្នុងន័យនេះ រដ្ឋបាលដែល មានក្រុមប្រឹក្សាជាថ្នាក់ដឹកនាំ មានសិទ្ធិសម្រេច ចាត់ចែង និងប្រើប្រាស់ថវិកាទាំងនោះ តាមតម្រូវការរបស់ស្រុក និងតម្រូវការអភិវឌ្ឍ។ តាមរយៈការធ្វើបែបនេះ ការអភិវឌ្ឍរបស់ស្រុក មានភាពរហ័ស ដោយសារការសម្រេចស្ថិតនៅអាជ្ញាធរមូលដ្ឋាន និងជិតប្រជាពលរដ្ឋជាងគេ។

**វិសហមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាលកម្ពុជា ធ្វើប្រតិភូកម្ម មុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ជាក់ស្តែង ការធ្វើវិស-ហមជ្ឈការនេះបានស្តែងតាម ការធ្វើប្រតិភូកម្មរបស់ក្រសួងមហាផ្ទៃ ដែលប្រគល់មុខងារធ្វើសេចក្តីចម្លងអត្រានុកូលដ្ឋានទៅឲ្យក្រុមប្រឹក្សាស្រុក ហើយអភិបាលស្រុកត្រូវបានប្រគល់ឲ្យអនុវត្តការងារនេះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ការធ្វើប្រតិភូកម្មនេះ គឺរដ្ឋបាលស្រុកត្រូវធ្វើមុខងារជំនួសឲ្យក្រសួង និងធ្វើក្នុងនាមក្រសួង។ ការធ្វើបែបនេះនឹងធ្វើឲ្យការផ្តល់សេវាមានភាពរហ័ស និងងាយស្រួលជូនប្រជាពលរដ្ឋ។

វិសហមជ្ឈការ និង វិមជ្ឈការខុសគ្នាត្រង់ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ ដោយភាពជាម្ចាស់នោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។

[2] យោងតាមសៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក

ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺធ្វើឡើងដើម្បីជម្រុញឲ្យការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើឡើងតាមគោលការណ៍នៃរដ្ឋបាលឯកភាព សំដៅបង្កើតជម្រុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសមាសធាតុ ៨៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

សមាសធាតុទាំង៨ មានទំនាក់ទំនងប្រទាក់ក្រឡាគ្នា និងមានគោលដៅរួមគឺ៖

- លើកកម្ពស់លទ្ធប្រជាធិបតេយ្យ
- ការផ្តល់សេវា និងការអភិវឌ្ឍ
- ការកាត់បន្ថយភាពក្រីក្រ

ដោយរាជរដ្ឋាភិបាលធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នោះ នាំឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់មានមុខងារ និងធនធានជារបស់ខ្លួន ដែលមានឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រង និងចាត់ចែងមុខងារ និងធនធានទាំងនោះស្របតាមលិខិតបទដ្ឋានជាធរមាន។ ហើយមុខងារដែលរដ្ឋបាលទទួលបានតាមរយៈការផ្ទេរពីថ្នាក់ជាតិ មានពីរប្រភេទ គឺ មុខងារជម្រើស និងមុខងារជាកាតព្វ-កិច្ច។ រាល់ការផ្ទេរមុខងារទាំងនេះថ្នាក់ជាតិត្រូវភ្ជាប់ជាមួយនូវធនធានចាំបាច់ និងការតាមដាន គាំទ្រផងដែរ។

### គ.៣. លក្ខខណ្ឌក្នុងការធ្វើសកម្មភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ទន្ទឹមនឹងការធ្វើកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ រាល់ការសម្រេច ឬ ធ្វើសកម្មភាពការងាររបស់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំធ្វើឡើយឲ្យស្របទៅតាមក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ដែលបានរៀបចំឡើងដើម្បីត្រួសត្រាយផ្លូវក្នុងការធ្វើកំណែទម្រង់។

➢ ក្របខ័ណ្ឌគោលនយោបាយ

ក្របខណ្ឌគោលនយោបាយដែលបានរៀបចំដោយរាជរដ្ឋាភិបាលមានៈ

– យុទ្ធសាស្ត្រចតុកោណ

ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ជាលក្ខខណ្ឌសំខាន់បំផុតក្នុងការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ ដែលមាន អភិបាលកិច្ចល្អនៅដំណាក់កាលទី១ ជាស្នូល។ នៅក្នុងកំណែទម្រង់រដ្ឋបាល រដ្ឋបាលត្រូវបានធ្វើកំណែលំអគុណភាពនៃសេវា និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។

– ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាឯកសារគោលនយោបាយរបស់កម្ពុជាដែលបានកំណត់អំពី ៖

- ចក្ខុវិស័យរបស់រដ្ឋាភិបាលអំពីកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋាបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

➢ ក្របខ័ណ្ឌច្បាប់

ចំពោះក្របខ័ណ្ឌច្បាប់ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាច្បាប់សម្រាប់រៀបចំអង្គការមូលដ្ឋានរបស់រាជរដ្ឋាភិបាល។ ហើយការបង្កើតច្បាប់នេះឡើងគឺជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនេះ។ ក៏ប៉ុន្តែដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលត្រូវរៀបចំលិខិតបទដ្ឋានជាច្រើនទៀតដើម្បីសម្រួលដល់បញ្ហាជាក់ស្តែង ហើយទាមទារឲ្យមានការត្រួតពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានជាបន្តបន្ទាប់ផងដែរ។

### ក.៤. ការកែប្រែរបៀបផ្តល់សេវា

ចំពោះការធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នេះត្រូវបានអនុវត្តចាប់ពីឆ្នាំ ១៩៩៣ ក្រោយមកទើបមានការពង្រីកវិសាលភាពនៃកំណែទម្រង់នេះ។ ក្រោយមកចាប់ពីឆ្នាំ ១៩៩៨ ដែលកម្ពុ-ជាមានសុខសន្តិភាព បញ្ហាតម្រូវការពាក់ព័ន្ធនឹង រដ្ឋបាល ក៏មានការកើនឡើង ហើយបញ្ហាទាំងនោះមានដូចជាការចំណាយពេលវេលាមិនសមស្រប ហើយតម្លៃចំណាយសម្រាប់សេវាក៏មិនទាន់មានតម្លាភាព។

ប៉ុន្តែក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានសម្រេចបង្កើតរដ្ឋបាលស្រុកគំរូ សាកល្បង ដោយមានបង្កើតការិយាល័យច្រកចេញចូលតែមួយ នៅស្រុកសៀមរាប នៃខេត្តសៀមរាប និងស្រុកបាត់ដំបង នៃខេត្តបាត់ដំបង។ ដោយសារតែមានលទ្ធផលល្អក្នុងការសាកល្បង និង មានការគាំទ្រច្រើនពីប្រជាពលរដ្ឋ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ ទើបក្រសួងមហាផ្ទៃ បានគៀងគររកការគាំទ្រមូលនិធិពីធនាគារពិភពលោក និងបានលើកសំណើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ដំណើរការសាកល្បង និងពង្រីកគម្រោងនេះទៅតាមក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តដែលនៅសល់។

កំណែទម្រង់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើឡើងដោយការបង្កើតឲ្យមាន « ការិយាល័យច្រកចេញចូលតែមួយ» ដើម្បីផ្តល់សេវាដល់ប្រជាពលរដ្ឋ និងជាដៃជើងរបស់រដ្ឋបាលដែលនៅកៀកនឹងប្រជាពលរដ្ឋ។

**ការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ស្រុក ខណ្ឌ គឺជា៖**

- កន្លែងផ្តល់សេវាកម្មរដ្ឋបាលដែលប្រជាពលរដ្ឋត្រូវការចាំបាច់ ឲ្យបានទាន់ពេលវេលា មានតម្លាភាព និងតាមនីតិវិធីសាមញ្ញ
- កន្លែងប្រមូលផ្តុំសេវាកម្ម និង នីតិវិធីរដ្ឋបាលមួយចំនួន
- កន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ និងទទួលព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ស្តីពីការផ្តល់សេវាសេវាសាធារណៈផ្សេងៗ និងការបង់កំរៃសេវាកម្ម ឬ អាករផ្សេងៗ
- កន្លែងផ្តល់លទ្ធផលសម្រេចជាផ្លូវការ លើសេចក្តីស្នើសុំដល់អតិថិជនវិញ។

**ការិយាល័យច្រកចេញចូលតែមួយមាន តួនាទី ភារកិច្ចដូចជា៖**

- ផ្តល់សេវាជូនអតិថិជន ដែលកំពុងធ្វើសកម្មភាពនៅក្នុងមូលដ្ឋាន ក្រុង ស្រុក ខណ្ឌ
- ផ្តល់ព័ត៌មានពិស្តារ និងព័ត៌មានទូទៅដល់ប្រជាពលរដ្ឋ និងអតិថិជននានា អំពីកិច្ចការរដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- ផ្តល់ព័ត៌មានអំពីនីតិវិធីរដ្ឋបាល ដែលជាសមត្ថកិច្ចរបស់ថ្នាក់ជាតិ និងថ្លៃសេវាកម្មសម្រាប់នីតិវិធីទាំងនេះ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ដីធ្លី ផែនការប្រើប្រាស់ដីធ្លី រួមទាំងព័ត៌មានគាំពារសុខភាព ការអប់រំ វប្បធម៌ និងបញ្ហាសង្គមផងដែរ។

**រចនាសម្ព័ន្ធការិយាល័យច្រកចេញចូលតែមួយ៖**




នេះគឺជាការធ្វើកំណែទម្រង់លើសេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលត្រូវបានកែប្រែការរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការបង្កើតអង្គភាពច្រកចេញចូលតែមួយ ដែលជាដៃជើងដ៏សំខាន់តែផ្តល់សេវារដ្ឋបាលជូលប្រជាពលរដ្ឋ។ ក្រៅពីការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏មានការិយាល័យជាច្រើនទៀតដែរ។

### ក.៥. គោលដៅធ្វើកំណែទម្រង់រចនាសម្ព័ន្ធ

កាលពីឆ្នាំ ២០១៥ ដល់ ២០១៨ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈដោយបាន ៖

- លើកកម្ពស់គុណភាពសេវាសាធារណៈ
- កែប្រែការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន
- ការកែទម្រង់ប្រព័ន្ធបៀវត្ស។

បន្ទាប់ពីបានធ្វើកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានរៀបចំជាគម្រោងក្នុងការធ្វើកំណែទម្រង់ទៅមុខទៀត ចាប់ពីឆ្នាំ ២០១៩ ដល់ ២០៣០ ដែលត្រូវបានបែងចែកជា បីដំណាក់កាលៈ

- ដំណាក់កាលទី ១ (២០២០-២០២៣)៖ ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ដំណាក់កាលទី ២ (២០២៣-២០២៧)៖ ការអនុវត្តនិងការវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ
- ដំណាក់កាលទី ៣ (២០២៧-២០៣០)៖ គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ

ក្នុងអត្ថបទនេះ ដំណាក់កាលទី១ (២០២០-២០២៣) នឹងត្រូវយកមកបកស្រាយ។

ដំណាក់កាលទី ១ (២០២០-២០២៣)៖ ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ មានចង្កោមសកម្មភាព ៣ដែលជាបណ្តុំនៃសកម្មភាពដែលត្រូវធ្វើដើម្បីសម្រេចបាននូវគោលដៅពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ក្នុងនោះមាន៖

**ចង្កោមសកម្មភាព១៖ការកែទម្រង់និងការលើកកម្ពស់សមត្ថភាពសាធារណៈ**

1.1. ការធ្វើវិចារណកម្មមុខងារ ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័នដោយពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់

1.2. ពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវ និងសាមគ្គីភាពផ្ទៃក្នុងស្ថាប័ន ការរៀបចំ និងអនុវត្តឬហត់ចត់នូវក្រមប្រតិបត្តិសម្រាប់បំពេញការងារ និងការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍល្អប្រសើរសម្រាប់ការតែងតាំងមុខតំណែងដឹកនាំក្នុងរដ្ឋបាលសាធារណៈ និងលើកកម្ពស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ

1.3. ការលើកកម្ពស់គុណាធិបតេយ្យក្នុងការជ្រើសរើស ការតែងតាំង ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការផ្តក់អត្ថប្រយោជន៍ផ្សេងទៀត

1.4. ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំលិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធការងារ ក្របខណ្ឌអភិវឌ្ឍមូលធនមនុស្សដែលទាក់ទាញសមត្ថភាពជំនាញនិងទេពកោសល្យ និងការជំរុញការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យសាធារណៈ

**ចង្កោមសកម្មភាព២៖ ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ**

2.1. ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីសេវាសាធារណៈលិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយជាតិ

2.2. ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវារួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រការអនុវត្ត

2.3. ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ចនិងសវនកម្មក្នុងវិស័យសាធារណៈ

2.4. ការពង្រឹងប្រសិទ្ធភាពរៀបចំ និងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមភាពមុខងារ និងទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ

**ចង្កោមសកម្មភាព៣៖ ការពង្រឹងប្រសិទ្ធភាពការងារនៃការអនុវត្តការងារ**

3.1. ការបន្តដំឡើងបៀវត្សជារៀងរាល់ឆ្នាំជូនមន្ត្រីរាជការ ព្រមទាំងប្រាក់សោធនជូននិវត្តជននិងអតីតយុទ្ធជន ដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារក្នុងរយៈពេល២សប្តាហ៍ម្តង

3.2. ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ

3.3. ការជំរុញនវានុវត្តន៍ និងរដ្ឋបាលឯកភាពក្នុងកម្រិតក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានី ដើម្បីធានាប្រសិទ្ធភាពទាំងក្នុងការបំពេញមុខងារ និងទាំងក្នុងការប្រើប្រាស់ធនធាន

3.4. ការដាក់អោយអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំនិងគ្រប់គ្រងស្ថាប័នសាធារណៈ

3.5. ការដាក់អោយអនុវត្តយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជំរុញការអនុវត្តកែលម្អវិធានការតម្រង់ទិសយុទ្ធសាស្ត្រ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួងសម្រាប់ការកសាង រៀបចំនិងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល

3.6. ការពង្រឹងយន្តការចែករំលែកនិងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងឆ្លើយតបទៅនឹងសេចក្តីត្រូវរបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងការវិវត្តន៍ឆាប់រហ័សនៃបរិការណ៍ជាតិ និងអន្តរជាតិ។

លើសពីនេះទៀតដើម្បីសម្រេចបាននូវការផ្តល់សេវារដ្ឋបាលឲ្យមានប្រសិទ្ធិភាព ស្អាតស្អំ ឆ្លាតវៃនោះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្ត្រ ៣គឺ ៖

១. ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ៖

- ជំរុញរៀបចំលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការបង្កើតសេដ្ឋកិច្ចឌីជីថល និងការអនុវត្តរដ្ឋបាលឌីជីថល
- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីទទួលយកយោបល់ត្រឡប់ នឹងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈពង្រឹងការចែករំលែកព័ត៌មាន
- ពង្រឹង និងពង្រីកការធ្វើបច្ចុប្បន្នភាពព័ត៌មានសេវាសាធារណៈ
- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងព័ត៌មានមន្ត្រីរាជការ
- ជម្រុញ និងលើកទឹកចិត្តឲ្យមានការច្នៃប្រឌិតក្នុងការផ្តល់សេវាសាធារណៈ

២. ការជំរុញនិងការរៀបចំដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

- បង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- រៀបចំ និងប្រើប្រាស់សូចនាករគោលសម្រាប់ការផ្តល់សេវាសាធារណៈ
- សាកល្បងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ

៣. ការផ្សារភ្ជាប់សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈជាមួយការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល

- កម្មវិធីថវិកា និងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- ការធ្វើប្រតិភូកម្មសិទ្ធិអំណាច និងការផ្ទេរមុខងារនិងធនធាន
- ការរួមបញ្ចូលសេវាសាធារណៈឲ្យមានលក្ខណៈជាប្រព័ន្ធ
- ការផ្សារភ្ជាប់សកម្មភាពកែទម្រង់ និងគោលនយោបាយ
- ការពង្រឹងយន្តការសម្របសម្រួលស្ថាប័ន
- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងការផ្លាស់ប្តូរ

## ខ. កំណែទម្រង់មនុស្ស

មុនពេលមានការធ្វើកំណែទម្រង់ និងមុននឹងមានការតាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សិទ្ធិអំណាចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌគឺស្ថិតនៅអភិបាលក្រុង ស្រុក ខណ្ឌ ដែលជាអ្នកសម្រេចទៅតាមឋានានុក្រម ហើយក្នុងអំឡុងពេលដែរអំណាចប្រមូលផ្តុំ នាំឲ្យការអនុវត្តការងារមិនមានភាពល្អប្រសើរឡើយដោយហេតុថា ការសម្រេចចិត្តគឺស្ថិតនៅលើបុគ្គលម្នាក់ មិនទទួលបានការចូលរួមបញ្ចេញមតិ ជាដើម ដោយហេតុនេះហើយទើប ក្រោយពេលមានការកែប្រែតាមទម្រង់វិមជ្ឈការ ការសម្រេចកិច្ចការវិមជ្ឈការនឹងត្រូវធ្វើឡើងតាមរយៈក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌជំនួសវិញ។

បន្ទាប់ពីមានការកែប្រែលើប្រព័ន្ធក្នុងការផ្តល់សេវា និងការងារមក ការកែប្រែនូវប្រព័ន្ធគ្រប់គ្រង អ្នកដឹកនាំក៏ត្រូវមានផងដែរ ដើម្បីតម្រូវទៅនឹងការធ្វើកំណែទម្រង់ថ្មី និងមានតម្លាភាព។

ក្រោយពីមានការធ្វើកំណែទម្រង់រដ្ឋបាលក្រុង ស្រុក ខណ្ឌ កំណែទម្រង់មនុស្សត្រូវបានកែប្រែដូចតទៅ៖

### ខ.១.ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតរៀងរាល់ ៥ឆ្នាំម្តង ដោយស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងមានចំនួនសមាជិកប្រែប្រួលពី ០៧ ទៅ ១៥រូប។ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាអង្គការដែលការពារ និងជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

#### ខ.១.១. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

មានសិទ្ធិអំណាច ២៖

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ តាមរយៈការដាក់ចេញដីកា
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកគោលការណ៍ បែបបទ និង នីតិវិធីដែលកំណត់ក្នុងច្បាប់នឹងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ប្រសិនបើមានករណីមិនបានចែងពីបែប បទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ក្រុមប្រឹក្សា អាចរៀបចំបែបបទនិងនីតិវិធី សមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័ត ដើម្បីដោះស្រាយកិច្ចការនេះ ឬ អាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីឬប្រធានស្ថាប័ន នានា ធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ។លើសពីនេះទៀតក្រុមប្រឹក្សាត្រូវធានា ថា រាល់សេចក្តីសម្រេចរបស់ខ្លួនត្រូវបានយកទៅអនុវត្ត។

**កិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមានពីរប្រភេទគឺ ៖

- កិច្ចប្រជុំសាមញ្ញ
- កិច្ចប្រជុំវិសាមញ្ញ

កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំប្រព្រឹត្តទៅត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ សេចក្តីសម្រេចណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម ប្រឹក្សា ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចពាក់ព័ន្ធទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធាន
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- ផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងៗ
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជន និងការផ្សព្វផ្សាយព័ត៌មាន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាន

### ខ.១.២. ប្រធានក្រុមប្រឹក្សា

ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រាស្រុកលើ៖

- ដីកា ឬសេចក្ដីសម្រេចដែលក្រុមប្រឹក្សាស្រុកបានអនុម័តរួច
- សេចក្ដីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាបានអនុម័ត
- សំណើដកហូតអភិបាល ឬអភិបាលរងស្រុកចេញពីមុខតំណែង តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាស្រុក
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាស្រុក
- ប្រតិទិនកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុកសម្រាប់រយៈពេល ១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សា
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា។

### ខ.១.៣. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

គណៈកម្មាធិការត្រូវបានបង្កើតដោយក្រុមប្រឹក្សា ដោយមានចំនួនបីគឺ៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស: គណៈកម្មាធិការនេះត្រូវបានរៀបចំឡើងដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារធនធាន ដែលបានប្រគល់ ឬបានផ្ទេរប្រតិភូកម្មឲ្យក្រុមប្រឹក្សាស្រុក។
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ: គណៈកម្មាធិការនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក អភិបាលស្រុក និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាស្រុក លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាស្រុក។
- គណៈកម្មាធិការលទ្ធកម្ម: គណៈកម្មាធិការនេះមានតួនាទីជ្រើសរើសអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ និងការចុះកិច្ចសន្យាច្បាស់លាស់មួយ អំពីការងារដែលពួកគេត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត តម្លៃ និងលក្ខខណ្ឌចាំបាច់ផ្សេងៗទៀត។

## ខ.២. គណៈអភិបាលក្រុង ស្រុក ខណ្ឌ

គណៈអភិបាលមានប្រធានមួយរូបគឺ អភិបាល និងអភិបាលរងមួយចំនួន។ គណៈអភិបាលមានតួនាទី ភារកិច្ចចម្បងដូចជាៈ

- គណៈអភិបាល ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានា ដែល ពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ។
- គណៈអភិបាលផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- នៅពេលទទួលបានរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាចគណៈអភិបាលស្រុកត្រូវធ្វើការ ស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាល ត្រូវធ្វើការរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាស្រុក និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**អភិបាលក្រុង ស្រុក ខណ្ឌ**

មានតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង ស្រុក ខណ្ឌ។ ដែលអភិបាលមានមុខការដូចជា៖

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ បង្កើនការយល់ដឹងផ្នែកច្បាប់របស់ ប្រជាពលរដ្ឋ ធានាឲ្យមានការគោរពច្បាប់ និងគោរពសិទ្ធិមនុស្សក្នុងសហគមន៍ផងដែរ។
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំ សម្របសម្រួល និងរក្សាសុវត្ថិភាពសណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈ។
- អភិបាលអាចទទួលបាននូវសិទ្ធិអំណាចមួយចំនួនក្នុងនាមជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធបើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើសំណើទៅនាយករដ្ឋមន្ត្រីដើម្បីធ្វើវិសហមជ្ឈការសិទ្ធិនោះ
- អភិបាលជាអ្នកតំណាងឲ្យរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌ ដែលអាចចុះកិច្ចសន្យាក្នុងនាមរដ្ឋក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌ និងតំណាងរដ្ឋនៅតុលាការ។
- អភិបាលទទួលបន្ទុកអនុវត្តច្បាប់ បទបញ្ជាក្នុងក្រុង ស្រុក ខណ្ឌ

- ណែនាំ និង សម្របសម្រួលតម្រង់ទិស ដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុកឲ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។
- ពិនិត្យវាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យអង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់។
- ផ្តល់យោបល់លើបេក្ខភាពស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅក្នុងស្រុក។ បើមិនគាំទ្រ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរពីមូលហេតុជូនអភិបាលខេត្តមុននឹងជូនទៅរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នសាមី។
- រាយការណ៍ទៅអភិបាលខេត្តពេលមានបញ្ហាមិនប្រក្រតី កើតមានក្នុងរិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅស្រុក។
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬ ប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័ន ដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តកម្មបាន។

**នាយករដ្ឋបាល**

នាយករដ្ឋបាលត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ តួនាទី ភារកិច្ចរបស់នាយករដ្ឋបាល មានដូចជា៖

- អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឲ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ
- ផ្តល់យោបល់ជូនក្រុមប្រឹក្សា ដល់គណៈកម្មធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើតការជម្រុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

- ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

នាយករដ្ឋបាលអាចទទួលបាននូវប្រតិភូកម្មការងារពីគណៈអភិបាលក្នុងកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពការងាររបស់គណៈអភិបាល

## ខ.៣. ទំនាក់ទំនងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ខ.៣.១. ទំនាក់ទំនងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ថ្នាក់ជាតិ

ដើម្បីយល់ពីការគ្រប់គ្រងទៅលើរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិដ៏ទៃឲ្យកាន់តែច្បាស់នោះ ការយល់ដឹងពីទំនាក់ទំនងដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានជាមួយរដ្ឋបាលថ្នាក់ជាតិក៏ជាកត្តាមួយសំខាន់ផងដែរ ព្រោះទំនាក់ទំនងនេះនឹងបង្ហាញថារដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីអ្វី។

ទំនាក់ទំនងរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖

- ក្រសួង ស្ថាប័នថ្នាក់ជាតិ៖
  - កំណត់អំពីស្តង់ដារជាតិសម្រាប់អនុវត្ត
  - ពិនិត្យនីត្យានុកូលភាពទៅលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
  - តាមដាន ត្រួតពិនិត្យ និងគាំទ្រ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
  - គោរពតាមស្តង់ដារជាតិ
  - មានគណនេយ្យភាពចំពោះថ្នាក់ជាតិ ក្នុងការអនុវត្តមុខងារដែរទទួលបានការផ្ទេរពីថ្នាក់ជាតិ។

### ខ.៣.២. ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាល

ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាលក្រុង ស្រុក មានដូចខាងក្រោម ៖

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុក ក្រុងបានសម្រេចរួច ហើយគណៈអភិបាលស្រុក ក្រុងត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួន។ ដូច្នេះ គណៈអភិបាលស្រុក ក្រុង គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តី សម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក ក្រុង

- ក្រុមប្រឹក្សាស្រុក ក្រុងត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការ ដែលអនុវត្តដោយគណៈអភិបាលស្រុក ក្រុង ដើម្បីធានាថា គណៈអភិបាលស្រុក ក្រុងអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវ តាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក ក្រុង
- គណៈអភិបាលស្រុក ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក ក្រុង
- គណៈអភិបាលស្រុក ក្រុង ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក ក្រុង និង មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការអនុវត្តតាមរដ្ឋ-ធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា
- អភិបាលស្រុក ក្រុងដោយមាននាយករដ្ឋបាលសាលាស្រុក ក្រុងជាជំនួយការ ត្រូវរៀបចំសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការ អនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ន នានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ ប្រចាំខែ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូន ក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួន
- ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុក ក្រុង ក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក ក្រុងអាចតម្រូវឱ្យអភិបាលស្រុក ក្រុងធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ក្រុង
- ក្រុមប្រឹក្សាស្រុក ក្រុងអាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលស្រុក ក្រុងអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលស្រុក ក្រុងត្រូវ ទទួលយកអនុសាសន៍ និងការណែនាំនានាពីក្រុមប្រឹក្សាស្រុក ក្រុងរបស់ ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់ការិយា ល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង-ស្ថាប័នដែលប្រចាំ នៅស្រុក ក្រុង ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ ជូនក្រុមប្រឹក្សាស្រុក ក្រុងរបស់ខ្លួនវិញ។

ក្រៅពីទំនាក់ទំនងនានាដូចបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក ក្រុង និងគណៈអភិបាលស្រុក ក្រុង ក៏បានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក ក្រុង គណៈអភិបាលស្រុក ក្រុងផងដែរ។

# ជំពូកទី ២
# កំណែទម្រង់ហិរញ្ញវត្ថុ

ទន្ទឹមនឹងការធ្វើកំណែទម្រង់លើប្រព័ន្ធគ្រប់គ្រង និងការផ្តល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការធ្វើកំណែទម្រង់ហិរញ្ញវត្ថុជាកត្តាមួយដ៏សំខាន់ផងដែរសម្រាប់ធ្វើឲ្យការអភិវឌ្ឍអាចដំណើរការទៅបានរលូន។ ក្នុងការធ្វើកំណែទម្រង់ហិរញ្ញវត្ថុនេះផងដែរ ត្រូវបានបែងចែកជាពីរ ដែលមាន ថវិការកម្មវិធី និងប្រតិបត្តិការចំណូលចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## គ. ថវិកាកម្មវិធី

### គ.១. អ្វីទៅជាថវិកាកម្មវិធី

នៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានដាក់អនុវត្តជាផ្លូវការក្នុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលសម្រេចបាននូវជំហានទី ១ គឺ «ភាពជឿទុកចិត្តបាននៃថវិកា» និង ជំហានទី ២គឺ « គណនេយ្យភាពហិរញ្ញវត្ថុ»។ បន្ទាប់មក «ថវិកាកម្មវិធី» ត្រូវបានចាប់ផ្តើមសាកល្បងអនុវត្តដោយរាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវ ជំហានទី ៣ គឺ «ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ» និង ក្នុងឆ្នាំ២០២១ ដល់ ២០២៥ រាជរដ្ឋាភិបាលគ្រោងនឹងអនុវត្តជំហានទី ៤គឺ «គណនេយ្យភាពសមិទ្ធកម្ម»។ តែក្នុងនេះ ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ ដែលជាជំហានទី ៣ នឹងត្រូវលើកមកនិយាយ។

ថវិកាកម្មវិធីជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ថវិកាកម្មវិធី គឺជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់នូវធាតុចូលជាចំណាយចរន្ត និងចំណាយមូលធន សម្រាប់អនុវត្តចង្កោមសកម្មភាព ដើម្បីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួង និងត្រូវមានសូចនាករ សមិទ្ធកម្មសម្រាប់យន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមកម្មវិធីនីមួយៗ។ បើយោងតាមគេហទំព័រ Wikipedia ថវិកាកម្មវិធី [3] គឺជាកញ្ចប់ថវិកា ឬគម្រោងថវិកាដែលត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់ក្នុងគម្រោងណាមួយជាក់លាក់។

[3] https://en.m.wikipedia.org/wiki/Programme-budgeting

## គ.២. ដំណើរការរៀបចំថវិកាកម្មវិធី

ដំណើរការរៀបចំថវិកាកម្មវិធីមាន៖

1. ការកំណត់គោលបំណងគោលនយោបាយ៖

ដើម្បីកំណត់គោលបំណងគោលនយោបាយបានសមស្របត្រូវផ្អែកលើ៖

- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- គោលនយោបាយតាមវិស័យ
- អាណត្តិកិច្ច/តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័ន។

ជាឧទាហរណ៍ក្នុងប្រទេសកម្ពុជា គោលបំណងគោលនយោបាយមាន៖

- បង្កើនទំនុកចិត្តទៅលើវិធានច្បាប់
- កែលម្អដំណើរការតុលាការ
- លើកកម្ពស់ការយល់ដឹងអំពីច្បាប់ថ្មី
- បន្តពង្រឹង និងកែលម្អការគ្រប់គ្រងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

2. ការបង្កើតរចនាសម្ព័ន្ធកម្មវិធី

រចនាសម្ព័ន្ធកម្មវិធី៖



1) កម្មវិធី

កម្មវិធី គឺជាបណ្តុំនៃអនុកម្មវិធី/វិធីសាស្ត្រក្នុងការអនុវត្តដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយ។

កម្មវិធីមានលក្ខណៈសម្បត្តិដូចជា៖

- ត្រូវមានឈ្មោះ អត្ថន័យ និងគោលបំណងច្បាស់លាស់
- ត្រូវគ្របដណ្តប់គ្រប់មុខងារទាំងអស់របស់ក្រសួង-ស្ថាប័ន
- គួរមានច្រើនបំផុតចំនួន ៥
- ត្រូវមានលក្ខណៈងាយយល់សម្រាប់ទាំងមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន និងទាំងប្រជាពលរដ្ឋ
- ត្រូវពណ៌នាអំពីសកម្មភាពជាក់លាក់ក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន
- ត្រូវមានសូចនាករលទ្ធផលចុងក្រោយយ៉ាងតិចចំនួន ១ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន។

2) អនុកម្មវិធី

អនុកម្មវិធី គឺជាបណ្តុំនៃសកម្មភាព/វិធីសាស្ត្រក្នុងការអនុវត្តដើម្បីសម្រេចបាននូវគោលបំណងកម្មវិធី។

អនុកម្មវិធីមានលក្ខណៈសម្បត្តិដូចជា៖

- ត្រូវមានឈ្មោះ អត្ថន័យ និងគោលបំណងច្បាស់លាស់
- ត្រូវមានលក្ខណៈងាយយល់សម្រាប់ទាំងមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន និងទាំងប្រជាពលរដ្ឋ
- ត្រូវពណ៌នាអំពីសកម្មភាពជាក់លាក់ក្នុងការសម្រេចបាននូវកម្មវិធី
- គួរមានសូចនាករលទ្ធផលក្នុងឆ្នាំមួយ ឬច្រើនដើម្បីគាំទ្រក្នុងការសម្រេច បាននូវគោលបំណងនៃកម្មវិធីមួយ។

3) សកម្មភាព

សកម្មភាព គឺជាវិធីសាស្ត្រ ឬ បណ្តុំវិធីសាស្ត្រ ដែលត្រូវបានកំណត់ដោយក្រសួងដើម្បីសម្រេចបាននូវគោលបំណងរបស់អនុកម្មវិធី។

3. ការកំណត់សូចនាករ

សូចនាករ គឺជារង្វាស់លើលទ្ធផលដែលសម្រេចបាន។ សូចនាករ អាចជាបរិមាណ ឬជាគុណភាព។

សូចនាករមាន៖

- សូចនាករលទ្ធផលចុងក្រោយ ជារង្វាស់ភាពសក្តិសិទ្ធិនៃលទ្ធផលចុងក្រោយ ដោយផ្អែកលើ មូលដ្ឋាននៃលទ្ធផលក្នុងឆ្នាំដែលសម្រេចបាន។ សូចនាករនេះអាចវាស់លទ្ធផលដែលសម្រេចបានរបស់កម្មវិធី ដែលជាទូទៅសូចនាករនេះត្រូវបានបញ្ជាក់ជាភាគរយ អនុបាត ហើយវាស់វែងលទ្ធ-ផល ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងតែមួយ។
- សូចនាករលទ្ធផលក្នុងឆ្នាំ ជារង្វាស់លទ្ធផលក្នុងឆ្នាំ លើការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី ឬកម្មវិធី ធៀបនឹងគោលដៅដែលបានកំណត់ដើម្បីបញ្ជាក់ពីប្រសិទ្ធភាពថវិកា។ សូចនាករនេះជាឧបករណ៍សម្រាប់ការវាស់វែងសេវាកម្ម ឬទំនិញ ដែលត្រូវបានបង្កើតឡើងដោយក្រសួង-ស្ថាប័នតាមដានសមិទ្ធកម្មការងាររបស់ក្រសួង-ស្ថាប័ន និងបញ្ជាក់ជាចំនួននៃសេវាកម្ម ដែលបានអនុវត្ត ឬ ប្រគល់ជូន។

លក្ខណៈវិនិច្ឆ័យសូចនាករសមិទ្ធកម្ម៖

- ផ្តោតលើលទ្ធផល
- អាចវាស់វែងបាន
- មានន័យច្បាស់លាស់និងអាចយល់បាន
- អាចទុកចិត្តបាន
- សាមញ្ញ
- ត្រឹមត្រូវ
- អាចផ្ទៀងផ្ទាត់បាន

4. ការគណនាតម្រូវការចំណាយ

ការគណនាថ្លៃចំណាយ គឺជាការប៉ាន់ប្រមាណនូវចំនួនទឹកប្រាក់ដែលត្រូវការដើម្បីទូទាត់ទៅលើសេវាកម្ម ឬទំនិញ។ការគណនាចំណាយត្រូវតែធ្វើឡើងក្នុងគោលបំណងប្រៀបធៀបលទ្ធផលកម្មវិធីដែលរំពឹងទុកទៅនឹងចំណាយលើការបង្កើតលទ្ធផលកម្មវិធី ដែលធ្វើឲ្យសមត្ថភាពកាន់តែប្រសើរសម្រាប់អ្នកសម្រេចចិត្តក្នុងការវិភាជន៍ថវិកាដល់កម្មវិធីឲ្យមានប្រសិទ្ធភាពបំផុត និងធ្វើឲ្យមានឥទ្ធិពលលើការសម្រេចជ្រើសរើសយុទ្ធសា-ស្ត្រផ្សេង ដោយធ្វើការប្រៀបធៀបថ្លៃចំណាយ និងលទ្ធផលកម្មវិធី។

ថ្លៃចំណាយអាចចែកជាពីរប្រភេទគឺថ្លៃចំណាយផ្ទាល់ និងចំណាយប្រយោល។

➢ ចំណាយផ្ទាល់ គឺថ្លៃចំណាយ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅលើសេវាកម្ម ឬទំនិញរបស់កម្មវិធី។ ម៉្យាងទៀតចំណាយផ្ទាល់ពាក់ព័ន្ធនឹងការបង្កើតលទ្ធផលក្នុងឆ្នាំ។ ចំណាយផ្ទាល់ត្រូវគណនាតាមវិធីពីរគឺ៖

- ការកំណត់ថ្លៃចំណាយផ្ទាល់ដោយផ្អែកលើការចំណាយពីមុនៈ ព័ត៌មាននៃការចំណាយពីមុនជាមូលដ្ឋានការគណនាថ្លៃចំណាយរបស់កម្មវិធីនាពេលអនាគត ដោយការចំណាយនាពេលអនាគតត្រូវគិតគូពីផលប៉ះពាល់ដូចជា៖
    - អតិផរណា ឬបរិត្តផរណា៖ ការកើនឡើងនៃតម្លៃទូទៅ ដែលនាំឲ្យចំណាយប្រែប្រួល
    - ការផ្លាស់ប្តូរតម្រូវការសម្រាប់កម្មវិធី៖ ការប្រែប្រួលនៃតម្រូវការ ដែលនាំឲ្យការចំណាយកើនឡើង
    - ការផ្លាស់ប្តូរគោលនយោបាយ៖ ការអនុវត្តកម្មវិធីនឹងប៉ះពាល់ នៅពេលមានការកែប្រែគោលនយោបាយ
- ការកំណត់ថ្លៃចំណាយផ្ទាល់ដោយមិនមានការចំណាយពីមុនៈ ដើម្បីកំណត់ថ្លៃចំណាយដែលមិនមានការចំណាយពីមុនគួរពិចារណាអំពីកត្តាមួយចំនួនដូចជា៖
    - តម្រូវឲ្យមានការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង
    - កម្មវិធីស្រដៀងគ្នាអាចយកមកធ្វើជាមូលដ្ឋានសម្រាប់គណនាថ្លៃចំណាយ

នៅក្នុងការកំណត់ថ្លៃចំណាយនេះផងដែរគេត្រូវសិក្សាពីចំណុចសំខាន់ដែលជះឥទ្ធិពលក្នុងការចំណាយរបស់កម្មវិធីផងដែរគឺ កត្តាជម្រុញថ្លៃចំណាយ ដែលសំដៅទៅលើកត្តាដែលនាំឲ្យថ្លៃចំណាយកម្មវិធីប្រែប្រួល។ កត្តាជម្រុញថ្លៃចំណាយមាន ៥ប្រភេទសំខាន់ៗដូចជា៖

- ការប្រែប្រួលប្រជាសាស្ត្រ៖
  - ចំនួនសិស្សកំណត់តម្រូវការផ្នែកអប់រំ
  - ចំនួនមនុស្សចាស់កំណត់តម្រូវការលើការចំណាយថ្លៃវេជ្ជសាស្ត្រ និងចំណាយសោធននិវត្តន៍
- ការប្រែប្រួលសង្គមនិងសេដ្ឋកិច្ច
  - អត្រាលែងលះធ្វើឲ្យប៉ះពាល់ដល់តម្រូវការថែទាំកុមារ និងមនុស្សចាស់
  - អត្រាប្រើប្រាស់គ្រឿងញៀនធ្វើឲ្យប៉ះពាល់ដល់តម្រូវការសេវាវេជ្ជសាស្ត្រ និងនគរបាល
  - ការធ្លាក់ចុះសេដ្ឋកិច្ចជាសកលបង្កើតតម្រូវការបណ្តុះបណ្តាលការងារ
- ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល
  - ការផ្លាស់ប្តូរសិទ្ធិទទួលបានអត្ថប្រយោជន៍សង្គមធ្វើឲ្យប៉ះពាល់បន្ទុកការងារវិស័យសាធារណៈ
  - ការផ្លាស់ប្តូរពូជស្រូវថ្មីសម្រាប់ផ្តល់ជូនកសិករ ដើម្បីបង្កើនទិន្នផល នាំឲ្យតម្រូវការចំណាយលើពូជស្រូវថ្មីកើនឡើង
- ការរីកចម្រើនផ្នែកបច្ចេកវិទ្យា
  - ឱសថ ឬបច្ចេកទេសវេជ្ជសាស្ត្រថ្មីៗអាចកាត់បន្ថយថ្លៃចំណាយលើការថែទាំវេជ្ជសាស្ត្រ
  - ការផ្តល់ព័ត៌មានតាមរយៈប្រព័ន្ធអ៊ីនធឺណិតកាត់បន្ថយថ្លៃចំណាយលើការបោះពុម្ព និងការមកទទួលព័ត៌មាននៅការិយាល័យរបស់សាធារណៈជន
- បរិយាកាសខាងក្រៅ
  - ស្តង់ដារថ្មីដែលបានដាក់តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិដូចជា៖
    - អង្គការពាណិជ្ជកម្មពិភពលោក
    - ពិធីសារក្រុងក្យូតូអំពីបម្រែបម្រួលអាកាសធាតុ
    - គណៈកម្មាធិការទន្លេមេគង្គ
  - ការជូនដំណឹងអំពីជម្ងឺឆ្លងផ្សេងៗ
  - ការផ្លាស់ប្តូរស្ថានភាពនយោបាយរបស់ប្រទេសជិតខាង។

លើសពីនេះទៅទៀតកត្តាជម្រុញថ្លៃចំណាយក៏អាចជាកាតព្វកិច្ច និងជាកត្តាដែលមិនតម្រូវឲ្យមានការឆ្លើយតបពីក្រសួងឡើយ

- កត្តាជម្រុញថ្លៃចំណាយជាកាតព្វកិច្ច
  - សិទ្ធិស្របច្បាប់ក្នុងការទទួលបានសេវាដូចជា ការអប់រំ
  - ចំណាយលើការសងបំណុល
  - សិទ្ធិស្របច្បាប់ក្នុងការទទួលបានសេវាដូចជា ការអប់រំ
  - ចំណាយលើការសងបំណុល
- កត្តាជម្រុញផ្សេងទៀតដែលមិនតម្រូវឲ្យមានការឆ្លើយតបពីក្រសួងឡើយ
  - កំណើនចំនួនអ្នកជាប់ពន្ធ (មិនតម្រូវឲ្យមានកំណើនចំនួនចុះអនុវត្តសវនកម្មពន្ធឡើយ)
  - កំណើនចំនួនទេសចរ (មិនតម្រូវឲ្យក្រសួងទេសចរណ៍ត្រូវតែបង្កើនការផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរណ៍)

ក្នុងការគណនាថ្លៃចំណាយគេធ្វើតាម៖

ថ្លៃចំណាយមួយឯកតា ✖ កត្តាជម្រុញថ្លៃចំណាយ 〓 ថ្លៃចំណាយ

ដែលថ្លៃចំណាយមួយឯកតាអាចឡើង ឬចុះអាស្រ័យលើអនុបាតធាតុចូលធៀបនឹងលទ្ធផលក្នុងឆ្នាំ ហើយកត្តាជម្រុញថ្លៃចំណាយ ត្រូវបានប៉ាន់ស្មានលើបម្រែបម្រួលកត្តាជម្រុញ ថ្លៃចំណាយ និងអតិផរ-ណា។

➢ ចំណាយប្រយោល គឺជាចំណាយទូទៅដែលមិនពាក់ព័ន្ធដោយផ្ទាល់ ទៅនឹងកម្មវិធី។ លើសពីនេះទៅទៀតថ្លៃចំណាយប្រយោលអាចគាំទ្រដល់កម្មវិធីជាច្រើន។

ចំណាយប្រយោលត្រូវបានធ្វើវិភាជដើម្បីកំណត់ពីថ្លៃចំណាយកម្មវិធីពិតប្រាកដ តាមតយៈវិធីសាស្ត្រដូចជា៖

- វិធីសាស្ត្រ ពីលើចុះក្រោម ដែលសាមញ្ញ ដោយប្រើប្រាស់ការវិនិច្ឆ័យដោយនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធានកម្មវិធីក្នុងការបែងចែកថ្លៃចំណាយសម្រាប់កម្មវិធី
- វិធីសាស្ត្រ ពីក្រោមឡើងលើ ដែលអាចស្មុគស្មាញ ដោយការវិភាគលម្អិតពិការប្រើប្រាស់ពេលវេលា និងសម្ភារៈសម្រាប់បុគ្គលិកនៅក្នុងកម្មវិធីនីមួយៗ។

5. ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

បន្ទាប់ពីការអនុម័តថវិកាប្រចាំឆ្នាំរួច ចាំបាច់ត្រូវការតាមដានការអនុវត្តលើចំនួនថវិកាអនុម័តដែលកំពុងចំណាយថាតើលទ្ធផលក្នុងឆ្នាំគ្រោងទុកទទួលបានដូចការរំពឹងទុកដែរឬទេ និងដើម្បីឆ្លុះបញ្ចាំងដល់ថ្នាក់ដឹកនាំថាមានបញ្ហាក្នុងការអនុវត្តថវិកាដែរឬទេ។ ដើម្បីតាមដានលើការអនុវត្តថវិកានេះ ត្រូវមានឧបករណ៍បីដូចជា៖

- ការតាមដាន គឺជាការត្រួតពិនិត្យឡើងវិញ ជាប្រចាំ ឬតាមពេលកំណត់លើការអនុវត្តកម្មវិធី។

  ការតាមដានត្រូវបានធ្វើឡើងដើម្បី៖

  - វាយតម្លៃការអនុវត្តកម្មវិធី
  - កំណត់បញ្ហា
  - ប្រមូលផ្តុំឯកសារអំពីលទ្ធផលសម្រេចបាន
  - ផ្តល់អនុសាសន៍នូវវិធានការដោះស្រាយពេលអនាគត

  គុណសម្បត្តិនៃ ប្រព័ន្ធតាមដាន និងវាយតម្លៃល្អ៖

    - ជម្រុញឲ្យមានការរៀបចំផែនការកម្មវិធី
    - លើកកម្ពស់ឲ្យមានការសម្របសម្រួល និងទំនាក់ទំនង
    - កំណត់នូវការទទួលខុសត្រូវច្បាស់លាស់
    - បង្កលក្ខណៈងាយស្រួលដល់ការកំណត់ និងដោះស្រាយបញ្ហា
    - លើកកម្ពស់សមិទ្ធកម្ម និងគណនេយ្យភាពថវិកា
    - ធានាឲ្យមានការអនុវត្តតាមគោលនយោបាយ និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល

- ការធ្វើរបាយការណ៍ គឺជាការរាយការណ៍ព័ត៌មាន ឬទិន្នន័យអំពីការអនុវត្តថវិកា ដើម្បីដាក់ជូនទៅស្ថាប័នគ្រប់គ្រង។

  ការធ្វើរបាយការណ៍ត្រូវធ្វើតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី

  - ការអនុវត្តហិរញ្ញវត្ថុ
  - វឌ្ឍនភាពសូចនាករលទ្ធផលចុងក្រោយនិងលទ្ធផលក្នុងឆ្នាំ។ ហើយប្រព័ន្ធតាមដាននិងធ្វើរបាយការណ៍គួរមាន៖

      - ចំណាយ៖ ប្រតិបត្តិការ និង មូលធន

- ចំណូល៖ ក្នុងស្រុក និង ប្រភពក្រៅប្រទេស
- សមិទ្ធកម្ម
- ការបង្ហាញ និងការប្រតិបត្តិ ចំពោះការកែតម្រូវថវិកា

សមាសធាតុនៃប្រព័ន្ធតាមដាន និងវាយតម្លៃមានដូចជា៖

- ផែនការសមិទ្ធកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ
  - ផែនការចំណាយ និងចំណូលប្រចាំខែ និងប្រចាំត្រីមាស
    - ដោយផ្អែកលើថវិកាដែលបានអនុម័ត
    - ស្របតាមផែនការគ្រប់គ្រងសាច់ប្រាក់
    - រៀបចំនៅកម្រិតកម្ម-នាយកដ្ឋាន
- របាយការណ៍ប្រចាំឆមាស លើគោលដៅលទ្ធផលក្នុងឆ្នាំដែលសម្រេចបាន
- របាយការណ៍ប្រចាំឆ្នាំ លើគោលដៅលទ្ធផលចុងក្រោយដែលសម្រេចបាន

- ការវាយតម្លៃ គឺជាការប្រៀបធៀបលទ្ធផលនៃការអនុវត្ត កម្មវិធីទៅនឹងការគ្រោងទុក។

ដំណើរការ ឬសកម្មភាពវាយតម្លៃភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពកម្មវិធី ធៀបនឹងគោលបំណងជាក់លាក់។ ការវាយតម្លៃមានលក្ខណៈ៖

- មានរយៈពេលវែង និងលក្ខណៈជាយុទ្ធសាស្ត្រ
- ផ្តោតលើលទ្ធផលចុងក្រោយ
- មានមុខងារស្មុលនៃការវិភាគថវិកា
  - ពិនិត្យមើលទិន្នន័យ
  - ឧបករណ៍វិភាគ
  - មូលដ្ឋាននៃការវិភាជធនធាន
- ឲ្យដឹងពីការបង្កើត និងការរៀបចំផែនការថវិកានាពេលអនាគត។

ទាំងអស់នេះគឺជាដំណើរការរបស់ថវិកាកម្មវិធីដែលជាវិធីសាស្ត្រក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីសម្របទៅនឹងការកែប្រែរដ្ឋបាល និងសម្រេចនូវគោលដៅអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ឃ. ប្រតិបត្តិការចំណូលចំណាយ

ការធ្វើចំណូលចំណាយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ជាចំណុចដ៏សំខាន់មួយដែលត្រូវធ្វើការកែប្រែដើម្បីឲ្យសមស្របនឹងកម្មវិធីកំណែទម្រង់ដែលបានធ្វើការកែប្រែទៅលើរដ្ឋបាល ហើយ ប្រតិបត្តិការចំណូលចំណាយនេះក៏បញ្ជាក់ពីសកម្មភាពដែលរដ្ឋបាលបានធ្វើផងដែរ។

### ឃ.១. ប្រភពចំណូលរដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌមានប្រភពចំណូលដូចជា៖

- ចំណូលផ្ទាល់
- ចំណូលបានមកពីការផ្ទេរពីថវិកាជាតិក្នុងក្របខណ្ឌនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចំណូលផ្សេងៗទៀត។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភពថវិកាស្ទើរតែទាំងស្រុងទទួលបានមកពីការផ្ទេរថវិកាពីថ្នាក់ជាតិតាមរយៈ មូលនិធិក្រុង ស្រុក ដែលជាចំណូលដែលរាជរដ្ឋាភិបាលបានផ្តល់ឲ្យដើម្បីប្រើប្រាស់សម្រាប់ចំណាយ និងអភិវឌ្ឍក្នុងមូលដ្ឋាន។

ដោយសារតែចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានកម្រិតដែលមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចំណាយដើម្បីអភិវឌ្ឍ និងដើម្បីបង្កើនធនធានហិរញ្ញវត្ថុជូនរដ្ឋបាលនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំបង្កើនកញ្ចប់ថវិកាបន្ថែមចំនួន ០.១% ប្រចាំឆ្នាំជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ហេតុនេះដោយសារតែកាលពីឆ្នាំ ២០១៩ រដ្ឋបាលនេះមានកញ្ចប់ថវិកាចំនួន ១.១% នោះ បន្ទាប់មកទៀតនាំឲ្យកញ្ចប់ថវិកា ស្មើនឹង ១.២% (ឆ្នាំ ២០២០) ១.៣% (ឆ្នាំ ២០២១) ១.៤% (ឆ្នាំ ២០២២) ១.៥% (ឆ្នាំ ២០២៣) នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំមុន។

ប្រភពចំណូលមួលទៀតគឺ ចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានីខេត្ត។ ប្រភពចំណូលនេះរដ្ឋ-បាលក្រុង ស្រុក ទើបតែទទួលបានតាមរយៈការចេញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានបង្កើននូវប្រភពធនធានហិរញ្ញវត្ថុដល់រដ្ឋបាលនេះ ដោយបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឲ្យរដ្ឋបាលក្រុង ស្រុក ចំនួន ៣% សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចប្រគល់ចំណូលពីពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អភិវឌ្ឍមូលដ្ឋាន។

## ឃ.២. គំណែនទម្រង់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ឃ.២.១. ការរៀបចំ និងការអនុម័តថវិកា

1. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ

ការរៀបចំផែនការយុទ្ធសាស្ត្រនេះ មិនមែនជាកិច្ចការរបស់រដ្ឋបាលក្រុង ស្រុក ទេ តែរដ្ឋបាលក្រុង ស្រុកក៏រួមចំណែកក្នុងផែនការនេះនៅក្នុងគោលដៅឆ្នាំ២០២៥ ពេលដែលផែនការនេះក្លាយជាផែនការយុទ្ធសាស្ត្រថវិការួម ហៅថា « ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត» ដែលជាដំណើរផ្សារភ្ជាប់គ្នារវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឲ្យបាននូវសមិទ្ធផលជាអតិបរមា នោះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការសម្រាប់ធ្វើអន្តរាគមន៍របស់ខ្លួនដោយផ្តោតជាសំខាន់លើវិស័យអាទិភាពនៅមូលដ្ឋាន ដើម្បីគាំទ្រដល់ អាទិភាពគោលនយោបាយរដ្ឋបាលរាជធានី ខេត្ត ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យ និងអាទិភាពជាតិ។

2. ការរៀបចំថវិកាប្រចាំឆ្នាំ

បច្ចុប្បន្ន ការរៀបចំថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំផ្អែកតាមប្រភពថវិកាដែលរៀបចំផ្ទេរពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការព្យាករនូវលទ្ធភាពចំណូលសរុបរបស់រដ្ឋបាលនីមួយៗ ដោយគម្រោងថវិការបស់រដ្ឋបាលក្រុង ត្រូវបូកបញ្ចូលគម្រោងថវិការដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង។

នៅក្នុងឆ្នាំ ២០២៥ រាជរដ្ឋាភិបាលមានគោលបំណងពង្រឹងគ្រប់ជ្រុងជ្រោយនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗ តាមរយៈការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ដើម្បីសម្រេចបានគោលបំណងនេះ ផែនការថវិការប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការសម្របសម្រួលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដើម្បីឲ្យផែនការថវិការមានការផ្សារភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ/កម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

3. ការចរចាថវិកា និងការអនុម័តថវិកា

គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សា រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុប មុននឹងបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុប មុនបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យនិងផ្តល់អនុលោមភាព។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលជាផ្នែកមួយនៃថវិកាជាតិ។ ចំណែកឯការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត មានដំណើរការនិងផ្អែកលើការផ្សារភ្ជាប់ផ្សេងៗគ្នា ដែលផែនការរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាសាមី រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គម្រោងថវិកានេះត្រូវបានរៀបចំដើម្បីឲ្យសមស្របនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិដែលក្លាយជាផែនការរួមរបស់រាជធានីខេត្ត ហើយគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុកនេះត្រូវបានសម្របសម្រួលដោយរដ្ឋបាលរាជធានី ខេត្ត ដើម្បីធានាបាននូវ សង្គតិភាព និងប្រសិទ្ធិភាពនៃការអនុវត្តថវិកា។

ការចរចាថវិកា នឹងត្រូវធ្វើការពង្រឹង និងតម្រង់ទិសក្នុងការចរចារថវិកាផ្តោតលើគោលនយោបាយ និងវិស័យអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដោយមានការបង្កើតយន្តការសម្របសម្រួលមួយ និងមានគោលការណ៍ណែនាំស្តីពីការចរចារថវិកាថ្នាក់ក្រោមជាតិ ដើម្បីទុកជាមូលដ្ឋានសម្រាប់ចរចារថវិកាប្រចាំឆ្នាំ។

ដោយសាររដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំផែនការលទ្ធកម្មដោយផ្អែកតាមផែនការអភិវឌ្ឍ៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល តួលេខកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន ហើយត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការអនុម័តជាផ្លូវការឲ្យបានមុនឆ្នាំអនុវត្តថវិកា។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវផ្ញើរបាយ-ការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នោះសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវដាក់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងពេលដំណាលគ្នានឹងផែនការថវិកា ដែលត្រូវដាក់ជូនអភិបាលរាជធានីខេត្ត ដើម្បីផ្តល់អនុលោមភាព។

### ឃ.២.២. ការអនុវត្តនិងការត្រួតពិនិត្យថវិកា

1) សិទ្ធិអំណាចនៃការបញ្ជាចំណាយ

ក្នុងការអនុវត្តជាក់ស្តែងបច្ចុប្បន្នរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់មានឆន្ទានុសិទ្ធិពេញលេញគ្រប់គ្រាន់ក្នុងការអនុវត្ត និងត្រួតពិនិត្យថវិកានៅឡើយទេ ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ តម្រូវឲ្យមានការត្រួតពិនិត្យចំណាយដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវការការស្នើសុំធានាចំណាយពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទេ តែតម្រូវឲ្យមានការត្រួតពិនិត្យថវិកាពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុននឹងធ្វើការទូទាត់។ ក្នុងករណីត្រូវការប្រើប្រាស់ថវិកា រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈប្រចាំបន្ទាន់ ដែលមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ បើអាចធ្វើតាមនីតិវិធីធម្មតា ឬមិនមានប្រតិបត្តិការមិនប្រក្រតីទេ ត្រូវអនុវត្តចំណាយតាមនីតិវិធីនៃការផ្តល់ធានាចំណាយ និងនីតិវិធីលទ្ធកម្មសាធារណៈ។

ចំពោះយន្តការគ្រប់គ្រងនិងនីតិវិធីអនុវត្តនៃការបញ្ជាចំណាយសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យ ផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានីខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ ត្រួតពិនិត្យ និងទូទាត់ចំណាយថវិកា។

ក្នុងឆ្នាំ ២០២៥ រាជរដ្ឋាភិបាលមានគម្រោងធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់អ្នកគ្រប់គ្រងផ្ទាល់ក្នុងការចាត់ចែងធនធានឲ្យបានល្អ ដើម្បីសម្រេចសមិទ្ធផលល្អ តែការផ្តល់ការអនុញ្ញាតនោះអនុញ្ញាតឲ្យបញ្ជាចំណាយពេលមួយឆ្នាំ លើកលែងមុខចំណាយមួយចំនួនដែលមានទំហំធំ និង/ ឬមានវេទ  យិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការអនុញ្ញាតនឹងធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាស/ ឆមាស ស្របតាមគោលការណ៍កំណត់ដោយធ្វើការបែងចែកធនធានទៅតាមកម្មវិធី អង្គភាពថវិកាមុខចំណាយ និងពេលវេលា។ ម្យ៉ាងទៀតនីតិវិធីនៃការអនុវត្តថវិកានឹងត្រូវបានធ្វើទំនើបកម្ម និងពន្លឿនថែមទៀត តាមរយៈការលើកកម្ពស់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

2) ការត្រួតពិនិត្យការអនុវត្តថវិកា

ការត្រួតពិនិត្យចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមយន្តការ មជ្ឈការទាំងក្នុងដំណាក់កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់។

តែក្នុងពេលខាងមុខក្នុងឆ្នាំ ២០២៥ រាជរដ្ឋាភិបាលនឹងពន្លឿន និងធ្វើឲ្យការអនុវត្តថវិកាមានភាពសាមញ្ញ ដោយប្រគល់សិទ្ធិ អំណាចជាអតិបរមាតាមការវិវត្តនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ហើយដើម្បីឲ្យយន្តការត្រួតពិនិត្យមានលក្ខណៈកាន់តែមានប្រសិទ្ធិភាព និងការទទួលខុសត្រូវច្បាស់លាស់ គណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្ត នឹងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) និង E-Transfer និងកាត់បន្ថយការត្រួតពិនិត្យមកនៅត្រឹមកម្រិតអប្បបរមា។ ចំពោះថវិការដ្ឋបាលក្រុង ស្រុក ការត្រួតពិនិត្យត្រូវធ្វើតាមរតនគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ។ លើសពីនេះគណនេយ្យករសាធារណៈនេះអាចនឹងដាក់ឲ្យនៅអមរដ្ឋបាលក្រុង ស្រុក តែម្តងដើម្បីពន្លឿន និងសម្រួលដល់ការអនុវត្តថវិកា។

3) កិច្ចលទ្ធកម្ម

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនទាន់ទទួលការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវចំពោះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅឡើយទេ ដោយការត្រួតពិនិត្យកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានត្រួតពិនិត្យដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ដើម្បីឈានដល់ការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញ ការប្រគល់សិទ្ធិនឹងត្រូវធ្វើបណ្តើរៗ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច លើកលែងមុខចំណាយមួយចំនួនដែលមានទំហំធំ និង ឬ មានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការត្រួតពិនិត្យទៅលើការអនុវត្តលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនឹងត្រូវពង្រឹងជាបណ្តើរៗតាមរយៈការធ្វើសវនកម្មកិច្ចលទ្ធកម្ម ព្រមទាំងបង្កើតឲ្យមានរបបដាក់ទោសចំពោះការរំលោភបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន។ ដោយមានគម្រោងផ្តល់សិទ្ធិអំណាចនេះ ការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្ម និងការធ្វើសវនកម្មកិច្ចលទ្ធកម្មក៏ត្រូវបានធ្វើឡើង ដើម្បីធានាតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ព្រមទាំងធានាបាននូវតម្លៃសាច់ប្រាក់ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារ-ណៈ។

4) ប្រព័ន្ធរបាយការណ៍ ការតាមដាន និង ការវាយតម្លៃថវិកា

ការរៀបចំរបាយការណ៍ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌនៅមានភាពយឺតយ៉ាវ ហើយគុណភាពក៏នៅមានកម្រិត។ ដោយហេតុនេះ របបរបាយការណ៍នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវតែធ្វើ ស្ថាប័ននីយកម្ម ហើយសមត្ថភាពក្នុងការធ្វើរបាយការណ៍ថវិកាកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។ រីឯ ប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានភាពសាមញ្ញ និងសមស្របទៅតាមការទទួលខុសត្រូវជាគតិយុត្តិនៅថ្នាក់ក្រោមជាតិ។

ចំពោះរបបរបាយការណ៍នៃចង្កោមកម្មវិធីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើពីក្រោមឡើងលើ។ ចំពោះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍ពីវឌ្ឍនភាពនៃអនុកម្មវិធីទៅឲ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។

ចំពោះការវាយតម្លៃថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តត្រឹមការតាមដានថវិកា និងការធ្វើរបាយការណ៍ថវិកា។ ដោយរង់ចាំ នៅពេលដែលប្រព័ន្ធតាមដាននិងរបាយការណ៍ថវិកាអនុវត្តបានល្អហើយ ប្រព័ន្ធវាយតម្លៃថវិកានឹងចាប់ផ្តើមដាក់ឲ្យសាកល្បងជាបណ្តើរៗ។

ការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តតាមទិសដៅវិមជ្ឈការ ដោយត្រូវផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ឃ.៣. ការកែប្រែហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

### ឃ.៣.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា

ដោយសារតែមានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិច្រើន យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាបាននឹងត្រូវធ្វើការពិនិត្យ និងរៀបចំប្រមូលផ្តុំឡើងវិញ ព្រមទាំងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តិទាំងនោះក្នុងគោលបំណងធានាឲ្យមានលិខិតបទដ្ឋានគតិយុត្តរួមតែមួយ ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីពាក់ព័ន្ធនានា ដែលអាចអនុវត្តបានដោយគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្របទៅតាមចរិតលក្ខណៈនៃរចនាសម្ព័ន្ធគ្រប់គ្រង សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ឃ.៣.២. ការកសាង និងអភិវឌ្ឍសមត្ថភាព

ក្នុងគោលបំណងផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយភាពជាម្ចាស់ និងការទទួលខុសត្រូវភាគច្រើន ត្រូវបានផ្ទេរទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាការដាក់ឲ្យអនុវត្តថវិកាកម្មវិធីជាបណ្តើរៗដែលជាជំហានឆ្ពោះពីប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងវិមជ្ឈការ។ហើយដើម្បីសម្រេចបាននូវការធ្វើទំនើបកម្មនេះ ការកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ គឺចាំបាច់ណាស់ ព្រោះបើសមត្ថភាពរបស់មន្ត្រីនៅមានកម្រិតទាបនោះការអនុវត្ត អាចនឹងមានកំហុសដែលនាំឲ្យមានការខាតបង់ ក៏ដូចជាការប្រព្រឹត្តទៅនៃគម្រោងនីមួយៗមិនមានភាពរលូនទេ។

### ឃ.៣.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាបណ្តុំនៃប្រព័ន្ធស្វ័យប្រវត្តិកម្មដែលដោះស្រាយ នឹងជួសកែលម្អដល់ការរៀបចំ និងការអនុវត្តថវិកាថ្នាក់ក្រោមជាតិ តាមរយៈការពន្លឿន និងធ្វើស្វ័យប្រវត្តិកម្មទូទាត់ ការកត់ត្រាគណនេយ្យ និងការរៀបចំរបាយការណ៍។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមករដ្ឋបាលក្រុង ស្រុក ខណ្ឌជារដ្ឋបាលមូលដ្ឋានថ្នាក់កណ្តាល ដែលនៅជិតប្រជាពលរដ្ឋ និងជាដៃជើងរបស់រាជរដ្ឋាភិបាលសម្រាប់គ្រប់គ្រងប្រទេសផងដែរ។ រដ្ឋបាលនេះត្រូវបានផ្តល់នូវស្វ័យភាពទាំងផ្នែករដ្ឋបាល និងស្វ័យភាពហិរញ្ញវត្ថុក្រោយពីវិមជ្ឈការឆ្នាំ ២០០៨មក តែ ការទទួលបាននេះគ្រាន់តែជាសេរីភាពដែលរាជរដ្ឋាភិបាលបានផ្តល់ឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការសម្រេចកិច្ចការរបស់ខ្លួនដែលហៅថា កិច្ចការមូលដ្ឋាន ប៉ុណ្ណោះ មិនមែនឯករាជភាពទេ។ លើសពីនេះទៀត ស្វ័យភាពដែលបានផ្តល់ឲ្យដោយរាជរដ្ឋាភិបាល ក៏មិនទូលំទូលាយ ដែលអនុញ្ញាតឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ធ្វើការសម្រេចដោយខ្លួនឯងទាំងស្រុងទេ គឺទាមទារឲ្យមានការជ្រោមជ្រែងពីស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ដោយសារតែកម្រិតសមត្ថភាពប្រព័ន្ធដឹកនាំ ការផ្តល់សេវា នៅមានកម្រិតនាំឲ្យការអភិវឌ្ឍ និងការកែប្រែត្រូវតែធ្វើឡើងជាដាច់ខាតដើម្បីសម្រេចបាននូវគោលដៅជាតិ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវកិច្ចការរដ្ឋបាលសាធារណៈ។ ការធ្វើកំណែទម្រង់របស់រដ្ឋបាលនេះគឺធ្វើឡើងដោយកែប្រែទាំងប្រព័ន្ធផ្តល់សេវា រចនាសម្ព័ន្ធ សិទ្ធិអំណាច និង ប្រព័ន្ធថវិកា។

ចំពោះការកែប្រែរចនាសម្ព័ន្ធការងារដែលសំដៅដល់ការការកែប្រែសេវា គឺមានការផ្លាស់ប្តូរពីការផ្តល់សេវាលក្ខណៈស្មុគស្មាញ យឺតយ៉ាវ មិនសូវមានប្រសិទ្ធភាព ដោយប្រព័ន្ធផ្តល់សេវាដាច់ដោយឡែក ដែលនាំឲ្យប្រជាពលរដ្ឋមានភាពពិបាកក្នុងការទទួលយកសេវាសាធារណៈទាំងនោះ មកជា ការផ្តល់សេវាដែលមានប្រសិទ្ធភាពខ្ពស់ រហ័ស ងាយស្រួល ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មាន ក៏ដូចជាការប្រើប្រាស់នូវវិធានការផ្តល់សេវារួមតាមរយៈការិយាល័យដែលបានបង្កើតឡើង ជាក់ស្តែង ការិយាល័យច្រកចេញចូលតែមួយ។ រីឯការកែប្រែមនុស្សដែលសំដៅដល់សិទ្ធិសម្រេច ឬថ្នាក់ដឹកនាំនៃរដ្ឋបាលនេះ គឺកែប្រែពីប្រព័ន្ធដឹកនាំតាមឋានានុក្រម មកការដឹកនាំតាមបែបប្រជាធិបតេយ្យដោយមានក្រុមប្រឹក្សា ជំនួសឲ្យអភិបាលដែលជាថ្នាក់ដឹកនាំកំពូលនៃ រដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ។ ក្នុងចំណុចនេះ ការកែប្រែមានប្រសិទ្ធភាព ដោយហេតុថាប្រជាពលរដ្ឋអាចទទួលយកសេវាបានងាយស្រួលជាងមុន និងយល់ដឹងពីការផ្តល់សេវាបានច្រើនជាងមុន ក៏ប៉ុន្តែការកែប្រែនេះនៅមានការខ្វះខាតនៅឡើយ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរលើប្រព័ន្ធនេះបន្ថែមទៀត ដោយត្រូវអភិវឌ្ឍវិធីសាស្ត្រនៃការផ្តល់សេវានេះ ទៅតាមបច្ចេកវិទ្យាដែលកំពុងរីកចម្រើនសព្វថ្ងៃ ដែលនាំឲ្យការផ្តល់សេវាមានភាពទំនើប និងងាយស្រួល។ មិនតែប៉ុណ្ណោះ ចំពោះសិទ្ធិអំណាចដែលបានផ្តល់ទៅឲ្យក្រុមប្រឹក្សាគឺជា វិធីសាស្ត្រដ៏ឆ្លាតវៃ ដោយសារមានការប្រជុំ និងមានការពិភាក្សាដែលនាំឲ្យការសម្រេចមានភាពល្អិតល្អន់ និងមានលក្ខណៈប្រជាធិបតេយ្យដោយសារមានការបញ្ចេញមតិរបស់សមាជិកទាំងអស់។

រីឯការកែប្រែទៅលើប្រព័ន្ធថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ វិញ គឺត្រូវបានកែប្រែដោយពឹងផ្អែកលើកម្មវិធីកំណែទម្រង់ ថវិកាកម្មវិធី ដែលធ្វើឡើងដើម្បីផ្សារភ្ជាប់ថវិកានឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងធ្វើឲ្យការប្រើប្រាស់ថវិការបស់រដ្ឋបាលនេះមានភាពច្បាស់លាស់ និងស្របទៅតាមគោលការណ៍ដែលរាជរដ្ឋាភិបាលបានកំណត់ ដោយសារតែថវិកាដែលចំណាយបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមិនទាន់សមស្របនឹងគោលនយោបាយនៅឡើយ។ ម្យ៉ាងវិញទៀត ចំពោះប្រតិបត្តិការចំណូលចំណាយក៏ត្រូវបានផ្លាស់ប្តូរ ដែលចំណូលរបស់រដ្ឋបាលនេះត្រូវបានបន្ថែមដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្គត់ផ្គង់ការចំណាយរបស់រដ្ឋបាលនេះ ក៏ដូចជាបង្កើននូវលទ្ធភាពក្នុងការអភិវឌ្ឍតំបន់ផងដែរ។ ទន្ទឹមនឹងការបន្ថែមចំណូលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌតាមរយៈមូលនិធិក្រុង ស្រុក និងការកាត់ពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត មកឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនោះ ការចំណាយក៏មានការត្រួតពិនិត្យពីរាជរដ្ឋាភិបាលផងដែរ ដោយតម្រូវឲ្យមានការរៀបចំជាផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ការធ្វើសវនកម្ម ក៏ដូចជាការធ្វើរបាយការណ៍របស់រដ្ឋបាលជូនទៅរាជរដ្ឋាភិបាលផងដែរ ដោយរាល់កិច្ចការពាក់ព័ន្ធនឹងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវឆ្លងកាត់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាអ្នកប្រឹក្សា ដោយសាររដ្ឋបាលនេះមិនទាន់ទទួលបាននូវស្វ័យភាពពេញលេញក្នុងការសម្រេចលើថវិកានេះនៅឡើយ។ ត្រង់ចំណុចនេះបានបង្ហាញឲ្យឃើញថាថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំយ៉ាងច្បាស់លាស់ដែលជាវិធីសាស្ត្រដ៏ល្អ ដែលមានការជ្រោមជ្រែងពីរាជរដ្ឋាភិបាល ក៏ប៉ុន្តែដរាបណារដ្ឋបាលក្រុង ស្រុក ខណ្ឌមិនទាន់ទទួលបាននូវស្វ័យភាពពេញលេញក្នុងការសម្រេច ការអនុវត្តរបស់ រដ្ឋបាលនេះនៅតែមិនទាន់មានភាពរហ័ស និងមានប្រសិទ្ធភាពទេ ព្រោះការអនុវត្តនៅតាមតំបន់តម្រូវការមានភាពខុសគ្នា ដែលតម្រូវឲ្យការប្រើប្រាស់ថវិកាតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗមានភាពខុសគ្នា ហើយការប្រើប្រាស់ថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវឆ្លងកាត់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលនាំឲ្យរដ្ឋបាលនេះមិនអាចសម្រេចលើការអភិវឌ្ឍ ដោយខ្លួនឯងទាំងស្រុង និងនាំឲ្យរាជរដ្ឋាភិបាលពិបាកក្នុងការវាយតម្លៃពីការដឹកនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗបាន។

ការធ្វើកំណែទម្រង់ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទាមទារឲ្យមានការធ្វើឡើងជាបន្ត បន្ទាប់ព្រោះការអភិវឌ្ឍរបស់ប្រទេសមួយគឺទាមទារឲ្យមានការអភិវឌ្ឍពីក្រោមឡើងទៅ បើសិនជាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ក៏ដូចជារាជធានីមានភាពរីកចម្រើននោះ ការដឹកនាំ ការកំណត់ពីគោលនយោបាយអភិវឌ្ឍបន្តទៅទៀតគឺមានភាពល្អប្រសើរជាង និង មានសក្តានុពលខ្លាំង ដែលនាំយើងឆ្ពោះទៅរកភាពជោគជ័យក្នុងការ អភិវឌ្ឍប្រទេសជាតិទាំងមូល។

# ការផ្តល់អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវរួចមកបានបង្ហាញឲ្យឃើញថា រដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចចាំបាច់ក្នុងការគ្រប់គ្រង ដឹកនាំ ថែរក្សា អភិវឌ្ឍ ក្រុង ស្រុក ខណ្ឌនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៀតយើងរកឃើញថារដ្ឋបាលក្រុង ស្រុក ខណ្ឌទទួលស្វ័យភាពមិនទាន់ពេញលេញនៅឡើយ បើទោះបីជាមានការកែប្រែកន្លងមកហើយក្តី ក៏នៅមានបញ្ហាជាច្រើនដែលត្រូវដោះស្រាយនិង កែប្រែជាបន្តបន្ទាប់។ ដូចដែលខ្ញុំបាទបានធ្វើការសន្និដ្ឋានខាងលើ ខ្ញុំបាទសូមបញ្ចេញនូវមតិផ្ទាល់ខ្លួនមួយចំនួនក្នុងគោលបំណងជួយពង្រឹងនិងបង្កើនសក្តានុពល ប្រសិទ្ធិភាពក្នុងការកែប្រែទៅលើរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ ៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់គួរតែទទួលបាននូវស្វ័យភាពពេញលេញដើម្បីអនុវត្តការងារបានឆាប់រហ័ស និងមានប្រសិទ្ធិភាព ដោយរាជរដ្ឋាភិបាលអាចប្រគល់ស្វ័យភាពនោះនៅពេលដែលសមត្ថភាពរបស់មន្ត្រីស្ថិតក្នុងកម្រិតល្អប្រសើរ
- បណ្តុះបណ្តាលមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការបង្កើតជាកម្មវិធីសិក្សាអភិវឌ្ឍសមត្ថភាពជាដើម
- ជម្រុញ និងលើកទឹកចិត្តដល់រដ្ឋបាល ឲ្យធ្វើការអស់ពីកម្លាំងកាយចិត្ត ដើម្បីអភិវឌ្ឍសង្គមជាតិ
- បង្កើតស្មារតីរួមក្នុងស្ថាប័ន និង គិតពីផលប្រយោជន៍រួមជាធំ
- ជម្រុញឲ្យមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌធ្វើការដោយសហការគ្នាឲ្យបានស្អិតរមួត
- បង្កើតទម្រង់ផ្តល់សេវាថ្មី តាមរយៈប្រព័ន្ធអេឡិចត្រូនិច
- បង្កើនចំណូលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- អភិវឌ្ឍធនធានមនុស្សបន្ថែម
- ជម្រុញឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអនុវត្តការងារស្របតាមច្បាប់ និងគោលការណ៍អភិវឌ្ឍឲ្យបានខ្ជាប់ខ្ជួន
- បង្កើតឲ្យមានភាពទូលំទូលាយក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេវាកម្មរបស់រដ្ឋបាលតាមរ-យៈប្រព័ន្ធអ៊ីនធឺណិត

# ឯកសារយោង

❈❈❈


- **លិខិតបទដ្ឋានគតិយុត្ត**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
  - ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
  - អនុក្រឹត្យលេខ: ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាល ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
  - យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ខែឧសភា ឆ្នាំ ២០១៩
- **សៀវភៅទ្រឹស្តី**
  - សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ខែកញ្ញា ឆ្នាំ ២០១០
  - សៀវភៅណែនាំស្តីពី ការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ខែកក្កដា ឆ្នាំ ២០១៥
  - សៀវភៅនីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ឡឺក ពិដោរ
- **ឯកសារផ្សេងៗ**
  - កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ ខែមីនា ឆ្នាំ២០១៩
  - បទបង្ហាញថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - បទបង្ហាញស្តីពីទស្សនវិស័យនៃកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០
  - អត្ថបទក្រុមប្រឹក្សាក្រុង ស្រុក ទទួលបានតាមរយៈhttps://km.wikipedia.org/wiki/ក្រុមប្រឹក្សាក្រុង-ស្រុក
  - វចនានុក្រមបារាំង Dictionnaire encyclopédique

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

ក្រសួងមុខងារសាធារណៈ

MINISTRY OF CIVIL SERVICE

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០

ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ
និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
រាជធានីភ្នំពេញ ថ្ងៃទី ២៦-២៧ ខែមីនា ឆ្នាំ២០១៩

## មាតិកា

1. ភាពចាំបាច់នៃការអនុវត្តការកែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល
2. បញ្ហាប្រឈមនិងតម្រូវការនៃការកែទម្រង់រដ្ឋបាលសាធារណៈ
3. អភិក្រមនៃការរៀបចំនិងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
4. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០
   - ចក្ខុវិស័យ
   - គោលបំណង
   - គោលដៅ
   - យុទ្ធសាស្ត្រ
   - ក្របខណ្ឌពេលវេលានៃការរៀបចំ និងការអនុវត្តកម្មវិធីជាតិ
   - យន្តការស្ថាប័នសម្រាប់ការអនុវត្ត
   - ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកម្មវិធីជាតិ
   - ប្រភពធនធាននិងគោលការណ៍លើកទឹកចិត្ត

# ភាពចាំបាច់នៃការអនុវត្តការកែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល

គំនូសបំព្រួញស្ដីពី «យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៤»
ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព : កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

គោលដៅជាយុទ្ធសាស្ត្រនៃអភិបាលកិច្ចៈ
- ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ
- ការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០



# បញ្ហាប្រឈមនិងតម្រូវការនៃការកែទម្រង់រដ្ឋបាលសាធារណៈ

- សេវាសាធារណៈមិនទាន់ទទួលបានទំនុកចិត្តពេញលេញពីសាធារណៈជន
- ក្របខណ្ឌបទដ្ឋានលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការផ្ដល់សេវាសាធារណៈមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងប្រសិទ្ធភាព
- សមត្ថភាពរបស់មន្ត្រីសាធារណៈដើម្បីអនុវត្តច្បាប់គឺស្ថិតនៅក្រោមកម្រិតដែលត្រូវការ
- ប្រសិទ្ធភាពនៃការអនុវត្តការងារពាក់ព័ន្ធនឹងសមត្ថភាពរបស់ស្ថាប័ន និងការសម្របសម្រួលលក្ខណៈអន្តរស្ថាប័ននៅមានកម្រិត
- សកម្មភាពអនុវត្តការងារជាប្រចាំមិនស្របជាមួយនឹងគោលដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ការរៀបចំរចនាសម្ព័ន្ធ និងការផ្ទេរមុខងារនិងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ
- បញ្ហាប្រឈមនៅក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤
- ការជំរុញឲ្យមានការប្រកួតប្រជែងនៅកម្ពុជាដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតមានឡើងនិងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដំណាក់កាលនៃការអភិវឌ្ឍថ្មី

# អភិក្រមនៃការរៀបចំនិងការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

| ការរៀបចំនិងអនុវត្តកម្មវិធីជាតិ | | | |
|---|---|---|---|
| ជំហានទី១៖ ការរៀបចំសេចក្តីព្រាង | ជំហានទី២៖ ការពិគ្រោះយោបល់ | ជំហានទី៣៖ ការអនុម័តកម្មវិធីជាតិ | ជំហានទី៤៖ ការអនុវត្តកម្មវិធីជាតិ |

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

- ចក្ខុវិស័យកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ:២០១៩-២០២៣ គឺដើម្បីធានាឱ្យបាននូវរដ្ឋបាលសាធារណៈ ស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្តោតលើប្រជាជនជាស្នូល សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម ប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌



# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

**គោលបំណង៖ ការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ**

**គោលដៅ៖ អនុវត្តជា៣ដំណាក់កាលៗ**

| ដំណាក់កាលទី១<br>២០១៩-២០២៣ | ដំណាក់កាលទី២<br>២០២៣-២០២៧ | ដំណាក់កាលទី៣<br>២០២៧-២០៣០ |
|---|---|---|
| • ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | • ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | • គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ |

**យុទ្ធសាស្ត្រ**

1. ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ
2. ការជំរុញនិងការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
3. ការផ្សារភ្ជាប់សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈជាមួយការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល


# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០


## ក្របខណ្ឌពេលវេលានៃការរៀបចំ និងការអនុវត្តកម្មវិធីជាតិ

**ដំណាក់កាលទី១ (២០១៩-២០២៣)**
**ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ**

| ចង្កោមសកម្មភាព១៖ ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ | ចង្កោមសកម្មភាព២៖ ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ | ចង្កោមសកម្មភាព៣៖ ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ |
|---|---|---|

## កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

### ក្របខណ្ឌពេលវេលានៃការរៀបចំ និងការអនុវត្តកម្មវិធីជាតិ

| ដំណាក់កាលទី២ (២០២៣-២០២៧) ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | | |
|---|---|---|
| ចង្កោមសកម្មភាព១៖ ការបន្តសកម្មភាពដែលបានអនុវត្តនិងមិនទាន់អនុវត្តពេញលេញក្នុងដំណាក់កាលទី១ | ចង្កោមសកម្មភាព២៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | ចង្កោមសកម្មភាព៣៖ ការត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម |

## កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

### ក្របខណ្ឌពេលវេលានៃការរៀបចំ និងការអនុវត្តកម្មវិធីជាតិ

| ដំណាក់កាលទី៣ (២០២៧-២០៣០) គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ | | |
|---|---|---|
| ចង្កោមសកម្មភាព១៖ ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្តនិងមិនទាន់អនុវត្តបានពេញលេញក្នុងដំណាក់កាលទី២ | ចង្កោមសកម្មភាព២៖ សេវាសាធារណៈប្រកបដោយឧត្តមភាព | ចង្កោមសកម្មភាព៣៖ ការត្រួតពិនិត្យនិងវាយតម្លៃគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ |

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

## យន្តការស្ថាប័នសម្រាប់ការអនុវត្ត

- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

តួនាទីនិងភារកិច្ចៈ

- ➢ ដឹកនាំ សម្របសម្រួល ជំរុញការអនុវត្ត
- ➢ តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

លេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាព

គណៈកម្មាធិការកែទម្រង់នៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមៈ

- ➢ អនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដោយផ្សាភ្ជាប់សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈជាមួយនឹងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ➢ រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈជាប្រចាំត្រីមាស ឆមាស និងឆ្នាំមកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

## ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

ធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តជាប្រចាំត្រីមាស ឆមាស ឆ្នាំ ផ្អែកលើសូចនាករសមិទ្ធកម្ម

ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

រៀបចំឱ្យមានការវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តរៀងរាល់ពីរឆ្នាំម្តង ធ្វើឡើងដោយស្ថាប័ន ឬអ្នកជំនាញបច្ចេកទេសពីខាងក្រៅ

លទ្ធផលនៃការវាយតម្លៃដែលធ្វើឡើងដោយស្ថាប័ន ឬអ្នកជំនាញបច្ចេកទេសពីខាងក្រៅ គឺសម្រាប់តែការប្រើប្រាស់ផ្ទៃក្នុង

# ឧបសម្ព័ន្ធទី ២

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ថវិកាកម្មវិធី



# មាតិកា

ផ្នែកទី១ និដ្ឋភាពទូទៅនៃថវិកាកម្មវិធី

១.១. សេចក្តីផ្តើម

១.២. និយមន័យ

១.៣. អត្ថប្រយោជន៍

ផ្នែកទី២ ដំណើរការរៀបចំថវិកាកម្មវិធី

២.១. ការកំណត់គោលបំណងគោលនយោបាយ

២.២. ការបង្កើតរចនាសម្ព័ន្ធកម្មវិធី

២.៣. ការកំណត់សូចនាករ

២.៤. ការគណនាតម្រូវការចំណាយ

២.៥. ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

# ១.១. សេចក្ដីផ្ដើម

- ថវិកាកម្មវិធី គឺជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ក្រសួងចំនួន ៧ ត្រូវបានដាក់ឲ្យអនុវត្តសាកល្បងថវិកាកម្មវិធី ចាប់តាំងពីឆ្នាំ២០០៧ និងឆ្នាំ២០០៨ បានបន្ថែមក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មួយទៀត
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាន និងកំពុងស្នើឲ្យមានការពង្រឹង និងពង្រីកថវិកាកម្មវិធីបន្ថែមទៀត។



# ១.២. និយមន័យ

- ជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដោយឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួង
- ត្រូវមានសូចនាករសមិទ្ធិកម្មសម្រាប់យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ត្រូវអាចវាស់វែង និងធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមកម្មវិធីនីមួយៗ
- ត្រូវកំណត់ឲ្យបានច្បាស់លាស់នូវធាតុចូល ដែលមានចំណាយចរន្ត និងចំណាយមូលធនសម្រាប់អនុវត្តចង្កោមសកម្មភាព ។

## ១.៣. អត្ថប្រយោជន៍

- ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន គោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- កែលម្អគណនេយ្យភាពស្ថាប័ន ដើម្បីសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុក
- ផ្តល់ព័ត៌មាន កាន់តែប្រសើរជាងមុនដល់មន្ត្រីជំនាញ និងថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តវិភាជធនធាន

## អត្ថប្រយោជន៍ (ត)

- ផ្លាស់ប្តូរពីការយកចិត្តទុកដាក់តែលើធាតុចូល ទៅជាការផ្តោតទៅលើលទ្ធផលចុងក្រោយដែលរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបាន
- ជំរុញការប្រើប្រាស់ការវិភាគអត្ថប្រយោជន៍នៃថ្លៃចំណាយ (Cost-Benefit Analysis) ក្នុងចំណោមជម្រើសជាច្រើន ក្នុងការសម្រេចបានគោលដៅលទ្ធផលចុងក្រោយរបស់កម្មវិធី។

## ២.១. ការកំណត់គោលបំណងគោលនយោបាយ

ដើម្បីកំណត់គោលបំណងគោលនយោបាយឲ្យបានសមស្រប ត្រូវផ្អែកលើ÷

- យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP)
- គោលនយោបាយតាមវិស័យ
- អាណត្តិកិច្ច/ តួនាទី និងភារកិច្ចរបស់ក្រសួង- ស្ថាប័ន

## ២.២. ការបង្កើតរចនាសម្ព័ន្ធកម្មវិធី



# រចនាសម្ព័ន្ធសូចនាករលទ្ធផល




## សូចនាករថវិកាកម្មវិធី

***និយមន័យ***

**សូចនាករ:** គឺជារង្វាស់លើលទ្ធផលដែលសម្រេចបាន ។ សូចនាករអាចជាបរិមាណ ឬជាគុណភាព។

**សូចនាករលទ្ធផលចុងក្រោយ:** ជារង្វាស់ភាពសក្តិសិទ្ធិនៃលទ្ធផលចុងក្រោយ ដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលក្នុងឆ្នាំដែលសម្រេចបាន ។

**សូចនាករលទ្ធផលក្នុងឆ្នាំ:** ជារង្វាស់លទ្ធផលក្នុងឆ្នាំ លើការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី ឬកម្មវិធី ធៀបទៅនឹងគោលដៅដែលបានកំណត់ដើម្បីបញ្ជាក់ពីប្រសិទ្ធភាពថវិកា។

# សារៈសំខាន់នៃការកំណត់ថ្លៃចំណាយ

- មានសារៈសំខាន់ក្នុងការប្រៀបធៀបលទ្ធផលកម្មវិធីដែលរំពឹងទុកទៅនឹងចំណាយលើការបង្កើតលទ្ធផលកម្មវិធី
  - ធ្វើឲ្យសមត្ថភាពកាន់តែប្រសើរសម្រាប់អ្នកសម្រេចចិត្តក្នុងការវិភាជន៍ថវិកាដល់កម្មវិធីឲ្យមានប្រសិទ្ធភាពបំផុត
  - ការប្រៀបធៀបថ្លៃចំណាយ និងលទ្ធផលកម្មវិធី (ចំណាយមានប្រសិទ្ធភាពតិច ឬច្រើន) អាចនាំទៅដល់ការជ្រើសរើសយុទ្ធសាស្ត្រផ្សេងៗ ។

# ទំនាក់ទំនងធាតុចូល និងលទ្ធផល

- ខ្សែសង្វាក់លទ្ធផលត្រូវបានកំណត់ដូចខាងក្រោម÷




- ធាតុចូលគឺជាធនធានដែលត្រូវចំណាយដើម្បីបង្កើតលទ្ធផលក្នុងឆ្នាំ (ប្រាក់បៀវត្សរ៍ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់។ល។)
- ថ្លៃចំណាយកម្មវិធីអាស្រ័យលើលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំដែលចង់បាន។

# ថ្លៃចំណាយកម្មវិធី




# ឧទាហរណ៍ចំណាយផ្ទាល់របស់កម្មវិធី

| ចំណាយ លើ កម្មវិធី | | | |
|---|---|---|---|
| | | | ឯកតា: ពាន់រៀល |
| ធាតុ ចូល | ចំនួន | ថ្លៃឯ កតា | ថ្លៃស រុប |
| ប្រាក់ឈ្នួលបុគ្គលិក | 1,000 | 19,200 | 19,200,000 |
| ពូជស្រូវ/ តោន | 50,000 | 3,200 | 160,000,000 |
| វគ្គបណ្តុះបណ្តាល | 1,000 | 200 | 200,000 |
| សោហ៊ុយធ្វើដំណើររបស់បុគ្គលិក | 1,000 | 400 | 400,000 |
| សរុបថ្លៃចំណាយផ្ទាល់ ប្រចាំឆ្នាំ | | | **179,800,000** |

## ❑ ផលប៉ះពាល់នៃអតិផរណា

**អតិផរណា** គឺជាការកើនឡើងនៃតម្លៃទូទៅ។

- ការកើនឡើង 4% លើប្រាក់ឈ្នួលបុគ្គលិក និង 2% លើចំណាយផ្សេងៗ ដទៃទៀត នាំឱ្យថ្លៃចំណាយប្រែប្រួលដូចតារាងខាងក្រោម÷

| | | | ឯកតា: ពាន់រៀល |
|---|---|---|---|
| **ធាតុ ចូល** | **ចំនួន** | **ថ្លៃឯ កតា** | **ថ្លៃស រុប** |
| ប្រាក់ឈ្នួលបុគ្គលិក | 1,000 | 19,968 | 19,968,000 |
| ពូជស្រូវ/ តោន | 50,000 | 3,264 | 163,200,000 |
| វត្ថុបណ្ដុះបណ្ដាល | 1,000 | 204 | 204,000 |
| សោហ៊ុយធ្វើដំណើររបស់បុគ្គលិក | 1,000 | 408 | 408,000 |
| សរុបថ្លៃចំណាយផ្ទាល់ ប្រចាំឆ្នាំ | | | **183,780,000** |

## ❑ ផលប៉ះពាល់នៃការផ្លាស់ប្តូរតម្រូវការ

**ការផ្លាស់ប្តូរតម្រូវការសម្រាប់កម្មវិធី** ដូចជា ចំនួនកសិករ ឬទំហំផ្ទៃដីដាំដុះនៅក្នុងកម្មវិធី

- សន្មតថា កសិករកើនឡើងចំនួន 15,000 និងផ្ទៃដីកើនឡើង 45,000 ហិកតា

| | | | ឯកតា: ពាន់រៀល |
|---|---|---|---|
| **ធាតុ ចូល** | **ចំនួន** | **ថ្លៃឯ កតា** | **ថ្លៃស រុប** |
| ប្រាក់ឈ្នួលបុគ្គលិក | 1,150 | 19,968 | 22,963,200 |
| ពូជស្រូវ/ តោន | 55,625 | 3,264 | 181,560,000 |
| វត្ថុបណ្ដុះបណ្ដាល | 1,150 | 204 | 234,600 |
| សោហ៊ុយធ្វើដំណើររបស់បុគ្គលិក | 1,150 | 408 | 469,200 |
| សរុបចំណាយផ្ទាល់ | | | 205,227,000 |

## ❑ ផលប៉ះពាល់នៃការផ្លាស់ប្តូរគោលនយោបាយ

**ការផ្លាស់ប្តូរគោលនយោបាយ** : បង្កើន ឬបន្ថយគោលបំណងគោលនយោបាយ ការផ្លាស់ប្តូរយុទ្ធសាស្ត្រ និងការសម្រេចចិត្តផ្សេងទៀតដែលអាចប៉ះពាល់ដល់កម្មវិធីដែលត្រូវអនុវត្ត។

- សន្មតថា ក្រសួងចង់ប្រើប្រភេទពូជស្រូវល្អប្រសើរជាងមុន មានតម្លៃថ្លៃជាងមុន (ថ្លៃក្នុង ១ តោន គឺ = 3,400,000 រៀល) ដោយមិនមានការផ្លាស់ប្តូរចំពោះឧទាហរណ៍ពីមុន

## ❑ ផលប៉ះពាល់នៃការផ្លាស់ប្តូរគោលនយោបាយ (ត)

ដោយប្រើប្រភេទពូជស្រូវល្អជាងមុន (ថ្លៃក្នុង ១ តោន = 3,400,000 រៀល) នាំឲ្យថ្លៃចំណាយប្រែប្រួលដូចតារាងខាងក្រោម÷

| | | | ឯកតា: ពាន់រៀល |
|---|---|---|---|
| **ធាតុ ចូល** | **ចំនួន** | **ថ្លៃឯ កតា** | **ថ្លៃស រុប** |
| ប្រាក់ឈ្នួលបុគ្គលិក | 1,150 | 19,968 | 22,963,200 |
| ពូជស្រូវ/ តោន | 55,625 | 3,400 | 189,125,000 |
| វគ្គបណ្តុះបណ្តាល | 1,150 | 204 | 234,600 |
| សោហ៊ុយធ្វើដំណើររបស់បុគ្គលិក | 1,150 | 408 | 469,200 |
| សរុបចំណាយផ្ទាល់ | | | 212,792,000 |

## ២. ការកំណត់ថ្លៃចំណាយផ្ទាល់ ដែលមិនមានការចំណាយពីមុន

- ដើម្បីកំណត់ថ្លៃចំណាយចំពោះកម្មវិធីថ្មីដែលមិនមានព័ត៌មានពីការចំណាយពីមុន គួរពិចារណាអំពីកត្តាមួយចំនួនដូចខាងក្រោម÷
  - តម្រូវឱ្យមានការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង
  - កម្មវិធីស្រដៀងគ្នាអាចយកមកធ្វើជាមូលដ្ឋានសម្រាប់គណនាថ្លៃចំណាយ
    - ❖ សំណួរដូចខាងក្រោមនេះ អាចជួយកំណត់ពីការចំណាយ:
      - ✓ តើមានប្រជាពលរដ្ឋប៉ុន្មាននាក់ ដែលត្រូវទទួលបានសេវាសាធារណៈ?
      - ✓ តើបុគ្គលិកម្នាក់អាចផ្តល់សេវាដល់ប្រជាពលរដ្ឋបានប៉ុន្មាននាក់?
      - ✓ តើអ្វីទៅជាការចំណាយគាំទ្រ ដែលបុគ្គលិកម្នាក់ៗត្រូវការ (បៀវត្ស សោហ៊ុយដឹកជញ្ជូន ទូរស័ព្ទ ឬការផ្គត់ផ្គង់សម្ភារៈ ។ល។)

## ប្រភេទនៃកត្តាជំរុញថ្លៃចំណាយ

- កត្តាជំរុញថ្លៃចំណាយ (Cost driver) សំដៅទៅលើកត្តាដែលនាំឱ្យថ្លៃចំណាយកម្មវិធីប្រែប្រួល (**កើនឡើង ឬថយចុះ**)។
- កត្តាជំរុញថ្លៃចំណាយមាន ៥ ប្រភេទសំខាន់ៗ ដូចខាងក្រោម÷
  - ការប្រែប្រួលប្រជាសាស្ត្រ
  - ការប្រែប្រួលសង្គមនិងសេដ្ឋកិច្ច
  - ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល
  - ការរីកចម្រើនផ្នែកបច្ចេកវិទ្យា
  - បរិយាកាសខាងក្រៅ

# ប្រភេទនៃកត្តាជំរុញថ្លៃចំណាយ (ត)

- **ការប្រែប្រួលប្រជាសាស្ត្រ៖**
  - ចំនួនសិស្សកំណត់តម្រូវការផ្នែកអប់រំ
  - ចំនួនមនុស្សចាស់កំណត់តម្រូវការលើការចំណាយថ្លៃវេជ្ជសាស្ត្រ និង ចំណាយសោធននិវត្តន៍
- **ការប្រែប្រួលសង្គម និងសេដ្ឋកិច្ច៖**
  - អត្រាលែងលះធ្វើឱ្យប៉ះពាល់ដល់តម្រូវការថែទាំកុមារ និងមនុស្សចាស់
  - អត្រាប្រើប្រាស់គ្រឿងញៀនធ្វើឱ្យប៉ះពាល់ដល់តម្រូវការសេវាវេជ្ជសាស្ត្រ និងនគរបាល
  - ការធ្លាក់ចុះសេដ្ឋកិច្ចជាសកលបង្កើតតម្រូវការការបណ្តុះបណ្តាលការងារ



# ប្រភេទនៃកត្តាជំរុញថ្លៃចំណាយ (ត)

- **ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល៖**
  - ការផ្លាស់ប្តូរសិទិទទួលបានអត្ថប្រយោជន៍សង្គមធ្វើឱ្យប៉ះពាល់បន្ទុកការងារ វិស័យសាធារណៈ
  - ការផ្លាស់ប្តូរពូជស្រូវថ្មីសម្រាប់ផ្តល់ជូនកសិករ ដើម្បីបង្កើនទិន្នផល នាំឱ្យតម្រូវការចំណាយលើពូជស្រូវថ្មីកើនឡើង
- **ការរីកចម្រើនផ្នែកបច្ចេកវិទ្យា៖**
  - ឱសថ ឬបច្ចេកទេសវេជ្ជសាស្ត្រថ្មីៗអាចកាត់បន្ថយថ្លៃចំណាយលើការថែទាំវេជ្ជសាស្ត្រ
  - ការផ្តល់ព័ត៌មានតាមរយៈប្រព័ន្ធអ៊ីនធឺណិតកាត់បន្ថយថ្លៃចំណាយលើការបោះពុម្ព និងការមកទទួលព័ត៌មាននៅការិយាល័យរបស់សាធារណៈជន

# ប្រភេទនៃកត្តាជំរុញថ្លៃចំណាយ (ត)

**បរិយាកាសខាងក្រៅ÷**

- ស្តង់ដារថ្មីដែលបានដាក់តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិដូចជា:
    - អង្គការពាណិជ្ជកម្មពិភពលោក
    - ពិធីសារក្រុងក្យូតូអំពីបម្រែបម្រួលអាកាសធាតុ
    - គណៈកម្មាធិការទន្លេមេគង្គ
- ការជូនដំណើងអំពីជម្ងឺផ្តាសាយបក្សីពីប្រទេសជិតខាង
- ការផ្លាស់ប្តូរស្ថានភាពនយោបាយរបស់ប្រទេសជិតខាង

# ភាតព្វកិច្ច និងឆន្ទានុសិទ្ធិ (Mandatory Vs Discretionary)

- កត្តាជំរុញថ្លៃចំណាយអាចជាកាតព្វកិច្ច
    - សិទ្ធិស្របច្បាប់ក្នុងការទទួលបានសេវាដូចជា ការអប់រំ
    - ចំណាយលើការសងបំណុល

# ឧទាហរណ៍អំពីកត្តាជំរុញថ្លៃចំណាយ

***វិស័យរដ្ឋបាលទូទៅ***

- ក្រសួងយុត្តិធម៌
  - ចំនួនរឿងក្តីដែលបានប្តឹងទៅតុលាការ
  - ចំនួនបទឧក្រិដ្ឋដែលបានរាយការណ៍
  - ចំនួនអ្នកជាប់ពន្ធនាគារ
- ក្រសួងហិរញ្ញវត្ថុ
  - ចំនួនឯកសារពន្ធដែលបានប្រកាស
- ក្រសួងការបរទេស
  - ចំនួនដាក់ពាក្យសុំលិខិតឆ្លងដែន និងទិដ្ឋាការ
  - ចំនួនស្ថានទូត និងស្ថានកុងស៊ុលដែលមាន

# កត្តាជំរុញ និងលទ្ធផលក្នុងឆ្នាំ

| | | |
|---|---|---|
| កត្តាជំរុញ | ប្រជាជនដល់អាយុចូលរៀន | ក្រៅការគ្រប់គ្រងរបស់ក្រសួង |
| ធាតុចូល | គ្រូ សាលារៀន សម្ភារៈសិក្សា | ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង |
| លទ្ធផលក្នុងឆ្នាំ | ចំនួនសិស្សទទួលបានការបង្រៀន | |

# ការគណនាថ្លៃចំណាយ

| | |
|---|---|
| ថ្លៃចំណាយមួយឯកតា | សមស្រប |
| × | |
| កត្តាជំរុញថ្លៃចំណាយ | ការប៉ាន់ស្មាន |
| = | |
| ថ្លៃចំណាយ | លទ្ធផលក្នុងឆ្នាំ |

## កត្តាជំរុញ ថ្លៃចំណាយក្នុងមួយឯកតាក្នុងករណីមានអតិផរណា

- អាចប្រើការប៉ាន់ស្មានលើបម្រែបម្រួលកត្តាជំរុញ ថ្លៃចំណាយ និងអតិផរណាដើម្បីព្យាករបម្រែបម្រួលថវិកា
- ឧទាហរណ៍ពីវិស័យអប់រំ÷
  - ថ្លៃចំណាយក្នុង ១ ឯកតា = ថ្លៃចំណាយសរុប/ចំនួននិស្សិតសរុប
  - ថ្លៃចំណាយមួយឯកតាកើនឡើងតាមអតិផរណា
  - ចំនួននិស្សិតកើនឡើងតាមអត្រាកំណើន
  - ថ្លៃចំណាយសរុបថ្មី = ចំនួនសិស្សសរុបថ្មី x ថ្លៃចំណាយថ្មីក្នុង ១ ឯកតា

| | អត្រា | ចំនួននិសិត្យ | ថ្លៃចំណាយក្នុង 1ឯកតា | ថ្លៃចំណាយសរុប |
|---|---|---|---|---|
| ឆ្នាំបច្ចុប្បន្ន | | 1,150,000 | 1.640 | 1,886,000 |
| អតិផរណា | 3.40% | | 0.056 | |
| កំណើននិស្សិត | 1.70% | 19,550 | | |
| ឆ្នាំថវិកា | | 1,169,550 | 1.696 | 1,983,557 |

# ការវិភាជថ្លៃចំណាយប្រយោល

- ចាំបាច់ត្រូវកំណត់ថ្លៃចំណាយកម្មវិធីពិតប្រាកដ។
- មានវិធីសាស្ត្រជាច្រើនដើម្បីវិភាជថ្លៃចំណាយប្រយោលសម្រាប់កម្មវិធី÷
  - វិធីសាស្ត្រ "**ពីលើចុះក្រោម**" ដែលសាមញ្ញ ដោយប្រើប្រាស់ការវិនិច្ឆ័យដោយនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធានកម្មវិធីក្នុងការបែងចែកថ្លៃចំណាយសម្រាប់កម្មវិធី។
  - ដំណើរការ "**ពីក្រោមឡើងលើ**" ដែលអាចស្មុគស្មាញ ដោយការវិភាគលម្អិតពីការប្រើប្រាស់ពេលវេលា និងសម្ភារៈសម្រាប់បុគ្គលិកនៅក្នុងកម្មវិធីនីមួយៗ។

## ឧទាហរណ៍ទី១: ការវិភាជផ្អែកលើទំហំផ្ទៃក្រឡាការិយាល័យ

- កម្មវិធីចំនួន ៤ ប្រើប្រាស់ក្រឡាផ្ទៃការិយាល័យទំហំ ៥០,០០០ម៉ែត្រការ៉េតាមសមាមាត្រដូចខាងក្រោម÷
  - កម្មវិធីទី១ - 30%
  - កម្មវិធីទី២ - 40%
  - កម្មវិធីទី៣ - 20%
  - កម្មវិធីទី៤ - 10%
- ថ្លៃចំណាយប្រចាំឆ្នាំលើទំហំការិយាល័យមានចំនួន ១០លានរៀល
- ថ្លៃចំណាយប្រចាំឆ្នាំបែងចែកតាមកម្មវិធី÷
  - កម្មវិធីទី១ - 3,000,000រៀល
  - កម្មវិធីទី២ - 4,000,000រៀល
  - កម្មវិធីទី៣ - 2,000,000រៀល
  - កម្មវិធីទី៤ - 1,000,000រៀល

# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ




# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

## គោលបំណង÷

បន្ទាប់ពីការអនុម័តថវិកាប្រចាំឆ្នាំរួច ចាំបាច់ត្រូវការតាមដានការអនុវត្តលើចំនួនថវិកាអនុម័តដែលកំពុងចំណាយថាតើលទ្ធផលក្នុងឆ្នាំគ្រោងទុកទទួលបានដូចការរំពឹងទុកដែរឬទេ។ ពេលកំពុងអនុវត្តថវិកា ព័ត៌មាននេះអាចផ្តល់ឲ្យថ្នាក់ដឹកនាំក្រសួង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវការឆ្លុះបញ្ចាំងថា តើមានបញ្ហានៅក្នុងការអនុវត្តថវិកាដែរឬទេ។

## ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

ដើម្បីបំពេញគោលបំណងខាងលើ គួរមានឧបករណ៍សំខាន់ចំនួន ៣÷

- **ការតាមដាន** គឺជាការត្រួតពិនិត្យឡើងវិញជាប្រចាំ ឬតាមពេលកំណត់លើការអនុវត្តកម្មវិធី។
- **ការធ្វើរបាយការណ៍** គឺជាការរាយការណ៍ព័ត៌មាន ឬទិន្នន័យអំពីការអនុវត្តថវិកា (ដោយបំពេញទម្រង់ដែលរៀបចំរួចជាស្រេច) ដើម្បីដាក់ជូនទៅស្ថាប័នគ្រប់គ្រង។
- **ការវាយតម្លៃ** គឺជាការប្រៀបធៀបលទ្ធផលនៃការអនុវត្ត កម្មវិធីទៅនឹងការគ្រោងទុក។

## ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ



# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

- វិធីសាស្ត្រមួយក្នុងការវាស់វែងថវិកាដែលល្អ គឺធ្វើការប្រៀបធៀប ថវិកាដើមឆ្នាំ ដែលអនុម័តដោយសភា ជាមួយនឹងថវិកាជាក់ស្តែង ដែលបានអនុវត្តក្នុងឆ្នាំសារពើពន្ធ។
- តារាងខាងក្រោម ជាស្តង់ដារអន្តរជាតិនៃកម្មវិធីចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ:

| ពិន្ទុ | លក្ខខណ្ឌតម្រូវអប្បបរមា (PEFA) |
|---|---|
| A | គម្លាតនៃចំណាយជាក់ស្តែងពីផែនការ មិនលើសពី 5% |
| B | គម្លាតនៃចំណាយជាក់ស្តែងពីផែនការ មានចាប់ពី 5 - 10% |
| C | គម្លាតនៃចំណាយជាក់ស្តែងពីផែនការ មានចាប់ពី 10 - 15% |
| D | គម្លាតនៃចំណាយជាក់ស្តែងពីផែនការ លើសពី 15% |

# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

មូលហេតុទូទៅសម្រាប់ភាពលម្អៀងពីផែនការ÷

- ការយឺតយ៉ាវក្នុងការទទួលបានមូលនិធិថវិកា
- ការព្យាករចំណូលមិនត្រឹមត្រូវ
- ការរកមិនបាននូវធនធានសំខាន់ៗ (សម្ភារៈផ្គត់ផ្គង់ បុគ្គលិក)
- ការយឺតយ៉ាវក្នុងកិច្ចលទ្ធកម្ម
- ការគ្រប់គ្រងកម្មវិធីមិនគ្រប់ជ្រុងជ្រោយ
- ការរៀបចំកម្មវិធីមិនត្រឹមត្រូវ
- កត្តាខាងក្រៅដែលមិនអាចដឹងមុន

## ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

### ការវាយតម្លៃ

- ដំណើរការ ឬសកម្មភាពវាយតម្លៃភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពកម្មវិធី ធៀបនឹងគោលបំណងជាក់លាក់។

## ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

### ការវាយតម្លៃ

- ខុសគ្នាពីការតាមដាន
  - មានរយៈពេលវែង និងលក្ខណៈជាយុទ្ធសាស្ត្រ
  - ផ្តោតលើលទ្ធផលចុងក្រោយ
- មុខងារស្នូលនៃការវិភាគថវិកា
  - ពិនិត្យមើលទិន្នន័យ
  - ឧបករណ៍វិភាគ
  - មូលដ្ឋាននៃការវិភាជធនធាន
- ឲ្យដឹងអំពីការបង្កើត និងការរៀបចំផែនការថវិកានាពេលអនាគត

# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

ការវាយតម្លៃពាក់ព័ន្ធនឹងទិដ្ឋភាពនៃកម្មវិធីដូចខាងក្រោម÷

| | |
|---|---|
| ភាពសក្តិសិទ្ធិ | តើកម្មវិធីសម្រេចតាមគោលដៅបានកម្រិតណា? |
| ប្រសិទ្ធភាព | តើលទ្ធផលកម្មវិធី អាចទទួលបានទេ ប្រសិនបើប្រើប្រាស់ថ្លៃចំណាយទាបជាងនេះ? |
| សុពលភាព | តើកម្មវិធីនៅតែបន្តមានន័យដែរឬទេ? |

# ការតាមដាន ការធ្វើរបាយការណ៍ និងការវាយតម្លៃ

| | |
|---|---|
| ឥទ្ធិពល | តើមានការផ្លាស់ប្តូរជាក់ស្តែងដែរឬទេ? ដូចជាកម្រិតវិជ្ជមាន ឬអវិជ្ជមាននៃឥទ្ធិពលចំពោះអត្ថគាហកជាដើម។ ដូចនេះ ត្រូវវាស់វែងពីសូចនាករលទ្ធផលចុងក្រោយ។ |
| ជម្រើស | តើមាន ឬនឹងមានយុទ្ធសាស្ត្រ ឬកម្មវិធីប្រកបដោយភាពស័ក្តិសិទ្ធជាងមុនសម្រាប់ដោះស្រាយបញ្ហា ព្រមទាំងសម្រេចគោលបំណងដែរឬទេ? |
| ចីរភាព | ជាមួយនឹងថ្លៃចំណាយសមរម្យ តើកម្មវិធីអាចនឹងបន្តសម្រេចលទ្ធផលនាពេលអនាគតបានដែរឬទេ? |

# ឧបសម្ព័ន្ធទី ៣

**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា
# រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥

*«ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព»*

**បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា**

**នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២**

**ត្រូវនឹងថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៩**

# ២. ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ថវិកាជាតិឬថវិការដ្ឋ រួមមាន ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ។ ថវិកាថ្នាក់ក្រោមជាតិសំដៅដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ថវិកាថ្នាក់ជាតិសំដៅដល់ថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ការគ្រប់គ្រង និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១។

ផ្នែកនេះ នឹងរៀបរាប់អំពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមានការគ្រប់គ្រងរដ្ឋបាលសាធារណៈ ការគ្រប់គ្រងបុគ្គលិកនិងការកសាងសមត្ថភាព ការគ្រប់គ្រងសេវារដ្ឋបាលនិងសេវាសាធារណៈ ការគ្រប់គ្រងថវិកា កិច្ចលទ្ធកម្ម និងច្បាប់ បទប្បញ្ញត្តិនិងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា។

## ២.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈ

បច្ចុប្បន្ន រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈកម្ពុជាមានពីរកម្រិត គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិសំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ចំណែកឯរដ្ឋបាលថ្នាក់ក្រោមជាតិចែកជាបីប្រភេទ រួមមាន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ រាជធានី ត្រូវបានបែងចែកជា ខណ្ឌ ហើយរដ្ឋបាលខណ្ឌចែកចេញជា សង្កាត់។ ខេត្ត ចែកចេញជាក្រុង និងស្រុក ខណៈដែលក្រុងត្រូវបានបែងចែកជាសង្កាត់ និងស្រុកត្រូវចែកចេញជាឃុំ។ បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានរាជធានី ខេត្តចំនួន២៥ ក្រុង ស្រុក ខណ្ឌចំនួន២០៣ ឃុំ សង្កាត់ចំនួន ១ ៦៤៦ និងភូមិចំនួន ១៤ ៣៨៣។ រដ្ឋបាលឃុំ សង្កាត់ត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សា និងគណៈអភិបាលនៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ចំណែកឯឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតសកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសស្របតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យទៅបំរើការងារជាមួយក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ប្រធានមន្ទីរជំនាញរាជធានី ខេត្ត

នៃក្រសួង ស្ថាប័ន ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីនៃក្រសួងស្ថាប័នសាមីតាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័ត។

បច្ចុប្បន្ន ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំតាមយន្តការត្រួតពិនិត្យជាមុនដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ លើកលែងតែថវិកាឃុំ សង្កាត់ គឺមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តថវិកាដោយផ្ទាល់។ រតនាគាររាជធានី ខេត្ត ដើរតួនាទីជាគណនេយ្យករសាធារណៈ និងទូទាត់ចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីប្រភេទ។

## ២.២. ការគ្រប់គ្រងបុគ្គលិក និងការកសាងសមត្ថភាព

ការរៀបចំ និងការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដូចជាច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ទទួលខុសត្រូវរៀបចំផែនការបុគ្គលិកគ្រប់ប្រភេទគ្រប់ខ័ណ្ឌនៅពេលមានតម្រូវការធនធានមនុស្សដើម្បីបំពេញភារកិច្ច និងករណីកិច្ចឆ្លើយតបទៅនឹងតម្រូវការការងារដែលរដ្ឋបាលនីមួយៗត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំនីមួយៗធ្វើឡើងនៅរាល់ត្រីមាសទី១ នៃឆ្នាំ ដើម្បីដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំបន្ទាប់ ដោយមានការគាំទ្រពីមន្ទីរមុខងារសាធារណៈ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ គោលការណ៍ បែបបទ និងនីតិវិធីនៃការរៀបចំផែនការបុគ្គលិកត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មន្ត្រីទទួលបន្ទុកភាគច្រើនមិនសូវមានជំនាញ និងមានការផ្លាស់ប្តូរជាញឹកញាប់ ដោយហេតុផលផ្សេងៗ ជាពិសេស នៅរដ្ឋបាលក្រុង ស្រុក។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានខិតខំផ្តល់ការណែនាំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការគាំទ្រពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារ រាជធានី ខេត្ត។

ទោះបីជាមានយន្តការក្នុងការពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់គ្រូបង្គោល និងមន្ត្រីជំនាញក៏ដោយ ក៏សមត្ថភាពមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ។ លើសពីនេះទៀត ការធ្វើទំនើបកម្ម ការពង្រឹងប្រព័ន្ធថវិកាតាមរយៈការដាក់ឱ្យរដ្ឋបាលរាជធានី ខេត្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា

និងអនុវត្តថវិកាកម្មវិធី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ទាមទារឱ្យមានការពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃតម្រូវការការងារក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

## ២.៣. ការគ្រប់គ្រងសេវារដ្ឋបាល និងសេវាសាធារណៈ

ក្នុងពេលបច្ចុប្បន្ន សេវាសាធារណៈដែលមានលក្ខណៈជា ***«សេវារដ្ឋបាល»*** មួយចំនួនធំត្រូវបានប្រមូលផ្តុំផ្តល់ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងសេវាសាធារណៈមួយចំនួនទៀតមិនទាន់ត្រូវបានផ្តល់ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅឡើយ។ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយ ដែលជាយន្តការសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវារដ្ឋបាលចាំបាច់នានា ដែលបានផ្ទេរពីរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ហេតុនេះ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយជាទីកន្លែងដែលប្រជាពលរដ្ឋមកស្នើសុំ និងទទួលឯកសារសំណុំបែបបទ និងព័ត៌មានពេញលេញពាក់ព័ន្ធនឹងប្រភេទសេវារដ្ឋបាល កម្រៃ និងពេលវេលានៃការផ្តល់សេវារដ្ឋបាល។ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយ ដែលបានបង្កើតឡើងនៅគ្រប់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌចំនួន៨៣ កំពុងផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងវិស័យចំនួន១៤ (នីត្យានុកូលកម្ម អគ្រានុកូលដ្ឋាន អប់រំ សុខាភិបាល ដឹកជញ្ជូន សុរិយោដី សំណង់ ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ កសិកម្ម ឧស្សាហកម្ម និងរ៉ែនិងថាមពល)។ ស្របពេលជាមួយគ្នានេះ ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតឡើងដើម្បីទទួលបណ្តឹង និងផ្តល់ព័ត៌មានភាពមិនប្រក្រតី និងភាពខ្វះខាត ប្រព្រឹត្តដោយបុគ្គលិកនៃរដ្ឋបាលពាក់ព័ន្ធចំពោះអ្នកទទួលសេវាសាធារណៈ។ ក្រៅពីនេះ នៅមានសេវាសាធារណៈមួយចំនួន បាននិងកំពុងរៀបចំផ្ទេរតាមរយៈយន្តការផ្ទេរមុខងារ និងធនធានពីបណ្តាក្រសួង ស្ថាប័ន ទៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោះបីមានការបែកចែក និងការកំណត់ប្រភេទសេវាសាធារណៈ និងសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក៏ដោយ ក៏ការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានភាពច្បាស់លាស់ និងមិនទាន់បានធ្វើសមាហរណកម្ម និងតម្រឹមគ្នាក្នុងគោលដៅដើម្បីអោយការប្រើប្រាស់ធនធានដែលមានកម្រិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទអាចសម្រេចឱ្យបាននូវសមិទ្ធផលជាអតិបរមា។

## ២.៤ ការគ្រប់គ្រងថវិកា

### ២.៤.១.អំពីថវិកា

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសំដៅដល់ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ទទួលបានការឧបត្ថម្ភធនឬការផ្ទេរធនធានថវិកាពីថវិកាថ្នាក់ជាតិដើម្បីបំពេញចំណាយរបស់ខ្លួន។ ថវិការដ្ឋបាលរាជធានីខេត្តមួយចំណែកធំមានប្រភពពីចំណូលផ្ទាល់នៅមូលដ្ឋាន (ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ) និងមួយចំណែកទៀតទទួលបានការផ្ទេរថវិកាជាឧបត្ថម្ភធនពីថ្នាក់ជាតិ។ ចំណែកថវិការដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទទួលបានស្ទើរតែទាំងស្រុងដោយការផ្ទេរថវិកាពីថ្នាក់ជាតិតាមរយៈមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។ ការបែងចែកប្រភេទចំណូលសារពើពន្ធ គឺស្ថិតក្នុងទម្រង់នៃការចែករំលែកប្រាក់ចំណូលដុល (១០០%) ដែលកំណត់ដោយច្បាប់ជាមួយនឹងការត្រួតពិនិត្យទាំងស្រុងលើរចនាសម្ព័ន្ធពន្ធ ការកំណត់មូលដ្ឋានគិតពន្ធ និងអត្រាពន្ធជាដើម ដែលថ្នាក់ជាតិនៅតែដើរតួនាទីសំខាន់ក្នុងកិច្ចការនេះ។ យ៉ាងណាមិញ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចលុបចោលការយកកម្រៃលើសេវាសាធារណៈមួយចំនួន រួមទាំងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ (ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងជលយានយន្តធុនតូច) និងពន្ធសត្តឃាត។

ចំណូលសារពើពន្ធមានភាពខុសគ្នាខ្លាំងរវាងខេត្តមួយទៅខេត្តមួយ ផ្អែកតាមសក្តានុពលនៃការប្រមូលចំណូលនៅតាមតំបន់នីមួយៗ។ ចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រមាណ៣ភាគ៤ ត្រូវបានប្រមូលនៅរាជធានីភ្នំពេញ ដែលក្នុងនោះពន្ធលើអាករបំភ្លឺសាធារណៈត្រូវបានប្រមូលស្ទើរតែទាំងស្រុងនៅរាជធានីភ្នំពេញ។ ការប្រមូលចំណូលមិនមែនសារពើពន្ធពុំទាន់អនុវត្តបានល្អនៅឡើយ បើប្រៀបធៀបទៅនឹងចំណូលសារពើពន្ធ។

ដើម្បីបង្កើនធនធានហិរញ្ញវត្ថុបន្ថែមជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំបង្កើនកញ្ចប់ថវិកាបន្ថែមចំនួន ០,១%ប្រចាំឆ្នាំជូនរដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់។ មូលនិធិក្រុង ស្រុក នឹងកើនពី ១,១% (ឆ្នាំ២០១៩) ដល់ ១,៥% (ឆ្នាំ២០២៣) និងមូលនិធិឃុំ សង្កាត់នឹងកើនពី ៣% (ឆ្នាំ២០១៩) ទៅ ៣,៤% (ឆ្នាំ២០២៣) នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំមុន។ លើសពីនេះ ដើម្បីបង្កើននូវប្រភពធនធានហិរញ្ញវត្ថុបន្ថែមទៀត ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣% និងរដ្ឋបាលឃុំ សង្កាត់ ១% សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចប្រគល់ចំណូលពីពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន តាមប្រកាសលេខ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ***«ការប្រគល់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យជូនរដ្ឋបាលថ្នាក់ក្រោមជាតិ»***។

ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានវិសាលភាពធំ ដែលមានរដ្ឋបាលច្រើនអនុវត្តថវិកា និងត្រូវមានតម្លាភាព និងគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោម-

ជាតិនីមួយៗ។ បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត ឯកសារថវិកាពាក់ព័ន្ធ និងសៀវភៅថវិកាសម្រាប់ការគ្រប់គ្រងថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ព័ត៌មានស្តីពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.៤.២. រដ្ឋបាលរាជធានី ខេត្ត

បន្ទាប់ពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់ រាជរដ្ឋាភិបាលដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិ។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចេញសារាចរណែនាំដោយឡែកមួយទៀត ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រថវិកា គឺជាផែនការបីឆ្នាំរំកិលតាមអភិក្រមពីក្រោមឡើងលើ ដែលត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយរដ្ឋបាលរាជធានី ខេត្ត។ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំត្រូវរៀបចំរយៈពេល៥ឆ្នាំម្តង ចំណែកកម្មវិធីវិនិយោគពាឆ្នាំរំកិលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្តត្រូវបានរៀបចំដោយផ្អែកលើកម្មវិធី និងអាទិភាព ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ រួចដាក់ឱ្យក្រុមប្រឹក្សា រាជធានី ខេត្ត ពិនិត្យនិងអនុម័តមុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការយុទ្ធសាស្ត្រថវិកានេះ ត្រូវបានរៀបចំទៅតាមគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព ដោយមានខ្លឹមសារពិពណ៌នាអំពីគោលបំណង សូចនាករគន្លឹះនិងគោលដៅសូចនាករ ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ ការគ្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និង សង្កាត់ចំណុះរដ្ឋបាលរាជធានី ដែលជាថវិកាបានពីការវិភាជ និង ផ្ទេរពីមូលនិធិឃុំ សង្កាត់ និង ចំណូលដែលរដ្ឋបាលខណ្ឌ និង សង្កាត់ប្រមូលខ្លួនឯង ។ ថវិការដ្ឋបាលរាជធានី ខេត្ត បន្ទាប់ពីក្រុមប្រឹក្សាពិនិត្យនិងអនុម័តហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីចរចានិងយល់ព្រម។ ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ជាផ្នែកមួយនៃថវិកាជាតិ។ ផ្អែកលើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់នីមួយៗដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

## ២.៤.៣. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់ចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកាទេ ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលរបស់

រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួន ដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តសាមី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌមិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក បន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យនិងអនុម័តថវិការួច មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបថវិកានេះនៅតាមខេត្តនីមួយៗ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថវិកាក្រុងត្រូវគ្រោងបញ្ចូលថវិកាសង្កាត់ដែលជាថវិកាបានពីការវិភាជ និងផ្ទេរពីមូលនិធិឃុំ សង្កាត់ ព្រមទាំងចំណូលផ្ទាល់នៅមូលដ្ឋាន។ អភិបាលនៃគណៈអភិបាលក្រុងត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់ដល់រដ្ឋបាលសង្កាត់នីមួយៗ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

### ២.៤.៤. រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ពុំទាន់រៀបចំផែនការយុទ្ធសាស្ត្រថវិកាទេ ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល៣ឆ្នាំរំកិលរបស់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍រដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួន ដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ឃុំ និងសង្កាត់ចំណុះរាជធានីត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តសាមីដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍សង្កាត់ចំណុះក្រុង ត្រូវបញ្ជូនទៅរដ្ឋបាលក្រុងដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍នេះ មិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។ រដ្ឋបាលឃុំ សង្កាត់នីមួយៗរៀបចំថវិកាដោយខ្លួនឯង រួចដាក់ឱ្យក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័ត បន្ទាប់មកបញ្ជូនទៅរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងផ្តល់អនុលោមភាព។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំទៅអភិបាលនៃគណៈអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជារួម ការគ្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានរៀបចំឈរលើមូលដ្ឋានកំណើនប្រចាំឆ្នាំ ដោយផ្អែកលើចំណូលថវិកាដែលបានពីការផ្ទេរពីថ្នាក់ជាតិ ចំណូលផ្ទាល់របស់រដ្ឋបាលនីមួយៗ តម្រូវការអភិវឌ្ឍន៍ជាអាទិភាព គោលនយោបាយតម្លើងប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល និងកំណើនបុគ្គលិកមន្ត្រីរាជការ។

### ២.៤.៥. ការត្រួតពិនិត្យការអនុវត្តថវិកា

ក្នុងការអនុវត្តបច្ចុប្បន្ន យន្តការគ្រប់គ្រង និងនីតិវិធីអនុវត្តនៃការបញ្ជាចំណាយសម្រាប់រដ្ឋបាលរាជធានីខេត្ត ដូចគ្នាទៅនឹងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈត្រួតពិនិត្យ និងទូទាត់ចំណាយថវិកា។ រដ្ឋបាលក្រុង ស្រុក មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយ ប៉ុន្តែតម្រូវឱ្យមានការត្រួតពិនិត្យថវិកាពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនធ្វើការទូទាត់។ ចំណែកថវិការដ្ឋបាលឃុំ សង្កាត់ត្រូវបានផ្តល់សិទ្ធិស្វ័យសម្រេចក្នុងការចាត់ចែងបញ្ជាចំណាយដោយខ្លួនឯង។ ការត្រួតពិនិត្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ទាំងក្នុងដំណាក់កាលធានាចំណាយកិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់។ ការត្រួតពិនិត្យថវិកាត្រូវបានអនុវត្តដូចនៅថ្នាក់ជាតិដែរ ដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យករសាធារណៈ។

## ២.៥. កិច្ចលទ្ធកម្ម

បច្ចុប្បន្ន ការគ្រប់គ្រង និងការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២ តែមួយដូចនៅរដ្ឋបាលថ្នាក់ជាតិ។ ក្រៅពីច្បាប់នេះ មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានផ្សេងទៀតត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវគ្រប់គ្រង និងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដោយឡែកដែលចេញដោយក្រសួងមហាផ្ទៃ។ ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានធ្វើឡើងដោយគណៈកម្មាធិការលទ្ធកម្ម ឬ/និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ គឺជាប្រធានគណៈកម្មាធិការលទ្ធកម្ម។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចចេញគោលការណ៍ និងប្រកាសណែនាំ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ។ រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំដោយផ្អែកលើផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល តួលេខកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យនិងសម្រេចដោយគណៈកម្មាធិការលទ្ធកម្មរបស់ខ្លួន មុននឹងបញ្ជូនទៅក្រុមប្រឹក្សារៀងៗខ្លួនពិនិត្យ និងផ្តល់ការឯកភាព។ បន្ទាប់មក ផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណែកផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការអនុម័តជាផ្លូវការឱ្យបានមុនឆ្នាំអនុវត្តថវិកា។ ដោយឡែករដ្ឋបាលឃុំ សង្កាត់ មិនតម្រូវឱ្យមានផែនការលទ្ធកម្មប្រចាំឆ្នាំឡើយ។ ចំពោះមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបញ្ជូន

ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដើម្បីពិនិត្យ និងដាក់ចូលជាឧបសម្ព័ន្ធជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួងស្ថាប័នសាមី រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការអនុម័តជាផ្លូវការឱ្យបានមុនឆ្នាំអនុវត្តថវិកា។

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែក មន្ទីរជំនាញរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍មកក្រសួងស្ថាប័នសាមី ដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បច្ចុប្បន្ន ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បាននិងកំពុងអនុវត្តតាមបែបវិមជ្ឈការ និងវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ជាពិសេស រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈប្រកាសអន្តរក្រសួងលេខ៥៦៨ សហវ.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានពីរកម្រិត គឺកិច្ចលទ្ធកម្មស្ថិតក្រោមកម្រិតទឹកប្រាក់សិទ្ធិសម្រេចដោយរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ និងកិច្ចលទ្ធកម្មលើសកម្រិតទឹកប្រាក់សិទ្ធិសម្រេចដែលត្រូវស្នើសុំការពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ២.៦. ច្បាប់, បទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រប់គ្រង និងអនុវត្តតាមគោលការណ៍ និង វិធាននានា ដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ បានចែងអំពីគោលការណ៍ និងវិធានសំខាន់ៗសម្រាប់គ្រប់គ្រងនិងអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្រៅពីច្បាប់ទាំងពីរនេះ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនទៀតត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ លិខិតបទដ្ឋានគតិយុត្តទាំងនោះ ទោះបីជាត្រូវបានរៀបចំឡើងក្នុងគោលដៅ និងគោលបំណងរួមដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និង វិធានដែលបានកំណត់ដោយច្បាប់ទាំងពីរនេះក៏ដោយ ក៏លិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានរៀបចំឡើងដាច់ដោយឡែកៗពីគ្នាសម្រាប់គ្រប់គ្រង និងអនុវត្តថវិការបស់ថ្នាក់នីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

# ៣. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឆ្លងតាមបទពិសោធន៍នៃការអនុវត្តកន្លងទៅ និងផ្អែកតាមលទ្ធផលនៃការសិក្សាពិនិត្យឡើងវិញ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានឈានទៅរកសេចក្តីសន្និដ្ឋានជារួមថា ទិសដៅយុទ្ធសាស្ត្រនៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវកែសម្រួលស្របពេលជាមួយនឹងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។ រាជរដ្ឋាភិបាលបានដាក់ចេញឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ដោយបានកំណត់នូវមូលដ្ឋានគ្រឹះ និងទិសដៅសំខាន់ៗរួចជាស្រេច សម្រាប់ការរៀបចំឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសក្របខ័ណ្ឌពេលវេលា ដោយត្រូវពិនិត្យឡើងវិញនូវបទពិសោធន៍នៃការអនុវត្តកន្លងមក និងបរិការណ៍បច្ចុប្បន្ននៃកម្ពុជារួមទាំងកត្តាសមត្ថភាព និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈកាន់តែសាមញ្ញ ទន់ភ្លន់ និងប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ក្នុងគោលដៅផ្តល់ឆន្ទានុសិទ្ធិកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅក្នុងការអនុវត្តថវិកា។

ផ្នែកទី៣នេះ នឹងពិនិត្យឡើងវិញនូវបណ្តាគោលបំណងពាក់ព័ន្ធនៃឯកសារទស្សនាទាន បទពិសោធន៍មេរៀនដែលទទួលបានពីការអនុវត្តជាក់ស្តែង និងទិសដៅសំខាន់ៗសម្រាប់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលបានគូសរំលេចក្នុងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដើម្បីកំណត់ក្របខ័ណ្ឌពេលវេលា និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.១. ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០

ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ បានកំណត់គោលបំណងនៃការផ្លាស់ប្តូរជាបណ្តើរៗ ជាជំហានៗ ពី ***«ប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ »*** ទៅរក ***«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ»*** ត្រឹមឆ្នាំ២០២០។ ឯកសារទស្សនាទានបានកំណត់គោលបំណង និងវិសាលភាពនៃការកែទម្រង់ក្នុងក្របខ័ណ្ឌនៃវដ្តថវិកា ជាពិសេស ត្រូវធានាឱ្យបាននូវប្រព័ន្ធថវិកាមួយមានឯកភាព សង្គតិភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកា។ ក្នុងទិសដៅនេះ ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវតម្រឹមជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិ ដូចខាងក្រោម ÷

- ធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

- កែលម្អ និងផ្លាស់ប្តូរជាជំហានៗនៃវដ្តថវិការដ្ឋបាលរាជធានី ខេត្ត,ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ពិសេស កំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលទាំង៤នៃវដ្តថវិកា។
- ប្រព័ន្ធ និងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងថ្នាក់ជាតិ ដោយប្រើប្រាស់ចំណាត់ថ្នាក់ថវិកា ប្លង់គណនី និងទម្រង់របាយការណ៍ដូចគ្នា។

សរុបមក ឯកសារទស្សនាទាននេះ មានសារៈប្រយោជន៍សម្រាប់ជាមគ្គុទ្ទេសក៍នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមអភិក្រមកែទម្រង់ជាបណ្តើរៗ និងជាជំហានៗ ដោយត្រូវតម្រឹមជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិ ដែលមកដល់ពេលនេះ គឺកំពុងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ។

## ៣.២. ការត្រួតពិនិត្យលើការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការសិក្សាវាយតម្លៃអំពីភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) បានបង្ហាញថា ការផ្តួចផ្តើមដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធីនៅរដ្ឋបាលរាជធានី ខេត្ត គឺជាវឌ្ឍនភាពមួយសំខាន់ ហើយការកំណត់ចំនួនគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា គឺជាចំណុចវិជ្ជមានក្នុងការជំរុញឱ្យផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មឱ្យបានកាន់តែខ្លាំងឡើង ជាពិសេស បានធ្វើឱ្យដំណើរការរៀបចំ និង អនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាព និងគ្រប់គ្រងបាន។ គ្រប់រដ្ឋបាលរាជធានី ខេត្តទាំងអស់តម្រូវឱ្យរៀបចំថវិកាប្រចាំឆ្នាំទៅតាមគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពសម្រាប់ការពិភាក្សារៀបចំកញ្ចប់ថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុវត្តផ្ទាល់ដោយអង្គភាពថវិកានៃរដ្ឋបាលរាជធានី ខេត្ត។ ទោះជាយ៉ាងនេះក្តី ការរៀបចំថវិកាផ្អែកលើធាតុចូលនៅតែជាឯកសារផ្លូវការសម្រាប់ដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច។

***«អង្គភាពថវិកា»***ត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាម្ចាស់ក្នុងការគ្រប់គ្រង និងអនុវត្ត ដោយផ្សារភ្ជាប់រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម។ អង្គភាពថវិការបស់រដ្ឋបាលរាជធានី ខេត្ត គឺជារដ្ឋបាលរាជធានី ខេត្ត ដែលទទួលបន្ទុកផ្ទាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្តក្នុងនាមជាអាណាប័កដើមខ្សែ។ ***អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ*** គឺទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្តដែលមានតួនាទីចម្បងមួយចំនួន គឺការរៀបចំថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកា។ ទន្ទឹមនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស និងមគ្គុទ្ទេសក៍ជាច្រើនដល់រដ្ឋបាលរាជធានី ខេត្តមក ការរៀបចំថវិកា និងផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកាកម្មវិធីបានទទួលការគាំទ្រ និងចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរដ្ឋបាលរាជធានី ខេត្ត។

ជាមួយនឹងវឌ្ឍនភាពខាងលើ ការសិក្សាដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខ័ណ្ឌគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ (PEFA) បានបង្ហាញនូវចំណុចខ្វះខាតមួយចំនួន ដែលទាមទារនូវដំណោះស្រាយ រួមមាន÷

- ការរៀបចំខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកាក៏នៅមានភាពទន់ខ្សោយ ដោយសារការយល់ដឹងផ្នែកទស្សនាទាននៅមានកម្រិត ហើយសមត្ថភាពខុសៗគ្នានៃរដ្ឋបាលរាជធានី ខេត្ត បានធ្វើឱ្យការរៀបចំរចនាសម្ព័ន្ធកម្មវិធីនៅមិនទាន់បានល្អ
- ការចូលរួមពីគ្រប់ទីចាត់ការក្នុងរដ្ឋបាលរាជធានី ខេត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីមិនទាន់បានពេញលេញ
- ការកំណត់សូចនាករសមិទ្ធកម្ម និងលទ្ធផលចុងក្រោយមិនទាន់បានល្អដោយសារបញ្ហាសមត្ថភាព
- កង្វះទិន្នន័យជាទៀងទាត់ និងអាចជឿជាក់បានជាមូលហេតុចម្បងដែលធ្វើឱ្យរបាយការណ៍អំពីសូចនាករសមិទ្ធកម្មសំខាន់ៗមិនអាចយកទៅប្រើប្រាស់បាន ក្នុងគោលដៅរៀបចំផែនការថវិកាឱ្យមានប្រសិទ្ធភាព។

ជារួម ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មពេញលេញសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺមិនអាចសម្រេចបានទេតាមទិសដៅនៃទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ ដោយសារបញ្ហាប្រឈមមួយចំនួនដូចបានរៀបរាប់ខាងលើ ពិសេស សមត្ថភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិនៅមានកម្រិត។

## ៣.៣. ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

ឆ្លងកាត់តាមបទពិសោធន៍នៃការអនុវត្តតាមទិសដៅនៃទស្សនាទានស្តីពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០ កន្លងមក និងផ្អែកតាមការសិក្សាវាយតម្លៃរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអ្នកជំនាញពាក់ព័ន្ធស្តីពីវឌ្ឍនភាពនៃការអនុវត្តថវិកាកម្មវិធី បានបង្ហាញថា ការកំណត់គោលដៅឆ្នាំ២០២០ ក្នុងការចាប់ផ្តើមអនុវត្ត ***«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»*** គឺមានមហិច្ឆតាខ្ពស់ពេក។ ក្នុងន័យនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចាត់តាំងក្រុមការងារមួយ ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែងគឺ ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»*** ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងតថភាពជាក់ស្តែងនៃកម្ពុជា។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានឆ្លងកាត់ការសិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងពីបណ្តាប្រទេសមួយចំនួន ដូចជា ប្រទេសបារាំង ស៊ុយអែត ថៃ និងម៉ាឡេស៊ី ជាពិសេស ផ្អែកលើបទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែងរយៈពេលជាច្រើនឆ្នាំរបស់កម្ពុជាផ្ទាល់ ក៏ដូចជា

ការចូលរួមចែករំលែកបទពិសោធន៍ពីអ្នកជំនាញការជាច្រើននាក់ ព្រមទាំងបានឆ្លងកាត់ការពិភាក្សាជាច្រើនលើក ច្រើនសារនៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗ។

*ជាលទ្ធផល យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានផ្តល់ជាក្របខ័ណ្ឌទស្សនាទាន សម្រាប់តម្រង់ទិសការរៀបចំ* ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ -២០២៥»*** *ដូចខាងក្រោម÷*

ទី១-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្អែកលើ ***«ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច» «ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម»*** និង ***«ក្របខ័ណ្ឌថវិការយៈពេលមធ្យម»*** តែមួយ។

ទី២-ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំមានតែមួយ ដែលរួមមានថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការដ្ឋបាលរាជធានី ខេត្ត នឹងឆ្លុះបញ្ចាំងជាសរុបតាមថ្នាក់រដ្ឋបាលនីមួយៗ ដោយចែកជាថវិកាចរន្ត និងថវិកាមូលធនជាឧបសម្ព័ន្ធនៃច្បាប់។ ដោយឡែក ថវិការបស់រដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដុល។

ទី៣- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក តាមរយៈការធ្វើការតម្រឹមផែនការនីយកម្ម ដើម្បីសម្រេចគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ **(ដូចដែលបានបង្ហាញក្នុងដ្យាក្រាមទី១ខាងក្រោម)**។

ទី៤-គំរូនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិរបស់ប្រទេសបារាំងបានផ្តល់ជាមូលដ្ឋានទស្សនាទានដ៏សំខាន់សម្រាប់យកមកគិតគូររៀបចំប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបរិបទរបស់កម្ពុជា ពិសេស ***«ការអនុវត្តនិងការត្រួតពិនិត្យថវិកា»***។

ទី៥-ការផ្តល់អំណាច និងការទទួលខុសត្រូវដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត។

ទី៦-ការផ្តល់សិទ្ធិសម្រេច និងការទទួលខុសត្រូវដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តថវិកា ប៉ុន្តែជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយដោយរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ។

ទី៧-ការធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍នៅថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិក្នុងការធ្វើរបាយការណ៍។

ជារួម ទោះបីជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានផ្តល់នូវក្របខ័ណ្ឌទស្សនាទានសម្រាប់តម្រង់ទិសក្នុងការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកាព័តិមានសមិទ្ធកម្មនៅឆ្នាំ២០២៥ក្តី ក៏ *«ក្របខ័ណ្ឌពេលវេលា»* នេះចាំបាច់ត្រូវពិនិត្យឡើងវិញឱ្យសមស្របនៅក្នុងបរិការណ៍ និងសមត្ថភាពជាក់ស្តែងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។

*ផ្សាក្រាមទី១÷ក្របខ័ណ្ឌទស្សនាទាននៃសមាហរណកម្មផែនការនីយកម្មថវិកាថ្នាក់ជាតិ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ*




*ប្រភពឯកសារ÷យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥*

## ៣.៤. ទិសដៅ និងក្របខ័ណ្ឌពេលវេលានៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់យកគោលដៅសម្រាប់ធ្វើការផ្លាស់ប្ដូរប្រព័ន្ធថវិកាជាតិជាជំហានៗ ដើម្បីឆ្ពោះទៅអនុវត្ត ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** នៅឆ្នាំ២០២៥ ។ ប៉ុន្តែផ្អែកតាមបទពិសោធន៍ និងការអនុវត្តជាក់ស្ដែង ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពស្មុគស្មាញ និងសមត្ថភាពមន្ត្រីជំនាញនៅមានកម្រិត ដែលធ្វើឱ្យក្របខ័ណ្ឌពេលវេលានៃការកែទម្រង់ពីប្រព័ន្ធ ***«ថវិកាកម្មវិធី»*** ទៅប្រព័ន្ធ ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** ដែលបានកំណត់ខាងលើ មិនសមស្របនៅក្នុងបរិការណ៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជានោះទេ។

ក្នុងន័យនេះ ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»*** មានទិសដៅពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាបណ្ដើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដោយធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោល-នយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើសមាហរណកម្មផែនការនីយកម្មកម្រិតផែនការយុទ្ធសាស្ត្រ គឺការលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ។ ការធ្វើសមាហរណកម្មនៃផែនការនីយកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើឱ្យការគ្រោងផែនការ

សកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីប្រភេទមានលក្ខណៈប្រមូលផ្តុំ ដើម្បីតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ជាងមុន សម្រាប់ជាមូលដ្ឋានក្នុងការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត។ ការធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗវដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ពិសេស កំណត់ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។ ការធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងការបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិឱ្យធ្វើរបាយ-ការណ៍លទ្ធផលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត។

ជារួម ការអនុវត្ត «**ថវិកាព័ត៌មានសមិទ្ធកម្ម**» នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើឡើងនៅក្រោយឆ្នាំ២០២៥។ ចក្ខុវិស័យសម្រាប់ឆ្នាំ២០២៥ គឺការប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិកម្ពុជាតាមរយៈការកំណត់ក្របខ័ណ្ឌពេលវេលាច្បាស់លាស់ និងការដាក់ចេញផែនការសកម្មភាពកែទម្រង់តាមអភិក្រមដែលមានលក្ខណៈសាមញ្ញ ទន់ភ្លន់ និងតម្លាភាព ដោយត្រូវបានផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របតាមសមត្ថភាព និងតថភាពជាក់ស្តែងនៃកម្ពុជា។

# ៤. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥

គោលដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ -២០២៥ គឺពង្រឹងការអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញ និងកសាងមូលដ្ឋានសម្រាប់ការអនុវត្តថវិកាព័តិមានសមិទ្ធកម្ម ដើម្បីធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។ ក្នុងគោលដៅនេះ ការធ្វើសមាហរណកម្មផែនការនីយកម្មមានភាពចាំបាច់ដើម្បីឱ្យផែនការយុទ្ធសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក និងតម្រឹមទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ។ ការរៀបចំផែនការថវិកាប្រចាំឆ្នាំចាំបាច់ត្រូវធានាឱ្យមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា និងត្រូវឱ្យមានការចូលរួមកាន់តែទូលំទូលាយពីភាគីពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ការវិភាជ និងការអនុវត្តថវិកានឹងត្រូវបានបង្កើនប្រសិទ្ធភាពថែមទៀត តាមរយៈការកែលម្អ និងការធ្វើសាមញ្ញកម្មនីតិវិធីចំណាយ ជាពិសេស ការផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ការរៀបចំរបាយការណ៍នឹងត្រូវធ្វើឱ្យបានទាន់ពេលវេលា ហើយការបង្កើនសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើរបាយការណ៍តាមកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។

ផ្នែកទី៤នេះ ដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមដែលមានលក្ខណៈសាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព ដោយផ្តោតលើសមាសធាតុគន្លឹះនៃវដ្តថវិកា និងសមាសធាតុដែលជារចនាសម្ព័ន្ធទ្រទ្រង់រួមមានក្របខ័ណ្ឌគតិយុត្ត ការកសាងនិងអភិវឌ្ឍសមត្ថភាព និងប្រព័ន្ធបច្ចេកវិទ្យាព័តិមានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ ។ ក្រៅពីនេះ នៅមានការកែទម្រង់មួយទៀត ដែលចាត់ទុកជាសមាសធាតុសំខាន់នៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.១. វដ្តថវិកា

### ៤.១.១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

#### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់បានធ្វើសមាហរណកម្មនៃផែនការយុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការតម្រឹមជាមួយផែនការយុទ្ធសាស្ត្ររបស់មន្ទីរជំនាញរាជធានីខេត្តនៅឡើយទេ ដែលជាហេតុនាំឱ្យការប្រើប្រាស់ធនធានដែលមានកម្រិតមិនទាន់ទទួលបានសមិទ្ធផលជាអតិបរមា។ម្យ៉ាងទៀត ការតម្រឹមផែនការ/កម្មវិធីរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្តនៅមិនអាចសម្រេចទៅបាន ដោយសារតែពុំទាន់មានការប្រឹក្សាយោបល់គ្នា និងសហការគ្នាឱ្យបាន

គ្រប់គ្រាន់រវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺអនុវត្តក្នុងកម្រិតរដ្ឋបាលរាជធានី ខេត្ត ដែលផែនការនេះមិនរួមបញ្ចូលផែនការអភិវឌ្ឍន៍ក្រុង ស្រុក និងឃុំ សង្កាត់។

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមូលដ្ឋានសំខាន់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំដាច់ដោយឡែករវាងថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានយន្តការសម្របសម្រួលពិគ្រោះយោបល់តាមរយៈ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដើម្បីធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដោយ ក៏ភាពខុសគ្នានៃពេលវេលា វិធីសាស្ត្រ និងអភិក្រម បានធ្វើឱ្យដំណើរការនៃការធ្វើសមាហរណកម្មបញ្ចូលគ្នានេះពិបាកនឹងសម្រេចបាន។

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំតាមអភិក្រមពីក្រោមឡើងលើដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិ។ ជាមួយគ្នានេះ សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តនៅមានកម្រិត ដែលបង្ហាញឱ្យឃើញពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ជាពិសេស ការគ្រោងថវិកា ការកំណត់សូចនាករសមិទ្ធកម្មនៅក្នុងកម្មវិធី និងចង្កោមសកម្មភាព។ ប្រការនេះបានធ្វើឱ្យការរៀបចំផែនការថវិកាមិនទាន់ផ្សារភ្ជាប់បានទាំងស្រុងទៅនឹងគោលបំណងគោលនយោបាយ ដែលធ្វើឱ្យការប្រើប្រាស់ធនធានសាធារណៈមិនទាន់មានប្រសិទ្ធភាព។

### ខ. ទិសដៅឆ្នាំ២០២៥

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត នឹងត្រូវធ្វើការកែលម្អជាបណ្តើរៗឱ្យក្លាយជាផែនការយុទ្ធសាស្ត្រថវិការួម ហៅថា «**ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត**» តាមរយៈការធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួងស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត) ដូចបានបង្ហាញក្នុងដ្យាក្រាមទី១ក្នុងផ្នែកទី៣ខាងលើ។ ដំណើរការនេះ គឺធានាឱ្យមានការផ្សារភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ/ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា។ តាមគោលដៅនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដោយផ្តោតជាសំខាន់លើវិស័យអាទិភាពនៅមូលដ្ឋាន ដើម្បីគាំទ្រដល់អាទិភាពគោលនយោបាយរដ្ឋបាលរាជធានី ខេត្ត ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យ និង អាទិភាពជាតិ។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់នឹងត្រូវដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទៅតាមអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់តាមអភិក្រមពីក្រោមឡើងលើ។ ជាមួយគ្នានេះ ផែនការរបស់មន្ទីរជំនាញរាជធានី ខេត្តនឹងត្រូវយកមកគិតគូរក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដើម្បីផ្តល់ភាពងាយស្រួលដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការតម្រឹមសកម្មភាពរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាព និងចំគោលដៅ។

ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺជាឧបករណ៍សំខាន់ ដែលត្រូវរៀបចំឱ្យមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការពង្រីកវិសាលភាពឱ្យគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ (ថវិការដ្ឋ ឧបត្ថម្ភធន ការផ្ទេរធនធានថវិកាដៃគូ និងចំណូលផ្ទាល់) និងគ្រប់មុខសញ្ញាចំណាយទាំងអស់ (ចំណាយបៀវត្ស ចំណាយចរន្តមិនមែនបៀវត្ស និងចំណាយមូលធន)។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តនឹងត្រូវរៀបចំទៅតាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយមានសេចក្តីពន្យល់ ខ្លឹមសារពិពណ៌នាអំពីគោលបំណង ប្រភេទហិរញ្ញប្បទាន សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវចំពោះកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដែលនឹងត្រូវលើកឡើងនៅក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងត្រូវរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

ដើម្បីសម្រេចបាននូវដំណើរការនៃការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត តម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលរវាងក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណាក់កាលនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវធ្វើការសម្របសម្រួលដោយ ***«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»*** ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មុននឹងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តត្រួតពិនិត្យនិងអនុម័ត រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រការនេះនឹងជួយកាត់បន្ថយពេលវេលា និងជួយសម្រួលដល់ដំណើរការនៃការរៀបចំ និងត្រួតពិនិត្យផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពជាងមុន។

ជាមួយគ្នានេះ ការបង្កើនការគាំទ្រពីមន្ត្រីជំនាញនៅថ្នាក់ជាតិ តាមរយៈការផ្តល់នូវការប្រឹក្សាយោបល់បច្ចេកទេសទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការចាំបាច់បំផុត។ ចំណុចនេះនឹងលើកយកមកពិភាក្សានៅផ្នែកហេដ្ឋារចនាសម្ព័ន្ធគាំទ្រខាងក្រោម។

ជារួម ដោយសារផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្តត្រូវបានរៀបចំ ដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិចុះមក, ផែនការយុទ្ធសាស្ត្រថវិកានេះ ក៏ត្រូវផ្តល់ភាពទន់ភ្លន់ឱ្យមានការដាក់បញ្ចូលនូវអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពរនានាពីរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជាអភិក្រមពីក្រោមទៅលើ។

### គ. ផែនទីចង្អុលផ្លូវ

រៀបចំកែលម្អឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធី ដើម្បីធានាឱ្យមានការផ្សារភ្ជាប់ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយត្រូវកំណត់គោលដៅកម្មវិធី អនុកម្មវិធី និងសូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល ដោយត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០១៩ និងសម្រេចឱ្យ

បាននៅឆ្នាំ២០២០។ ធ្វើសមាហរណកម្មជាបណ្តើរៗនូវផែនការរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ និងតម្រឹមផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត ដោយត្រូវចាប់ពីឆ្នាំ២០២១តទៅ។

ដើម្បីគាំទ្រដល់ការសម្រេចបានតាមទិសដៅខាងលើ មានសកម្មភាពមួយចំនួន ដូចជា÷

ទី(១)-ពង្រឹងយន្តការសម្របសម្រួល និងពិគ្រោះយោបល់តាមរយៈ ***«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»*** របស់រាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិ ដែលកិច្ចការនេះនឹងត្រូវកំណត់នៅពេលរៀបចំគោលការណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

ទី(២)-ជ្រើសរើសមន្ត្រីបច្ចេកទេសពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមជាមួយនឹងការផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងលក្ខខណ្ឌការងារច្បាស់លាស់។ កិច្ចការនេះនឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០២០។

ទី(៣)-ផ្តល់ការបង្ហាត់បង្រៀន (Coaching and Mentoring) ដល់មន្ត្រីទទួលបន្ទុកការងាររៀបចំផែនការយុទ្ធសាស្ត្រ និងផែនការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.១.២ ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ

### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំផែនការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានដំណើរការផ្សេងៗគ្នារវាងថវិកាមន្ទីរជំនាញរាជ-ធានី ខេត្ត និងរវាងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ថវិកាមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបានគ្រោងបញ្ចូលក្នុងផែនការថវិកាដែលរៀបចំឡើងដោយក្រសួងស្ថាប័នសាមី ដោយផ្អែកលើផែនការ-នីយកម្មពីលើចុះក្រោមទៅតាមអាទិភាពជាតិ។ គម្រោងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបានរៀបចំ និងទទួលខុសត្រូវដោយរដ្ឋបាលផ្សេងៗគ្នា ដោយផ្អែកតាមប្រភពថវិកាដែលរៀបចំផ្ទេរពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការព្យាករនូវលទ្ធភាពចំណូលសរុបរបស់រដ្ឋបាលនីមួយៗ។ គម្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានី។ គម្រោងថវិការបស់រដ្ឋបាលក្រុងត្រូវបូកបញ្ចូលគម្រោងថវិការដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង។

ការរៀបចំផែនការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ទីរជំនាញរាជធានី ខេត្តផ្អែកតាមយន្តការនៃការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រអាទិភាពផ្សេងៗគ្នា ហើយការរៀបចំផែនការថវិកានេះ ក៏មិនទាន់មានសង្គតិភាពគ្នាទាំងស្រុងជាមួយនឹងយុទ្ធសាស្ត្រអាទិភាពនៅឡើយទេ។ ការរៀបចំផែនការថវិការបស់មន្ទីរជំនាញរាជធានី ខេត្តផ្អែកតាមផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងស្ថាប័ន ដែលបានផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍ជាតិ។ ផែនការថវិការបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលបានផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួន។ ចំណែកផែនការថវិការបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ គឺផ្អែកតាមផែនការអភិវឌ្ឍន៍

៥ឆ្នាំ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលរបស់រដ្ឋបាលនីមួយៗ។ ជាទូទៅ ការរៀបចំផែនការថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មានភាពយឺតយ៉ាវ។

ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅមានកម្រិត។ ការរៀបចំផែនការថវិកានៅរដ្ឋបាលរាជធានី ខេត្ត មាននាយកទីចាត់ការហិរញ្ញវត្ថុជាអ្នកសម្របសម្រួល រៀបចំ ដើម្បីសុំការសម្រេចពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ នៅរដ្ឋបាលក្រុង ស្រុក មានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុជាអ្នករៀបចំនិងសម្របសម្រួល ដើម្បីសុំការសម្រេចពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក។ នៅរដ្ឋបាលឃុំ សង្កាត់ មានស្មៀនជាអ្នកសម្របសម្រួល និងរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីសុំការសម្រេចពីមេឃុំ និងចៅសង្កាត់។ អង្គភាពថវិកាត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាម្ចាស់លើការរៀបចំ និងការអនុវត្តថវិកាក្នុងនាមជាអាណាប័កដើមខ្សែ ក៏ប៉ុន្តែមានរដ្ឋបាលខេត្តមួយចំនួនធំនៅមិនទាន់បង្កើតក្រុមការងារថវិកានៅឡើយ។

ការរៀបចំគម្រោងថវិកាកម្មវិធីរបស់រដ្ឋបាលខេត្ត នៅមានភាពយឺតយ៉ាវ និងមិនទាន់មានគុណភាពល្អគ្រប់គ្រាន់។ ការរៀបចំខ្លឹមសារនៃរចនាសម្ព័ន្ធកម្មវិធីមានភាពទន់ខ្សោយ និងមិនទាន់បានល្អគ្រប់ជ្រុងជ្រោយដោយសារការយល់ដឹងផ្នែកទស្សនាទាននៅមានកម្រិត ហើយសមត្ថភាពខុសៗគ្នានៃរដ្ឋបាលរាជធានី ខេត្ត។ ការកំណត់សូចនាករលទ្ធផលនៃកម្មវិធីមិនទាន់ត្រឹមត្រូវល្អ ដោយសារកង្វះទិន្នន័យដែលអាចជឿជាក់បាន សមត្ថភាពយល់ដឹងនៅមានកម្រិត និងការចូលរួមពីគ្រប់ទីចាត់ការក្នុងរដ្ឋបាលរាជធានី ខេត្ត មិនទាន់បានពេញលេញ។

ការរៀបចំថវិកា និងការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង៧ (សេដ្ឋកិច្ច រដ្ឋបាល មុខងារ ភូមិសាស្ត្រ កម្មវិធី មូលនិធិ និងគម្រោង) មិនអាចអនុវត្តបានពេញលេញ។ ចំណាត់ថ្នាក់កម្មវិធី កំពុងដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត ដែលអនុវត្តថវិកាកម្មវិធី លើកលែងតែរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ សម្រាប់ចំណាត់ថ្នាក់ពីរទៀត គឺចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់គម្រោង នៅមានការលំបាកក្នុងដាក់ឱ្យអនុវត្ត ដែលប្រការនេះទាមទារឱ្យមានការសិក្សាបន្ថែមទៀត។ ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់បញ្ចូលសម្រាប់អនុវត្តក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ដោយឡែកចំពោះផែនការថវិការបស់រដ្ឋបាលឃុំ សង្កាត់ នៅមានភាពយឺតយ៉ាវក្នុងការដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ដោយសារការរៀបចំគម្រោងថវិកាមិនទាន់ពេលវេលា។

## ខ. ទិសដៅឆ្នាំ២០២៥

គោលបំណងនៅឆ្នាំ២០២៥ គឺជាការពង្រឹងភាពគ្រប់ជ្រុងជ្រោយនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗតាមរយៈការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ដើម្បីសម្រេចបានកិច្ចការនេះ គឺត្រូវធ្វើឱ្យមានសង្គតិភាពគ្នារវាងផែនការថវិកាប្រចាំឆ្នាំជាមួយនឹងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នឹងត្រូវធ្វើការសម្របសម្រួលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីឱ្យផែនការថវិកាមានការផ្សា-

ភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ/កម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ដំណើរការនេះអាចសម្រេចបានតាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលបានបង្កើតឡើងសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដូចដែលបានរៀបរាប់ខាងលើ។

ការរៀបចំផែនការថវិកានឹងត្រូវផ្អែកលើមូលដ្ឋានព័ត៌មានលទ្ធផលនៃការអនុវត្តឆ្នាំមុន បែបបទ និងនីតិវិធីដែលបានកំណត់ និងគោលការណ៍ចំណាយចាំបាច់ ជាពិសេស ត្រូវមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា និងត្រូវធានាឱ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយថវិកា ដើម្បីពង្រឹងគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានភាពគ្រប់ជ្រុងជ្រោយ និងគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ (ថវិការដ្ឋ ឧបត្ថម្ភធន ការផ្ទេរធនធាន ថវិកាដៃគូ និងចំណូលផ្ទាល់) និងគ្រប់មុខសញ្ញាចំណាយទាំងអស់ (ចំណាយបៀវត្ស ចំណាយចរន្តមិនមែនបៀវត្ស និងចំណាយមូលធន)។ ទន្ទឹមនឹងនេះ ការរៀបចំថវិកានឹងប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង ៧ ឱ្យបានពេញលេញ ដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

### គ. ផែនទីចង្អុលផ្លូវ

ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្ត **«ថវិកាព័ត៌មានសមិទ្ធកម្ម»** នៅក្រោយឆ្នាំ២០២៥ ការរៀបចំថវិកាកម្មវិធីនឹងត្រូវពង្រីកទៅគ្រប់រដ្ឋបាលខេត្តនៅឆ្នាំ២០២០ និងរាជធានីភ្នំពេញនៅឆ្នាំ២០២១។ ស្របពេលជាមួយគ្នានឹងការពង្រីកការអនុវត្តថវិកាកម្មវិធីដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់គម្រោងនឹងត្រូវដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២១។ ដោយឡែក ចំណាត់ថ្នាក់មុខងារនឹងត្រូវធ្វើការសិក្សានៅឆ្នាំ២០២០ ដើម្បីពិនិត្យលទ្ធភាពដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ក្នុងគោលដៅពង្រឹងការរៀបចំថវិកាប្រចាំឆ្នាំ ការរៀបចំ និងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) សម្រាប់រដ្ឋបាលរាជធានី ខេត្តនឹងត្រូវចាប់ផ្តើមពីឆ្នាំ២០២២តទៅ។

## ៤.១.៣. ការចរចាថវិកា និងការអនុម័តថវិកា

### ក. ការអនុវត្តបច្ចុប្បន្ន

ទោះបីជាការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ជួបប្រសព្វគ្នានៅកម្រិតរាជធានី ខេត្ត ក៏ដំណើរការនៃការរៀបចំគម្រោងថវិកាទាំងពីរនេះធ្វើឡើងតាមដំណើរការពីរផ្សេងគ្នា។ គម្រោងថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈក្រសួងស្ថាប័នសាមី។ ចំណែកថវិការដ្ឋបាល រាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត ហើយត្រូវបញ្ជូនគម្រោងថវិកានេះទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចរចានិងយល់ព្រម និងបូកសរុបដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក គឺមានភាពខុសប្លែកពីរដ្ឋបាលរាជធានី ខេត្ត ដោយគម្រោងថវិកាក្រុង ស្រុកត្រូវបានពិនិត្យ និង

អនុម័តដោយក្រុមប្រឹក្សា រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុប មុននឹងបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យនិងផ្តល់អនុលោមភាព។ ចំពោះរដ្ឋបាលឃុំ សង្កាត់វិញ ត្រូវរៀបចំគម្រោងថវិកា រួចដាក់ជូនក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័ត បន្ទាប់មកបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យនិងផ្តល់អនុលោមភាព។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលជាផ្នែកមួយនៃថវិកាជាតិ។ ដំណើរការចរចាថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនទាន់បានយកគម្រោងថវិកាតាមកម្មវិធីមកជាមូលដ្ឋានសម្រាប់ការពិភាក្សាថវិកាទេ។

ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត មានដំណើរការ និងផ្អែកលើការផ្សារភ្ជាប់ផ្សេងៗគ្នា។ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តត្រូវបានពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាសាមី រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាសាមី រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលឃុំ សង្កាត់ គឺមិនតម្រូវឱ្យមានផែនការលទ្ធកម្មប្រចាំឆ្នាំឡើយ។ ចំណែកផែនការលទ្ធកម្មប្រចាំឆ្នាំរបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវបញ្ជូនទៅក្រសួងស្ថាប័នសាមី ដើម្បីដាក់បញ្ចូលក្នុងឧបសម្ព័ន្ធរួម រួចផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ផ្អែកលើផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងតួលេខកញ្ចប់ថវិកាប្រចាំឆ្នាំរៀងៗខ្លួន។

តាមនីតិវិធីបច្ចុប្បន្ន ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំនិងអនុម័ត ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា នៅក្រោយកិច្ចចរចាថវិកាប្រចាំឆ្នាំ។ អង្គភាពលទ្ធកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនមិនបានបញ្ចប់សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំតាមពេលវេលាកំណត់ ដែលនាំឱ្យការអនុវត្តចំណាយតាមនីតិវិធីលទ្ធកម្មមិនទាន់ពេលវេលា និងមានប្រសិទ្ធភាព។

### ខ. ទិសដៅឆ្នាំ២០២៥

នៅពេលដែលការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិក្លាយជាផែនការរួមរបស់រាជធានី ខេត្ត តាមរយៈការធ្វើសមាហរណកម្មបញ្ចូលគ្នានូវផែនការយុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត ការពិនិត្យ និងសម្របសម្រួលដោយរដ្ឋបាលរាជធានី ខេត្ត លើគម្រោងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជាការចាំបាច់ ដើម្បីធានាបាននូវសង្គតិភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា។ រដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវធ្វើអាទិភាវូបនីយកម្មចំណាយក្នុងអំឡុងពេលនៃការធ្វើការពិនិត្យ និងសម្របសម្រួល ដើម្បីសន្សំសំចៃថវិកា និងឆ្លើយតបទៅនឹងអាទិភាពនៅក្នុងមូលដ្ឋានឱ្យបានកាន់តែប្រសើរឡើង។ ដំណើរការនៃការចរចាថវិការដ្ឋបាលរាជធានី ខេត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលផ្អែកលើធាតុចូលបច្ចុប្បន្ននឹងត្រូវផ្លាស់ប្តូរជាបណ្តើរៗឆ្ពោះទៅរកការចរចាថវិកាតាមកម្មវិធី ដើម្បីប្រើប្រាស់ថវិកាឱ្យកាន់តែច្បាស់លាស់ និងមានប្រសិទ្ធភាពជាងមុន។

ការចរចាថវិកា ដែលបច្ចុប្បន្នផ្តោតទៅលើថវិការដ្ឋបាលរាជធានី ខេត្ត នឹងត្រូវធ្វើការពង្រឹង និងតម្រង់ទិសការចរចាថវិកាផ្តោតលើគោលនយោបាយ និងវិស័យជាអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដែលរួមមានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ក្នុងន័យនេះ យន្តការសម្របសម្រួលមួយនៅក្នុងកម្រិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវបង្កើតឡើង។ ទន្ទឹមគ្នានេះ គោលការណ៍ណែនាំស្តីពីការចរចាថវិកាថ្នាក់ក្រោមជាតិនឹងត្រូវរៀបចំឡើង ជាមូលដ្ឋានសម្រាប់ការចរចាថវិកាប្រចាំឆ្នាំ ស្របតាមទិសដៅនៃការអនុវត្តថវិកាព័តិមានសមិទ្ធកម្មក្រោយឆ្នាំ២០២៥។

សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដែលកន្លងមកត្រូវបានរៀបចំ និងអនុម័តក្រោយកិច្ចចរចាថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវជំនួសដោយធ្វើការពិនិត្យ និងសម្រេចផែនការលទ្ធកម្មនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកានៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូចគ្នានេះដែរ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពេលដំណាលគ្នានឹងផែនការថវិកា ដែលត្រូវដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីផ្តល់អនុលោមភាព។

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់មកជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំដើម្បីជាមូលដ្ឋាននៃការចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។ សេចក្តីព្រាងផែនការលទ្ធកម្មនឹងត្រូវធ្វើការកែសម្រួលឡើងវិញ ដោយផ្អែកលើលទ្ធផលនៃការចរចាថវិកា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។ នៅពេលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីជានិយ័តករពេញលេញ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### គ. ផែនទីចង្អុលផ្លូវ

ដំណើរការនៃការចរចាថវិការដ្ឋបាលរាជធានី ខេត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបច្ចុប្បន្នផ្អែកលើធាតុចូលនឹងត្រូវធ្វើការផ្លាស់ប្តូរជាបណ្តើរៗឆ្ពោះទៅការចរចាថវិកាផ្អែកលើកម្មវិធីចាប់ពីឆ្នាំ២០២២តទៅ។ គោលការណ៍ណែនាំស្តីពីការចរចាថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវរៀបចំឡើងនៅឆ្នាំ២០២១។

សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលត្រូវពិនិត្យ និងសម្រេចក្នុងក្របខ័ណ្ឌនៃការចរចាថវិការបស់រដ្ឋបាលរាជធានី ខេត្តជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០១៩ តទៅ។ ចំពោះការពិនិត្យនិងអនុម័តលើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រឹមឆ្នាំ២០២២ ហើយចាប់ពី២០២៣តទៅ ការពិនិត្យ និងអនុម័តលើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវប្រគល់សិទ្ធិជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៤.១.៤. ការអនុវត្ត និងការត្រួតពិនិត្យថវិកា

#### ក. ការអនុវត្តបច្ចុប្បន្ន

- **សិទ្ធិអំណាចនៃការបញ្ជាចំណាយ**

ក្នុងការអនុវត្តបច្ចុប្បន្ន រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់មានឆន្ទានុសិទ្ធិពេញលេញក្នុងការអនុវត្ត និងត្រួតពិនិត្យថវិកានៅឡើយ លើកលែងតែរដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន តម្រូវឱ្យស្នើសុំធានាចំណាយ និងការត្រួតពិនិត្យចំណាយ ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែកឯរដ្ឋបាលក្រុង ស្រុក ខណ្ឌ តម្រូវឱ្យមានការត្រួតពិនិត្យចំណាយដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រោយពេលដែលច្បាប់ថវិកាប្រចាំឆ្នាំចូលជាធរមាន និងសៀវភៅថវិកាប្រចាំឆ្នាំត្រូវបានដាក់ឱ្យអនុវត្ត រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់ ដែលមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ ដោយឡែកចំពោះមុខសញ្ញាចំណាយប្រតិបត្តិការប្រក្រតីផ្សេងៗទៀត ត្រូវបានអនុវត្តចំណាយតាមនីតិវិធីនៃការផ្តល់ធានាចំណាយ និងនីតិវិធីលទ្ធកម្មសាធារណៈ ។ យន្តការគ្រប់គ្រង និងនីតិវិធីអនុវត្តនៃការបញ្ជាចំណាយសម្រាប់រដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺដូចគ្នាទៅនឹងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យ ផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ ត្រួតពិនិត្យ និងទូទាត់ចំណាយថវិកា។ ដោយឡែក ថវិការដ្ឋបាលឃុំ សង្កាត់មិនតម្រូវឱ្យមានការធានាចំណាយទេ។

- **ការត្រួតពិនិត្យការអនុវត្តថវិកា**

ការត្រួតពិនិត្យចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមយន្តការមជ្ឈការទាំងក្នុងដំណាក់កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់។ ការត្រួតពិនិត្យថវិកាត្រូវបានអនុវត្តដូចនៅថ្នាក់ជាតិដែរ ដែលមកទល់ពេលនេះការត្រួតពិនិត្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ។ ការធ្វើនិយ័តកម្មថវិការបស់រដ្ឋបាលរាជធានី ខេត្តនៅមិនទាន់មានភាពទន់ភ្លន់ លើកលែងតែរដ្ឋបាលខេត្តដែលអនុវត្តថវិកាកម្មវិធី។

- **កិច្ចលទ្ធកម្ម**

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់បានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានពេញលេញដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលជាស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅឡើយ។ ការត្រួតពិនិត្យកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ដែលមានក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុដើរតួសំខាន់ ទាំងក្នុងដំណាក់កាលរៀបចំផែនការលទ្ធកម្ម និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម។ ដូចគ្នានេះដែរ ការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានត្រួតពិនិត្យដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

លិខិតបទដ្ឋានគតិយុត្តនាពេលបច្ចុប្បន្ន បានប្រគល់សិទ្ធិអំណាចពេញលេញដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យ និងសម្រេចលើការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។ តែទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង សិទ្ធិសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តកិច្ចលទ្ធកម្មនៅមានភាពមិនច្បាស់លាស់នៅឡើយ។

- **សវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ**

សវនកម្មផ្ទៃក្នុងដែលជាសេនាធិការរបស់អាណាប័កដើមខ្សែ មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា ព្រមទាំងអាចផ្តល់យោបល់ ឬអនុសាសន៍ចាំបាច់ជូនអាណាប័កដើម្បីពិនិត្យនិងសម្រេច ឬផ្តល់ការណែនាំ។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្តត្រូវកំណត់ និងអនុវត្តដោយសវនកម្មផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ ទោះបីរដ្ឋបាលរាជធានី ខេត្តក្លាយជាអណាប័កដើមខ្សែនៃអង្គ-ភាពថវិការបស់ខ្លួនក៏ដោយ។ ក្រៅពីមានសវនកម្មផ្ទៃក្នុង ក៏នៅមានអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្រៅ ដែលមានភារកិច្ចត្រួតពិនិត្យ វាយតម្លៃការអនុវត្តថវិកា និងផ្តល់អនុសាសន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ខ. ទិសដៅឆ្នាំ២០២៥

- **សិទ្ធិអំណាចនៃការបញ្ជាចំណាយ**

កត្តាគន្លឹះនៃភាពជោគជ័យនៃប្រព័ន្ធថវិកាកម្មវិធី គឺការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅដល់អ្នកគ្រប់គ្រងផ្ទាល់ក្នុងការចាត់ចែងធនធានឱ្យបានល្អ ដើម្បីសម្រេចសមិទ្ធផល។ នៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច ឥណទានថវិកានឹងក្លាយជាមូលដ្ឋានក្នុងការផ្តល់ការអនុញ្ញាតឱ្យបញ្ជាចំណាយពេញមួយឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការអនុញ្ញាតឱ្យបញ្ជាចំណាយនឹងត្រូវធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស ស្របតាមគោលការណ៍កំណត់ដោយធ្វើការបែងចែកធនធានទៅតាមកម្មវិធី អង្គភាពថវិកា មុខចំណាយ និងពេលវេលា។ នីតិវិធីនៃការអនុវត្តថវិកានឹងត្រូវបានធ្វើទំនើបកម្ម និងពន្លឿនថែមទៀត តាមរយៈការលើកកម្ពស់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក នឹងទទួលខុសត្រូវ និងមានគណនេយ្យភាពទាំងស្រុងចំពោះការអនុវត្ត និងត្រួតពិនិត្យហិរញ្ញវត្ថុ។ រដ្ឋបាលខណ្ឌ នៅតែជាអង្គភាពថវិកាដែលជាអាណាបក់ផ្ទេរសិទ្ធនៃថវិការាជធានីភ្នំពេញ ប៉ុន្តែសិទ្ធិអំណាចនឹងត្រូវបានគិតគូរផ្តល់ជូនបន្ថែមទៀតក្នុងការវិភាជថវិកា និងអនុវត្តថវិកាក្នុងឋានៈជាអង្គភាពថវិកានៃរដ្ឋបាលរាជធានីភ្នំពេញ។ ចំពោះការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់ចាំបាច់ត្រូវធ្វើការគិតគូរឡើងវិញនូវយន្តការនៃការសម្របសម្រួលនានា ដែលរួមទាំងការពិនិត្យ និងការកែសម្រួលលក្ខខណ្ឌ

វិនិច្ឆ័យ ការវិភាជថវិកា ការគ្រប់គ្រង និងការត្រួតពិនិត្យវាយតម្លៃការអនុវត្តមូលនិធិឃុំ សង្កាត់ និងនីតិវិធីលទ្ធកម្មសាធារណៈ ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តថវិកាប្រកប ដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការខ្ពស់នៃការផ្តល់សេវាសាធារណៈ។

## ➢ ការត្រួតពិនិត្យការអនុវត្តថវិកា

ដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវពន្លឿន និងធ្វើសាមញ្ញកម្មការអនុវត្តថវិកា ដោយត្រូវប្រគល់សិទ្ធិជាអតិបរមាតាមការវិវត្តនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ស្របតាមទិសដៅនេះ យន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត និងថវិកាមន្ទីរជំនាញរាជធានី ខេត្តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្ម, នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ទាល់កាន់តែច្រើនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងមុខងារត្រួតពិនិត្យផ្នែកចំណាយ សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនឹងត្រូវលើកកម្ពស់ថែមទៀត។

ដូចគ្នានឹងថវិកាថ្នាក់ជាតិដែរ ផ្អែកតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ មុខងារគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្តនឹងត្រូវបន្តអនុវត្តយន្តការដូចបច្ចុប្បន្នក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ ប៉ុន្តែត្រូវកាត់បន្ថយការត្រួតពិនិត្យឱ្យមកនៅត្រឹមកម្រិតអប្បបរមាតាមរយៈការរៀបចំគតិយុត្តឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាពព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធ FMIS និង E-Transfer។ នាពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិកាកាន់តែត្រូវបានកែលម្អស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងសមត្ថភាពនៃស្ថាប័នពាក់ព័ន្ធកាន់តែខ្ពស់ មុខងារគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្តអាចនឹងត្រូវធ្វើសមាហរណកម្មជាមួយនឹងមុខងារត្រួតពិនិត្យថវិកានៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យយន្តការត្រួតពិនិត្យមានលក្ខណៈកាន់តែមានប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយ ដែលជាបុរេលក្ខខណ្ឌសម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានគណនេយ្យភាពពេញលេញ ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកសមិទ្ធកម្ម។

ចំពោះថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាលឃុំ សង្កាត់ ការត្រួតពិនិត្យការអនុវត្តថវិកាត្រូវធ្វើតាមរយៈរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ។ លើសពីនេះ ក្នុងគោលបំណងពន្លឿន និងសម្រួលដល់ការអនុវត្តថវិកា ជាពិសេស ដើម្បីផ្តល់សេវាទូទាត់ឱ្យបានឆាប់រហ័ស គណនេយ្យករសាធារណៈអាចនឹងត្រូវដាក់ឱ្យនៅអមរដ្ឋបាល ក្រុង ស្រុក ដោយអាចពង្រីកជាជំហានៗទៅតាមលទ្ធភាព និងតាមការចាំបាច់ជាក់ស្តែង។ ការអនុវត្តថវិការដ្ឋបាល ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយ។ ចំណែកថវិការដ្ឋបាលខណ្ឌវិញ ដែលជាថវិកាចំណុះរាជធានីភ្នំពេញ ត្រូវអនុវត្តដូចបច្ចុប្បន្ន ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកត្រួតពិនិត្យការអនុវត្តថវិកា និងរតនាគាររាជធានីជាគណនេយ្យករសាធារណៈ។

ការស្នើសុំធ្វើនិយ័តកម្មថវិកាសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្ត នៅតែអនុវត្តតាមយន្តការដដែល ដោយត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក៏ប៉ុន្តែ ក្រោយពេលរដ្ឋបាលរាជធានី ខេត្តអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២១, ការផ្តល់ប្រតិភូកម្មអំណាចក្នុងការធ្វើនិយ័តកម្មឥណទានថវិកាដល់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវអនុវត្តក្នុងកម្រិតណាមួយសមស្រប។

## ➢ កិច្ចលទ្ធកម្ម

ក្នុងគោលបំណងពន្លឿន និងសម្រួលនីតិវិធីការងារ ការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មនឹងត្រូវបង្កើនជាបណ្តើរៗបន្ថែមទៀតជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញនៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់។ ការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជូនរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវអនុវត្តជាបណ្តើរៗតាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ មានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រងនិង/ឬមានវេទយិតភាពខ្ពស់ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវពង្រឹងជាបណ្តើរៗតាមរយៈការធ្វើសវនកម្មកិច្ចលទ្ធកម្ម ព្រមទាំងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌចំពោះការរំលោភបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងត្រូវទទួលបានសិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញក្នុងការពិនិត្យ និងសម្រេចលើការអនុវត្តកិច្ចលទ្ធកម្មពីក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាឱ្យបាននូវតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

ទន្ទឹមនឹងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវធ្វើការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្ម និងការធ្វើសវនកម្មកិច្ចលទ្ធកម្ម ដើម្បីធានាតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ព្រមទាំងធានាបាននូវតម្លៃសាច់ប្រាក់ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

## ➢ សវនកម្ម និង អធិការកិច្ចហិរញ្ញវត្ថុ

ដើម្បីធានាប្រតិតុល្យការ តួនាទី និងភារកិច្ចអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាំបាច់ត្រូវលើកកម្ពស់បន្ថែមទៀត។ ទោះយ៉ាងនេះក្តី ដើម្បីធានាប្រសិទ្ធភាព និងភាពសន្សំសំចៃខ្ពស់ ការងារអធិការកិច្ចហិរញ្ញវត្ថុនឹងត្រូវកំណត់ឱ្យធ្វើត្រឹមកម្រិតអប្បបរមាដោយឈរលើមូលដ្ឋាននៃភាពចាំបាច់ជាក់ស្តែង ការរាយការណ៍ដោយគណនេយ្យករសាធារណៈ និងការប្តឹងផ្តល់ឬព័ត៌មាននៃភាពមិនប្រក្រតីជាយថាហេតុ។ ក្របខ័ណ្ឌ និងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់ដោយឡែក។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង នឹងត្រូវរៀបចំឡើងដោយត្រូវមានការគិតគូររួមគ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

### គ. ផែនទីចង្អុលផ្លូវ

កត្តាគន្លឹះនៃភាពជោគជ័យនៃប្រព័ន្ធថវិកាកម្មវិធី គឺការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅដល់អ្នកគ្រប់គ្រងផ្ទាល់ក្នុងការចាត់ចែងធនធានឱ្យបានល្អដើម្បីសម្រេចសមិទ្ធផល។ តាមទិសដៅនេះ ការផ្តល់ការធានាចំណាយ និងការទូទាត់នឹងត្រូវពន្លឿន និងលើកកម្ពស់ប្រសិទ្ធភាពតាមរយៈការសម្រួលនីតិវិធីការងារ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំនួសឱ្យការប្រើប្រាស់ក្រដាសស្នាមយ៉ាងយូរត្រឹមឆ្នាំ២០២៥។ ការផ្ទេរឥណទាន ឬនិយ័តកម្មឥណទានថវិកានឹងត្រូវចាប់ផ្តើមធ្វើប្រតិភូកម្មអំណាចជាបណ្តើរៗកាន់តែច្រើនជាងមុនដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីឆ្នាំ២០២១។

យន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដែលត្រូវធ្វើតាមរយៈរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ ដែលត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវចាប់ផ្តើមរៀបចំដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយ និងបែបបទនៃការត្រួតពិនិត្យហិរញ្ញវត្ថុដែលមានបច្ចុប្បន្ន ជាពិសេស អនុក្រឹត្យលេខ៨១ និងអនុក្រឹត្យលេខ៨២ ព្រមទាំងបទដ្ឋាន-គតិយុត្តពាក់ព័ន្ធនានានឹងត្រូវកែលម្អឡើងវិញ ស្របតាមពេលវេលា និងទិសដៅដែលបានចែងក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ទាល់កាន់តែច្រើនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការអនុវត្តកិច្ចលទ្ធកម្មចាប់ពីឆ្នាំ២០១៩រហូតដល់មានការប្រគល់សិទ្ធិសម្រេចពេញលេញនៅឆ្នាំ២០២៥។ រដ្ឋបាលរាជធានី ខេត្ត នឹងទទួលបានសិទ្ធិសម្រេចពេញលេញក្នុងការអនុវត្តកិច្ចលទ្ធកម្មចាប់ពីឆ្នាំ២០២៥តទៅ។ ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌនឹងធ្វើឡើងតាមយន្តការមជ្ឈការដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្របខ័ណ្ឌ និងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នឹងត្រូវកំណត់ឱ្យបានច្បាស់លាស់នៅឆ្នាំ២០២០។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងរបស់អង្គភាពថវិកានៅរដ្ឋបាលរាជធានី ខេត្តនឹងត្រូវកំណត់ឱ្យបានច្បាស់លាស់ចាប់ពីឆ្នាំ២០២១។

## ៤.១.៥. ប្រព័ន្ធរបាយការណ៍, ការតាមដាន និង ការវាយតម្លៃថវិកា

### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំរបាយការណ៍ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពយឺតយ៉ាវ ហើយគុណភាពរបាយការណ៍ក៏មិនទាន់អាចក្លាយជាឧបករណ៍សម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ធ្វើជាមូលដ្ឋានវាយតម្លៃលទ្ធផលសម្រេចបានទាំងទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពគោលនយោបាយ/យុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានទាំងស្រុងឡើយ។

## ខ. ទិសដៅឆ្នាំ២០២៥

តាមទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដូចបានលើកឡើងនៅក្នុងផ្នែកទី៣ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងក្លាយជាផែនការដែលធ្វើសមាហរណកម្មនូវគ្រប់ប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះ របបរបាយការណ៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវធ្វើស្វ័យប្រវត្តិកម្មជាបណ្ដើរៗ ហើយសមត្ថភាពក្នុងការធ្វើរបាយការណ៍ថវិកាកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។ ប្រព័ន្ធរបាយការណ៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានលក្ខណៈសាមញ្ញ និងសមស្របទៅតាមការទទួលខុសត្រូវជាតតិយុត្តនៅថ្នាក់ក្រោមជាតិ។

របបរបាយការណ៍នៃចង្កោមកម្មវិធីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើពីក្រោមឡើងលើ។ រដ្ឋបាលឃុំ សង្កាត់ នឹងរាយការណ៍ពីវឌ្ឍនភាពក្នុងទម្រង់ជាលទ្ធផលក្នុងឆ្នាំនៃសកម្មភាពទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរាយការណ៍ពីវឌ្ឍនភាពនៃអនុកម្មវិធីទៅឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលនៅកម្រិតកម្មវិធី អនុកម្មវិធី និងរាយការណ៍ទៅក្រុមប្រឹក្សារាជធានី ខេត្ត និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទម្រង់នៃរបាយការណ៍ នឹងត្រូវកែសម្រួលជាជំហានៗ ដើម្បីបំពេញទៅតាមការតម្រូវរបស់ក្រុមប្រឹក្សារាជធានី ខេត្តផង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង។

សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវាយតម្លៃថវិកានៅមានកម្រិត ដូចនេះ រដ្ឋបាលថ្នាក់-ក្រោមជាតិ នឹងត្រូវអនុវត្តត្រឹមការតាមដានថវិកា និងការធ្វើរបាយការណ៍ថវិកា។ នៅពេលដែលប្រព័ន្ធតាមដាន និងរបាយការណ៍ថវិកាអនុវត្តបានល្អហើយ ប្រព័ន្ធវាយតម្លៃថវិកានឹងចាប់ផ្ដើមដាក់ឱ្យអនុវត្តសាកល្បងជាបណ្ដើរៗ ។

ការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តតាមទិសដៅវិមជ្ឈការ ដោយត្រូវផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ក្នុងន័យនេះ ចាំបាច់ត្រូវបង្កើតឱ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មឱ្យបានជាទៀងទាត់ និងប្រកបដោយប្រសិទ្ធភាព។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបូកសរុប រួចបញ្ជូនបន្តមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែក មន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំមកក្រសួងស្ថាប័នសាមីដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## គ. ផែនទីចង្អុលផ្លូវ

ការធ្វើរបាយការណ៍ និងការតាមដានការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវពិនិត្យមើលឡើងវិញដើម្បីរៀបចំបង្កើតឱ្យមានក្របខ័ណ្ឌ និងនីតិវិធីច្បាស់លាស់មួយសម្រាប់របាយការណ៍ផ្នែកហិរញ្ញវត្ថុ និងផ្នែកលទ្ធផល ។ គោលការណ៍ណែនាំស្ដីពីនីតិវិធីនៃការរៀបចំរបាយការណ៍ និងការតាមដានការអនុវត្តថវិកានឹងត្រូវរៀបចំចាប់ពីឆ្នាំ២០១៩ ហើយដាក់ឱ្យអនុវត្តនៅឆ្នាំ២០២០។

សម្រាប់គោលដៅនៅឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តត្រឹមការតាមដានថវិកា និងការធ្វើរបាយការណ៍ថវិកា។ ដោយឡែក នៅពេលដែលប្រព័ន្ធតាមដាន និងរបាយការណ៍ថវិកាអនុវត្តបានល្អហើយ, ប្រព័ន្ធវាយតម្លៃថវិកា នឹងចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងជាបណ្តើរៗក្រោយឆ្នាំ២០២៥ តទៅ។

## ៤.២. ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

### ៤.២.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា

ក្រៅពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ នៅមានលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ លិខិតបទដ្ឋានគតិយុត្តទាំងនោះ ទោះបីជាត្រូវបានរៀបចំឡើងក្នុងគោលដៅ និងគោល-បំណងរួម ដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និងវិធានដែលបានកំណត់ដោយច្បាប់ទាំងពីរនេះក៏ដោយ ក៏លិខិតបទដ្ឋានគតិយុត្តិទាំងនោះត្រូវបានរៀបចំឡើងដាច់ដោយឡែកៗពីគ្នា។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ ក្នុងន័យនេះ ក្រោយពេលដែលច្បាប់នេះត្រូវបានធ្វើវិសោធនកម្មច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ ក៏ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឡើងវិញដើម្បីធានាបាននូវសង្គតិភាពជាមួយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការពិនិត្យ និងរៀបចំប្រមូលផ្តុំឡើងវិញ ព្រមទាំងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តិទាំងនោះក្នុងគោលបំណងធានាឱ្យមានលិខិតបទដ្ឋានគតិយុត្តរួមតែមួយ ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីពាក់ព័ន្ធនានា ដែលអាចអនុវត្តបានដោយគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្របទៅតាមចរិតលក្ខណៈនៃរចនាសម្ព័ន្ធគ្រប់គ្រង សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

គោលដៅនៅឆ្នាំ២០២៥ គឺច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់-ក្រោមជាតិឆ្នាំ២០១១ ត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ ក្រោយពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត។ កិច្ចការនេះនឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០២០ និងបញ្ចប់នៅឆ្នាំ២០២២។ លិខិតបទដ្ឋានគតិ-យុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការពិនិត្យ និងរៀបចំប្រមូលផ្តុំឡើងវិញ ព្រមទាំងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដោយត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០២៣ និងបញ្ចប់នៅឆ្នាំ២០២៥។

### ៤.២.២. ការកសាង និង អភិវឌ្ឍសមត្ថភាព

ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់កាលទី៣ ដែលផ្ដោតទៅលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយភាពជាម្ចាស់ និងការទទួលខុសត្រូវភាគច្រើនត្រូវបានផ្ទេរទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការដាក់ឱ្យរដ្ឋបាលរាជធានី ខេត្តអនុវត្តថវិកាកម្មវិធីជាបណ្ដើរៗ ដែលជាជំហានមួយនៅលើទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងវិមជ្ឈការ។ ជាមួយគ្នានេះដែរ គោលដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺការបង្កើនធនធានថវិកាកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់ទៅនឹងការកសាងសមត្ថភាព និងក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់។

ដើម្បីសម្រេចបានគោលដៅនៃការធ្វើទំនើបកម្ម និងការពង្រឹងប្រព័ន្ធថវិកា ជាពិសេសការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺចាំបាច់ត្រូវឱ្យមានការកសាង និងអភិវឌ្ឍសមត្ថភាពដល់អ្នកអនុវត្តផ្ទាល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនឹងចាប់ផ្ដើមនៅឆ្នាំ២០១៩ និងមន្ត្រីជំនួយការឃុំ សង្កាត់ទទួលបន្ទុកហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់ នឹងទទួលការបណ្ដុះបណ្ដាលចាប់ផ្ដើមនៅឆ្នាំ២០២០។

### ៤.២.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

ការអនុវត្តប្រព័ន្ធ FMIS នឹងជួយកែលម្អការរៀបចំ និងការអនុវត្តថវិកាថ្នាក់ក្រោមជាតិ តាមរយៈការពន្លឿន និងធ្វើស្វ័យប្រវត្តិកម្មការទូទាត់ ការកត់ត្រាគណនេយ្យ និងការរៀបចំរបាយការណ៍។ ជាក់ស្ដែង ប្រព័ន្ធ FMIS ត្រូវបានពង្រីកដាក់ឱ្យអនុវត្តដល់គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត។ ដើម្បីឱ្យប្រព័ន្ធ FMIS ក្លាយជាឧបករណ៍សំខាន់សម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យអនុវត្តនៅគ្រប់រដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២២។